BIBLIOTHÈQUE
NATIONALE
DU CAMBODGE
P.K-1
1967-7

ក-242 ក



# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយខាងសាសនា និង អក្សរសាស្ត្រ
បេញរាល់ខែ ពីពុទ្ធសាសនបណ្ឌិត្យ

## បញ្ជីរឿង

ទំព័រ

*ផ្នែកសាសនា*

១ – បញ្ហាព្យាករណ៍ពីពុទ្ធសាសនា លោក សម-ថាំង ប្រែ-រៀបរៀង (ត) . . . . ៦៨១
២ – សម្ដែងអំពីសុខនិងទុក្ខ ដែលកើតអំពីកម្ម ព្រះសាសនមុនី កិម-ទូ រៀបរៀង. . . . ៦៩១
៣ – យោបល់ឯកឧត្ដម ឃឹម-ទិត ផ្ញើជូនសហ. សម-ថាំង . . . . . . . . ៧០៤

*ផ្នែកអក្សរសាស្ត្រ*

៤ – ពិចារណាដើម្បីយល់តក្កវិជ្ជា លោក ហ៊ុន គីមសៀ រៀបរៀង (ត) . . . . . ៧១០
៥ – វចនានុក្រម សំស្ក្រឹត-ខ្មែរ ព្រះមហា ជាំង–ខាត់ រៀបរៀង (ត) . . . . . ៧១៦
៦ – រឿងសាមកុក អ្នកឧកញ៉ាវិបុលរាជសេនា នូ-កន ប្រែរៀបរៀង (ត) . . . . . ៧២០
៧ – ឯកសារ សាស្ត្រាស្ទឹកវែងនិងក្រាំង លោក ញ៉ុក-ថែម រៀបរៀង (ត) . . . . ៧៣២
៨ – ឯកសារកម្ពុជសុរិយា លោក ឌ.គាម ប្រមូលរៀបរៀង (ត) . . . . . . ៧៤៥
៩ – សេចក្ដីជូនដំណឹងអំពីលទ្ធផលនៃប្រឡងប្រជែងខាងចំរៀងទម្លាប់ខ្មែរ
(ឆមាសទី ១ ឆ្នាំ ១៩៦៧) . . . . . . . . . . . . . ៧៥៦
១០ – ប្រកាសប្រឡងប្រជែងចំរៀងទម្លាប់ខ្មែរ (ក្នុងឆមាសទី ២ ឆ្នាំ ១៩៦៧) . . . . ៧៥៩

## *ផ្នែកកំណាព្យ និង ប្រវត្តិការណ៍*


១១— ព្រះរាជបុតហ្លាយ សម្តេចព្រះសង្ឃរាជ . . . . . . . ៧៦៦

១២— ព្រះរាជសុន្ទរកថានៃសម្តេចព្រះប្រមុខរដ្ឋក្នុងឱកាសពិធីថ្វាយសញ្ញាប័ត្របណ្ឌិតខាងអក្សរសាស្ត្រ បំពោះសម្តេចព្រះសង្ឃរាជ ថ្នាក់ទី ១ ជួន-ណាត . . . . . ៧៦៨


មួយឆ្នាំមាន ១២ សៀវភៅ តម្លៃជាវ ២៣០៛០០ ។

| វិវេកសាសនា |
|---|

| | |
|---|---|
| ពាក្យឃាត់មិនឲ្យ | ធ្វើការអាក្រក់ |
| ជាការណាមក, | ឲ្យធ្វើល្អទៅ, |
| ឲ្យជ្រះស្វាត់ចិត្ត | កុំឲ្យហ្មងសៅ, |
| បីនេះលោកហៅ | ពុទ្ធសាសនា ។ |

ប.ព.

# បញ្ហាព្យាករណ៍ពីពុទ្ធសាសនា

(ត)

លោក សម-ថាំង ប្រែ - រៀបរៀង

បុ. ព្រះពុទ្ធសាសនា មានតែសេចក្ដីពិតម្យ៉ាង ហើយស្របគ្នានឹងក្បួនវិទ្យាសាស្ត្រឬ ?

វិ. ព្រះពុទ្ធសាសនាសព្វថ្ងៃនេះ មានលាយឡំដោយសេចក្ដីជំនឿខុសចាកការណ៍ពិត ដូចគ្នានឹងសាសនាបុរាណដទៃដែរ ។ មនោគតិរបស់ពួកកវី, ជំនឿនិងការបង់លើកតំកើង របស់អ្នកប្រាជ្ញក្នុងព្រះពុទ្ធសាសនា ក្នុងជំនាន់នោះ ៗ សឹងនាំឲ្យមានសៅហ្មងដល់ព្រះពុទ្ធសាសនាខ្លះដោយអន្ទើ ១ ដែលត្រូវតែកែលុបបំបាត់ចោលចេញ ទើបគួរ ។

បុ. ចុះពុទ្ធមាមកជនពិតប្រាកដ ត្រូវមានបំណងយ៉ាងណា កាលបើគេឃើញសេចក្ដីជំនឿបូមចូលមកលុកលុយក្នុងសាសនាដូច្នេះ ?

វិ. ពុទ្ធសាសនិកជន គប្បីខ្វល់ខ្វាយស្រាវជ្រាវរកសេចក្ដីបួមនេះ ហើយបើល្មមធ្វើបាន គោងតែជួយបំបាត់ឲ្យអស់ចេញ, បានធ្វើសង្គាយនាយ៉ាងធំបីគ្រាហើយ ដើម្បីជ្រើសស្រាវជ្រាវសម្រាំងព្រះពុទ្ធសាសនាហើយបំបាត់សេចក្ដីបួមនេះចេញ ។

ប្រ. សង្គាយនានេះ ធ្វើពីកាលណាខ្លះ ?

វិ. លើកដំបូង ធ្វើក្នុងគុហាសត្តបណ្ណិ ពេលក្រោយព្រះបរមគ្រូចូលបរិនិព្វានទៅបន្តិច, លើកទី ២ នៅវាលុការាម ក្នុងក្រុងវេសាលី, លើកទី ៣ នៅអសោការាម ក្នុងបាតលីបុត្ត រវាង ២៣៥ ឆ្នាំក្រោយព្រះអង្គបរិនិព្វាន ។

ប្រ. ព្រះពុទ្ធជាម្ចាស់ បានផ្ដាំប្រយ័ត្នអំពីហេតុដែលនាំឲ្យព្រះពុទ្ធសាសនាអាប់ឱន នៅក្នុងគម្ពីរណា ?

វិ. នៅក្នុងគម្ពីរសំយុត្តនិកាយ ។

ប្រ. ព្រះសម្មាសម្ពុទ្ធ មានប្រៀនប្រដៅអំពីការជឿដែរឬទេ ?

វិ. មាន, ព្រះអង្គបានប្រកាសហាមប្រាមថា យើងមិនត្រូវជឿពាក្យដោយគ្រាន់តែគេនិយាយប្រាប់នោះទេ មិនត្រូវប្រកបតាមទំនៀមទម្លាប់ ជាតំណអំពីបុរាណនោះទេ មិនត្រូវជឿពាក្យបរម្បរាបែបនេះទេ ទាំងក្បួនច្បាប់ទាំងពួង ក៏មិនត្រូវជឿ ដោយគិតស្មានថាបានសរសេរទុកហើយដែរ មនោគតិដែលយើងគិតស្មានថា ជារបស់ទេវតា ៗ មតិដែលយើងយល់ឃើញដោយការស្មានខុសទំនង ឬក៏សេចក្ដីប្រដូច ឬ

សំដី ដែលប្រកបដោយអំណាចនៃគ្រូបាធ្យាយរបស់យើង ក៏យើងមិនត្រូវជឿដោយឥតពិចារណាទាំងអស់ ។

ប្ញ. ក្នុងព្រះពុទ្ធសាសនា មានបញ្ញត្តិត្រង់ណា ដែលតម្រូវឲ្យជឿដោយឥតពិចារណាឬទេ ?

វិ. ទេ, មានតែពុទ្ធទ្រង់ហាមដោយដាច់ខាតថា កុំជឿដោយឥតត្រិះរិះនោះ(១) ។

ប្ញ. បើដូច្នោះ យើងត្រូវជឿដូចម្តេចវិញ ?

វិ. លុះតែគម្ពីរពាក្យប្រៀនប្រដៅ ឬពាក្យសំដីនោះ សមប្រកបស្របគ្នានឹងសេចក្តីត្រិះរិះពិចារណារបស់យើង ។ យល់ថា ត្រឹមត្រូវហើយសឹមជឿ; ការជឿនេះ ព្រះអង្គបានបញ្ជាក់ថា តថាគតបានប្រដៅប្រាប់អ្នកហើយថា មិនត្រូវជឿដោយព្រោះតែថានោះទេ តែបើអ្នកត្រិះរិះក្នុងចិត្តទៅ ហើយយល់ព្រមថាគួរជឿ អ្នកធ្វើតាមប្រាថ្នាចុះ ( មើលក្នុងកាឡាមសូត្រគម្ពីរអង្គុត្តរនិកាយ និងមហាបរិនិព្វានសូត្រ ) ។

ប្ញ. ព្រះសម្មាសម្ពុទ្ធ ទ្រង់ទុកដាក់ព្រះអង្គថាជាបុគ្គលបែបណា ?

វិ. ទ្រង់ត្រាស់ថាព្រះអង្គនិងព្រះពុទ្ធដទៃទៀតគ្រាន់តែជាអ្នកប្រដៅប្រាប់សេចក្តីពិត ( សច្ចៈ ) ជាអ្នកនាំឬបង្ហាញផ្លូវប៉ុណ្ណោះទេ ឯសេចក្តីល្អគ្រប់យ៉ាងស្រេចនៅលើយើងគ្រប់គ្នាខំប្រឹងប្រែងសន្សំបំពេញខ្លួនឯងចុះ ។

---

១ ត្រង់នេះ ក្នុងច្បាប់ដើមមានដោះស្រាយពិស្តារជាងនេះ តែលោកអ្នកជួយកែសម្រួល លុបផ្តាច់ចោលវិញ យើងនៅទុកសេចក្តីដោះស្រាយនេះវិញ ។

បុ. ព្រះពុទ្ធដីកានេះ មាននៅក្នុងទីណា ?

វិ. មាននៅក្នុងគម្ពីរធម្មបទ ត្រង់វគ្គទី ២០ ។

បុ. ព្រះពុទ្ធសាសនា ពោលសរសើរកិច្ចកលមាយា ឬអ្វី?

វិ. គម្ពីរធម្មបទមានសំដែងថា ផ្កាមានតែពណ៌សម្បុរ ក៏មិនមានប្រយោជន៍ យ៉ាងណា វាចាជាសុភាសិត មិនមានផលប្រយោជន៍ដល់អ្នកដែលមិនប្រតិបត្តិតាម យ៉ាងនោះដែរ ។

បុ. ព្រះពុទ្ធសាសនា ប្រដៅឲ្យធ្វើអំពើអាក្រក់ដល់គ្នានិងគ្នាទៅវិញទៅមកឬទេ ?

វិ. ក្នុងគម្ពីរធម្មបទ ព្រះបរមគ្រូសំដែងថា " ទោះបីបុគ្គលណាប្រព្រឹត្តល្មើសខុសឆ្គងនឹងតថាគត ក៏តថាគត នៅតែសង្គ្រោះសន្តោសដោយមេត្តាចិត្ត ទៅរកបុគ្គលនោះវិញដែរ ទោះទោសកំហុសនោះធ្ងន់ប៉ុន្មានក៏ដោយ តថាគតក៏នៅតែសង្គ្រោះដោយសេចក្ដីល្អជាដរាប, នេះជាផ្លូវនៃព្រះអរហត្ត ។ ការចងពៀរព្យាបាទដល់គ្នាទៅវិញទៅមកនោះច្បាប់ព្រះពុទ្ធសាសនាបានបញ្ញត្តហាមប្រាមដាច់ខាត ។

បុ. ព្រះពុទ្ធសាសនា និយមការកាចសាហាវឃោរឃៅឬទេ ?

វិ. ទេ, ក្នុងបញ្ចសីល និងក្នុងព្រះសូត្រជាច្រើនអន្លើ ព្រះអង្គបានប្រដៅឲ្យផ្សាយមេត្តាចិត្ត ចំពោះសត្វទាំងអស់ គឺត្រូវតែស្រឡាញ់រាប់អាន និងរកឧបាយឲ្យបានសេចក្ដីសុខ ដល់គ្នានិងគ្នាជាដរាប ។

ព្រះអង្គបានសំដែងសូត្រថែមទៀតថា កុំឲ្យបំផ្លាញ ផ្តាច់បង់ជីវិតសត្វ ហេតុដល់ការធ្វើមនុស្សឃាត ឬក៏ជួយទំនុកបំរុងដល់អំពើនេះ ។

បុ. ព្រះអង្គត្រាស់សំដែងក្នុងសូត្រណា ?

វិ. ក្នុងធម្មិកសូត្រ ព្រះអង្គត្រាស់សំដែងថា បុគ្គលពុំគប្បីផ្តាច់បង់ជីវិត ឬយល់ព្រមដល់ការបំផ្លាញជីវិត ឬក៏មានចិត្តសោមនស្ស ចំពោះអំពើឃាតកម្មនោះឡើយ ។ ត្រូវតែវៀរចាកការបៀតបៀនសត្វទាំងពួង ។

បុ. ព្រះពុទ្ធសាសនាបានអនុលោមដល់ការផឹកនូវទឹកស្រវឹងឬទេ?

វិ. ក្នុងធម្មិកសូត្រ ព្រះអង្គបានក្រើនរំលឹកហាមយើងកុំឲ្យផឹកទឹកស្រវឹង ហើយមិនត្រូវកំឡាឬសោមនស្សនឹងមនុស្សអ្នកផឹកនោះឡើយ ។

បុ. សេចក្តីស្រវឹង នាំមកនូវទោសដូចម្តេច ?

វិ. នាំឲ្យគេមិនពប់គាន, នាំឲ្យហ៊ានប្រព្រឹត្តបទឧក្រិដ្ឋ, នាំឲ្យខូចសតិ (វិកលចរិត) ព្រមទាំងនាំមកនូវសេចក្តីងងឹត (អវិជ្ជា) ដែលជាហេតុនាំមកនូវជាតិទុក្ខជាដើម ។

បុ. ព្រះពុទ្ធសាសនា សំដែងដូចម្តេចអំពីផ្លូវកាម ?

វិ. ការប្រព្រឹត្តិនូវព្រហ្មចរិយធម៌ ជាហេតុនាំឲ្យចំរើនផ្លូវចិត្តវិសេសណាស់, តែបើមានស្វាមីភរិយាតែមួយហើយមិនប្រព្រឹត្តកន្លងចិត្តគ្នា គឺជាការប្រសើរដែរ ។ ឯការដែលមានភរិយាច្រើន ព្រះពុទ្ធជាម្ចាស់

ទ្រង់ត្មះតិះដៀលថា ជាហេតុនាំឲ្យដេកត្រាំនៅក្នុងសេចក្ដីងងឹត ហើយនាំឲ្យខូចចិត្តគំនិតផង ។

បុ. ពាក្យប្រដៅនេះ មាននៅទីណា ?

វិ. ក្នុងគម្ពីរអង្គុត្តរនិកាយ ។

បុ. ព្រះពុទ្ធសាសនា ប្រដៅឲ្យមាតាបិតាសង្គ្រោះកូនដូចម្ដេច ?

វិ. មាតាបិតាត្រូវទំនុកបំរុងហ្វឹកហ្វឺនប្រដៅបុត្រ ការពារកុំឲ្យប្រព្រឹត្តអំពើអាក្រក់ ឲ្យប្រព្រឹត្តអំពើល្អសុចរិតស្លូតត្រង់ ឲ្យរៀនសិប្បវិជ្ជាផ្សេងៗ រៀបចំកូនឲ្យមានស្វាមីភរិយាតាមសមគួរដល់វង្សត្រកូល ហើយចែកសម្បត្តិទ្រព្យឲ្យក្នុងកាលគួរ ។

បុ. បុត្រ ត្រូវទំនុកបំរុងមាតាបិតាដូចម្ដេច ?

វិ. ត្រូវទំនុកបំរុងបីបាច់រក្សាមាតាបិតាតាស់ជរា ក្នុងពេលដែលមាតាបិតាត្រូវការ ត្រូវថែរក្សាវង្សត្រកូលទ្រព្យសម្បត្តិឲ្យសមគួរជាអ្នកទទួលកេរ្ដិ៍មរតក កាលបើមាតាបិតាទទួលអនិច្ចកម្មទៅហើយ ត្រូវធ្វើបុណ្យទក្ខិណានុប្បទានឧទ្ទិសផលជូនគាត់ ។

បុ. ករណីយកិច្ចរបស់សិស្សចំពោះគ្រូបាធ្យាយ ដូចម្ដេចខ្លះ ?

វិ. សិស្សត្រូវគោរពកោតខ្លាចបំរើ ស្ដាប់បង្គាប់, បំពេញសេចក្ដីត្រូវការ ហើយស្ដាប់ពាក្យឱវាទដំបូន្មានរបស់គ្រូបាធ្យាយ ។

បុ. ករណីយកិច្ច ដូចម្ដេច ដែលស្វាមីត្រូវធ្វើចំពោះភរិយា ?

វិ. ត្រូវថ្នាក់ថ្នមនិយាយទៅកាន់ភរិយាដោយសំដីល្អ មិនកន្ទងចិត្តភរិយា ប្រគល់ឥស្សរិយយស ហើយទំនុកបំរុងដោយគ្រឿងស្លៀកពាក់ និងតុបតែងរាងកាយតាមការគួរ ។

បុ. ចុះភរិយា ត្រូវធ្វើចំពោះស្វាមីដូចម្តេច?

វិ. ត្រូវសម្តែងឫកពារឲ្យឃើញថា ខ្លួនមានសេចក្តីស្រឡាញ់ពិត ត្រូវគ្រប់គ្រងផ្ទះសម្បែងឲ្យល្អ ត្រូវទទួលរាក់ទាក់ចំពោះញាតិរបស់ស្វាមី និងភ្ញៀវ ត្រូវមានចិត្តត្រង់នឹងស្វាមី ចេះរក្សាសន្សំទ្រព្យ ហើយត្រូវជាអ្នកប៉ិនប្រសប់ និងមិនខ្ជិលច្រអូសក្នុងការងារ ។

បុ. ដំបូន្មានទាំងនេះ មាននៅក្នុងសូត្រណា?

វិ. ក្នុងសិង្គាលោវាទសូត្រ ។

បុ. ទ្រព្យសម្បត្តិជាជំនួយដល់ការស្វែងរកទីដ៏ប្រសើរក្នុងអនាគត របស់មនុស្សដែរឬទេ?

វិ. គម្ពីរធម្មបទសំដែងថា ផ្លូវដែលនាំទៅកាន់ព្រះនិព្វាន ដទៃអំពីផ្លូវដែលនាំឲ្យបាននូវភោគសម្បត្តិ ។

បុ. បើដូច្នេះ អ្នកដែលមានទ្រព្យសម្បត្តិស្តុកស្តម្ភ នឹងប្រាថ្នានូវព្រះនិព្វានពុំបានទេ ឬដូចម្តេច?

វិ. ស្រេចហើយតែនឹងបំណង របស់បុគ្គលនោះ, បើបុគ្គលនោះ បរិច្ចាគទ្រព្យសម្បត្តិដល់មហាជន ដើម្បីសង្គ្រោះមនុស្សអ្នកមាន

ដម្បី ត្រូវគេសង្កត់សង្កិន និងមនុស្សល្ងង់ខ្លៅ, បុគ្គលនោះ នឹងបានទទួលផលនៃបុណ្យដោយពិត ។

បុ. ចុះបើពុំបរិច្ចាគសម្បត្តិទ្រព្យដូច្នេះទេ តើដូចម្តេចវិញ ?

វិ. បើអ្នកមានសម្បត្តិនោះកំណាញ់ប្រស្សា ស្រឡាញ់លោភទុកទ្រព្យសម្បត្តិនោះ ដោយគិតតែពីចង់បាន, អកុសលចិត្តនឹងកើតមានដល់បុគ្គលនោះ ហើយនាំឲ្យប្រព្រឹត្តអំពើអាក្រក់, បុគ្គលនោះ នឹងសោយសោក ត្រូវគេនិន្ទាក្នុងលោកនេះផង ត្រូវទទួលផលនៃអំពើអាក្រក់នោះក្នុងបរលោកផង ។

បុ. គម្ពីរធម្មបទសំដែងអំពីអវិជ្ជា ដូចម្តេច?

វិ. ថាជាកំពូលនៃអកុសលគ្រប់យ៉ាងរបស់សត្វ ។

បុ. គម្ពីរធម្មបទសំដែងពីការឃើញទោសរបស់អ្នកដទៃដូចម្តេច?

វិ. ទោសរបស់អ្នកដទៃ បុគ្គលឃើញដោយងាយណាស់, ឯទោសរបស់ខ្លួន បុគ្គលពិបាកមើលយល់ណាស់, មនុស្សច្រើនតែបរិហារពីទោសរបស់គេ តាមខ្យល់ ដូចជាកំទេចអង្កាម ហើយលាក់បំបាំងទោសរបស់ខ្លួន ប្រៀបដូចជាអ្នកលេងខ្លាច់ ដែលបំបាត់នូវខ្លាច់របស់ខ្លួនមិនឲ្យអ្នកលេងផងគ្នាដឹង ។

បុ. ព្រះពុទ្ធជាម្ចាស់ទ្រង់ទូន្មានឲ្យសង្គ្រោះអ្នកក្រីក្រកំសត់ទុគ៌តដូចម្តេចខ្លះ?

វិ. ព្រះអង្គត្រាស់សំដែងឲ្យចែកទ្រព្យសម្បត្តិ ដែលខ្លួនរកបានមក ជា ៤ ចំណែក មួយចំណែកត្រូវទុកធ្វើជាទានដល់ស្មូមយាចក ។

ប្រ. ជំនួញ ៥ ប្រការដែលហាមថាជាជំនួញដ៏ថោកទាបនោះគឺអ្វីខ្លះ?

វិ. គឺលក់គ្រឿងស្រវឹង, លក់សត្វដែលសម្រាប់ពិឃាតយកសាច់, លក់ថ្នាំពិសពុល លក់គ្រឿងសស្ត្រាវុធ និងធ្វើជំនួញមនុស្សដូចគ្នា ។

ប្រ. បុគ្គលណាខ្លះ ដែលមិនបានទទួលសេចក្តីចំរើនដោយមគ្គនិងផល ក្នុងព្រះពុទ្ធសាសនា?

វិ. គឺបុគ្គល អ្នកធ្វើបិតុឃាតកម្ម មាតុឃាតកម្ម អរហន្តឃាតកម្ម ភិក្ខុដែលបំបែកសង្ឃ បុគ្គលអ្នកបៀតបៀនដល់កាយព្រះពុទ្ធ និងបុគ្គលដែលយល់ឃ្លាង យល់ខុស គឺ សស្សតទិដ្ឋិ និងឧច្ឆេទទិដ្ឋិ ។

ប្រ. ព្រះពុទ្ធសាសនា មានសំដែងអំពីទីកន្លែងសម្រាប់បុគ្គលអ្នកធ្វើអំពើលាមកទុច្ចរិត ដែលទំលាយកងកាយលះបង់លោកនេះហើយ ត្រូវទៅកើតរងទុក្ខវេទនាឬទេ?

វិ. មាន, គឺសញ្ជីវៈ, កាឡសុត្រៈ, សង្ឃាតៈ, រោរុវៈ, មហារោរុវៈ, តាបៈ, ប្រតាបៈ, អវិចិ ។

ប្រ. ទុក្ខវេទនាដែលមានដល់បុគ្គលនោះជានិច្ចគ្មានទីបំផុតទេឬ?

វិ. ទេ! ពុំមែនទេ, គឺកំណត់កាលទៅតាមសមគួរដល់កម្លាំងកម្មរបស់អ្នកធ្វើ ។

ប៉ុ. ព្រះពុទ្ធសាសនាមានប្រកាសថា បុគ្គលណាមិនជឿព្រះបរម-សម្ពុទ្ធ ត្រូវមានបាបឬទេ?

វិ. ពុំមែនដូច្នោះទេ ដោយការធ្វើអំពើល្អ បុគ្គលនោះនឹងបានទទួលផលជាសុខ តាមកាលកំណត់ តែត្រូវមានជាតិកំណើតតទៅទៀត ព្រោះលះកាមតណ្ហាពុំទាន់អស់ស្រឡះ, ដើម្បីចៀសវាងការអន្ទោលទៅមកក្នុងភព ត្រូវប្រតិបត្តិតាមគន្លងព្រះអរិយមគ្គ ៨ ប្រការ ។

ប៉ុ. ស្ត្រីនឹងបានសម្រេចផលដូចម្ដេចតាមច្បាប់ព្រះពុទ្ធសាសនា ?

វិ. ស្ត្រីមានឧបនិស្ស័យស្មើគ្នានឹងបុរសគ្មានខុសគ្នាទេ, ព្រះពុទ្ធជាម្ចាស់ព្រះអង្គសំដែងក្នុងចុល្លវេទល្លសូត្រថា ស្ត្រីមានសម្រេចផលជាន់ខ្ពស់ថ្នាក់អរហត្តបានដូចជាបុរសដែរ ។

ប៉ុ. ចុះមានយោបល់នៃអ្នកប្រាជ្ញទំនើបថាដូចម្ដេច អំពីអានុភាពនៃព្រះពុទ្ធសាសនាចំពោះស្ត្រី ?

វិ. លោក ឡឺប៉ែលគ្រីហ្វីន (Sir Lepelqriffin) ថា : ព្រះពុទ្ធសា-សនាអនុគ្រោះដល់ស្ត្រីក្នុងផ្លូវសួគ៌និព្វានលើសលែងសាសនាទាំងពួង ។

ប៉ុ. ព្រះពុទ្ធជាម្ចាស់ សំដែងអំពីវណ្ណៈថាដូចម្ដេច?

វិ. មនុស្សគ្មានបូលក្នុងវណ្ណៈណាមួយជាចណ្ឌាល ឬជាព្រាហ្មណ៍ដោយជាតិទេ ស្រេចហើយតែអំពើអាក្រក់ល្អ ។ ព្រះអង្គសំដែងថា អំពើអាក្រក់ល្អនេះ អាចធ្វើបុគ្គលឲ្យជាចណ្ឌាល ឬជាព្រាហ្មណ៍ ។ (មើលក្នុងវសលសូត្រ) ។

(នៅមានត)

## សម្តែងអំពី

## សុខ និង ទុក្ខ

ដែលកើតអំពី

# កម្ម

ព្រះសាសនមុនី ក៏ម-ទួរ ក្រុមជំនុំព្រះត្រៃបិដក ពុទ្ធសាសនបណ្ឌិត្យ

រៀបរៀង

នមត្ថុ រតនត្តយស្ស

សូមនមស្ការ ចំពោះព្រះរតនត្រ័យ ដោយគោរព!

មនុស្សសត្វទាំងឡាយ ដែលកើតមកក្នុងលោក សុទ្ធសឹងតែមានគោលបំណងតែមួយដូច ៗ គ្នា គឺចង់បានសេចក្តីសុខតែម្យ៉ាង ហើយស្អប់ខ្ពើមសេចក្តីទុក្ខ ពុំចង់ជួបប្រទះសោះឡើយ ។ សេចក្តីសុខ ជាឥដ្ឋារម្មណ៍ គឺអារម្មណ៍ជាទីប្រាថ្នា, ឯសេចក្តីទុក្ខ ជាអនិដ្ឋារម្មណ៍ គឺអារម្មណ៍មិនជាទីប្រាថ្នា របស់មនុស្សសត្វទូទៅគ្រប់ប្រភេទ ។ សេចក្តីសុខនិងសេចក្តីទុក្ខ ជាផលដែលកើតចេញមកពី កម្ម ឬថា កម្មជាមូលហេតុដែលនាំបង្កបង្កើតសេចក្តីសុខនិងសេចក្តីទុក្ខគ្រប់យ៉ាង ។

ពាក្យថា កម្ម ជាពាក្យកណ្តាល ពុំទាន់ប្រាកដថា ល្អ ឬ អាក្រក់នៅឡើយទេ ពោះធ្វើល្អ ក៏ហៅថា កម្ម ធ្វើអាក្រក់ ក៏ហៅថា កម្ម ។ បើលុះតែគេដាក់ កុសល ឬ អកុសល នាំមុខទៅជា កុសល-

កម្ម ឬជា អកុសលកម្ម ទើបអាចដឹងថា កម្មល្អ ឬកម្មអាក្រក់ ៗ សេចក្ដីសុខនិងសេចក្ដីទុក្ខ, បុណ្យនិងបាប, គុណនិងទោស, ល្អនិងអាក្រក់ ជាដើម ទាំងអស់នេះ កើតចេញពីកម្មហ្នឹងឯងជាប្រកត, ព្រោះហេតុនោះ មនុស្សទាំងឡាយ ដែលកើតមកក្នុងលោកសុទ្ធតែមានកម្ម គឺកុសលនិងអកុសល ជាប់មកជារបស់ខ្លួន គ្មាននរណាគេចចៀសវាងផុតពីកម្មបានឡើយ ៗ សេចក្ដីនេះ សមនឹងព្រះពុទ្ធដីកាក្នុងចូឡកម្មវិភង្គសូត្រ គម្ពីរមជ្ឈិមនិកាយថា : សព្វេ សត្តា កម្មស្សកា កម្មទាយាទា កម្មយោនី កម្មពន្ធូ កម្មប្បដិសរណា យំ កម្មំ ករិស្សន្តិ កល្យាណំ វា បាបកំ វា តស្ស ទាយាទា ភវិស្សន្តិ កម្មំ សត្តេ វិភជតិ យទិទំ ហីនប្បណីតតាយ សេចក្ដីថា សត្វសត្វទាំងអស់ សុទ្ធតែមានកម្មជារបស់ខ្លួន មានកម្មជាទាយាទ (មត៌ក) មានកម្មជាកំណើត មានកម្មជាផៅពង្ស ឬ ជាញាតិសន្តាន មានកម្មជាគ្រឿងរលឹក ឬជា ទីពឹងពំនាក់ បើនឹងធ្វើនូវកម្មណា ទោះល្អក្ដី អាក្រក់ក្ដី នឹងជាអ្នកទទួលយកនូវផលនៃកម្មនោះ កម្ម តែងបែងចែកសត្វទាំងឡាយដើម្បីឲ្យមានឋានៈថោកទាប និង ខ្ពង់ខ្ពស់ ៗ សេចក្ដីនៃពុទ្ធភាសិតនេះបញ្ជាក់ឲ្យឃើញច្បាស់ថា ពួកសត្វដែលមានឋានៈដ៏ខ្ពង់ខ្ពស់ ប្រកបដោយសេចក្ដីសុខ-ចម្រើនគ្រប់យ៉ាង អាស្រ័យដោយសារកុសលកម្ម, ពួកសត្វ

ដែលមានឋានៈដ៏ថោកទាប ប្រកបដោយសេចក្តីទុក្ខលំបាកគ្រប់យ៉ាង អាស្រ័យដោយសារអកុសលកម្ម ។

## សេចក្តីសុខចំរើនគ្រប់យ៉ាង កើតអំពីកុសលកម្ម

ការប្រព្រឹត្តិធ្វើអ្វីខ្លះ ទើបហៅថា កុសលកម្ម ? ការលះបង់ទុច្ចរិត ៣ យ៉ាង មានកាយទុច្ចរិតជាដើមចេញ ហើយប្រព្រឹត្តសុចរិត ៣ យ៉ាង មានកាយសុចរិតជាដើមក្តី ការប្រព្រឹត្តិធ្វើបុញ្ញកិរិយាវត្ថុ ១០ យ៉ាង មានការឲ្យទាន និងការរក្សាសីលជាដើមក្តី ។ល។ ទាំងអស់នេះហៅថា កុសលកម្ម ប្រែថា អំពើជាកុសល ឬអំពើល្អ ដែលជាហេតុនាំឲ្យកើតសេចក្តីសុខ សេចក្តីចម្រើនគ្រប់យ៉ាងដល់អ្នកធ្វើ ។

លំដាប់តទៅនេះ សូមពណ៌នាចំពោះតែកុសលកម្មរបស់អស់លោកអ្នកសប្បុរសទាំងឡាយដែលបានកសាងសេនាសនៈទុកសំរាប់ចំពោះព្រះពុទ្ធសាសនា ។ ផ្នែកខាង អកុសលកម្ម ដែលជាអំពើអកុសលផ្ទុយនឹងកុសលកម្ម ពុំបានលើកយកមកពណ៌នាក្នុងអត្ថបទនេះដងឡើយ ។

ការកសាងទីសម្រាប់ដេក និងទីសម្រាប់អង្គុយ មានកុដិ សាលា វិហារជាដើម តំកល់ទុកក្នុងព្រះពុទ្ធសាសនា ច្រើនហៅថា សេនាសនទាន ។ ទីកន្លែងមានរោង ឬសាលាជាដើម ដែលគេកសាងបិតទៅក្បែរផ្លូវតូចធំសម្រាប់ជ្រកស្នាក់សម្រាកអាស្រ័យមួយដងមួយកាល នៃជនអ្នកធ្វើដំណើរឆ្លងទៅគ្រប់ប្រទេស ច្រើនហៅថា ឧបស្សយដ្ឋាន ឬអាវសថទាន ។

## ការកសាងសេនាសនៈ

សេនាសនៈ បើចែកទៅតាមប្រភេទនៃវត្ថុសម្រាប់ប្រើប្រាស់ មាន ៤ យ៉ាង គឺ

១– វត្ថុ គឺទីកន្លែងជាសំណង់សម្រាប់ដេក-អង្គុយនៃបព្វជិត មាន កុដិ សាលា វិហារ អឌ្ឍយោគ គុហ ថែវ ជាដើម ហៅថា វិហារសេនាសនៈ ។

២– វត្ថុ ជារបស់សម្រាប់ប្រើប្រាស់ មានគ្រែ តាំង តុ កៅអី ជាដើម ហៅថា មញ្ចបីឋសេនាសនៈ ។

៣– វត្ថុ គឺគ្រឿងកម្រាលសម្រាប់ក្រាលដេក-អង្គុយ មានកន្ទេល ខ្នើយ ពូក ព្រំ ចៀមចំ ជាដើម ហៅថា សន្ថតសេនាសនៈ ។

៤– ទីកន្លែងណាមួយ មានទីសម្រាប់ចង្ក្រម ឬទីលាន បរិវេណ ជិតកុដិ សាលា វិហារ ជាដើម ឬក៏ទីសួនច្បារ ដីស្រែចំការ ដែលគេ វេរឧទ្ទិសដល់សង្ឃ ដាក់ទុកជារបស់សម្រាប់វត្ត ហៅថា ឱកាសសេនាសនៈ ។

## សេនាសនៈដែលកើតឡើងជាដំបូងក្នុងព្រះពុទ្ធសាសនា

កាលដែលព្រះសម្មាសម្ពុទ្ធបរមគ្រូនៃយើង ទើបនឹងត្រាស់ដឹងឡើង ជាដំបូង ពុំទាន់មានវត្តនិងសេនាសនៈ ដូចសម័យសព្វថ្ងៃនេះនៅឡើយ ទេ, ពួកបព្វជិតជាសាវ័ករបស់ព្រះអង្គដែលបួសហើយ ច្រើននៅក្នុងព្រៃ

យកសម្បកឈើ ឬយកគល់ឈើធ្វើជាវត្ត ឬជាសេនាសនៈ ។ ខាងក្រោយមក ព្រះសម្មាសម្ពុទ្ធ ដោយមានភិក្ខុសង្ឃជាព្រះអរហន្តតាមហែហមជាបរិវារ ទ្រង់យាងចូលទៅកាន់ក្រុងរាជគ្រឹះ ដើម្បីសំដែងធម៌ប្រោសព្រះបាទពិម្ពិសាររាជ តាមសេចក្តីបដិញ្ញាក្នុងកាលមុនដែលព្រះអង្គពុំទាន់បានត្រាស់ដឹង ។ លុះព្រះអង្គព្រមទាំងភិក្ខុសង្ឃ ទ្រង់យាងចូលទៅដល់ព្រះរាជនិវេសនដ្ឋាននៃព្រះបាទពិម្ពិសារហើយ ព្រះរាជាក៏ទ្រង់មានព្រះរាជហឫទ័យសោមនស្សជ្រះថ្លាដ៏ក្រៃលែង ទើបអារាធនានិមន្តព្រះអង្គព្រមទាំងភិក្ខុសង្ឃ ទទួលភត្តក្នុងវេលាព្រឹកស្អែក ។

គ្រានោះ ព្រះបាទពិម្ពិសារទ្រង់ព្រះតម្រិះថា ឥឡូវព្រះមានព្រះភាគមួយអន្លើដោយភិក្ខុសង្ឃ ពុំទាន់មានវត្ត ឬសេនាសនៈដ៏សមគួរសម្រាប់គង់នៅឡើយ បើដូច្នោះ តើព្រះអង្គគួរគង់នៅក្នុងទីណាហ្ន៎ ដែលជាទីមិនឆ្ងាយពេក មិនជិតពេក អំពីទីក្រុង ជាទីងាយស្រួលល្មមទៅមកនៃមនុស្សទាំងឡាយដែលត្រូវការផង ជាទីមិនច្របូកច្របល់ក្នុងវេលាថ្ងៃ មានសម្លេងតិចមិនឮសូរគឹកកងក្នុងវេលាយប់ផង មានខ្យល់បក់ស្រួល គួរដល់ការពួនសម្ងំនៅនៃមនុស្សទាំងឡាយផង ។ ព្រះរាជតម្រិះនៃព្រះបាទពិម្ពិសាររាជក្នុងខណៈនោះថា អើ! យើងមានឧទ្យានវេឡុវ័នមួយ, ឧទ្យាននេះ មិនឆ្ងាយពេក មិនជិតពេក អំពីទីក្រុង ជាទីស្រួលល្មមទៅមកបានដោយងាយនៃមនុស្សទាំងឡាយដែលត្រូវការ បើដូច្នេះ គួរអាត្មាអញវេរថ្វាយឧទ្យានវេឡុវ័ននុ៎ះ ដល់ភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ។ ក្នុង

ពេលនោះ ព្រះបាទពិម្ពិសាររាជ ទ្រង់កាន់កុណ្ឌីមាសដ៏ពេញដោយទឹក ប្រូចដាក់លើព្រះហស្តនៃព្រះសម្មាសម្ពុទ្ធ ហើយក៏ក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន! ខ្ញុំព្រះអង្គសូមវេរថ្វាយនូវឧទ្យានវេឡុវ័ននុ៎ះ ជាអាវាសដល់ភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ។ ព្រោះនិទាននេះឯង ទើបព្រះភគវ័តទ្រង់ធ្វើធម្មីកថាចំពោះព្រះបាទពិម្ពិសាររាជ មួយអន្លើដោយភិក្ខុ-សង្ឃទាំងឡាយ អនុញ្ញាតអារាមក្នុងពេលនោះថា អនុជានាមិ ភិក្ខវេ អារាមំ បដិគ្គហេតុំ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាត ដើម្បីឲ្យភិក្ខុទាំងឡាយទទួលនូវអារាមបាន ។ អារាមឈ្មោះវេឡុវ័ននេះ កើតមានឡើងជាដំបូងបំផុតក្នុងព្រះពុទ្ធសាសនា ដែលព្រះបាទពិម្ពិសាររាជ ក្រុងរាជគ្រឹះ បានវេរថ្វាយព្រះអង្គ ។ ខាងក្រោយមក ទើបព្រះរាជាទ្រង់ចាត់ការឲ្យកសាងសេនាសនៈផ្សេងៗទៀត ជានិវាសនដ្ឋាន ថ្វាយព្រះសម្មាសម្ពុទ្ធនិងភិក្ខុទាំងឡាយសម្រាប់គង់នៅជាប្រក្រតី ។

តាមសេចក្ដីដំណាលក្នុងគម្ពីរបរមត្ថទីបនី អដ្ឋកថាខុទ្ទកនិកាយ ថា វត្តវេឡុវ័ននោះ មានកំពែងកំពស់ ១៨ ហត្ថព័ទ្ធជុំវិញ មានគន្ធកុដិមួយសម្រាប់ជាទីគង់នៅ នៃព្រះសម្មាសម្ពុទ្ធជាម្ចាស់ មានសេនាសនៈដទៃទៀតជាច្រើន គឺ កុដិ អឌ្ឍយោគ ប្រាសាទ គុហា មណ្ឌល ទីចង្ក្រម និងក្លោងទ្វារជាដើម ជាសេនាសនៈសម្រាប់ភិក្ខុសង្ឃជាសាវ័ក

នៅជាប្រក្រតី ៗ នៅខាងក្រៅកំពែង មានជួរគុម្ពឫស្សីជាច្រើនព័ទ្ធជុំវិញ បញ្ចេញពន្លឺពណ៌ខៀវស្រងាត់ គួរជាទីរីករាយចាប់ចិត្តយ៉ាងក្រៃលែង ព្រោះហេតុនោះ បានជាគេហៅថា វត្តវេឡុវ័ន ដរាបមក ៗ មួយយ៉ាងទៀត គេហៅឈ្មោះវត្តនេះវែងបន្តិចថា វេឡុវ័នកលន្ទកា. និវាបដ្ឋាន ប្រែថា ព្រៃឫស្សីជាទីដែលគេតែងឲ្យនូវចំណីដល់សត្វកង្ហែន ព្រោះមានរឿងតំណាលថា កាលពីដើម ព្រៃឫស្សីនេះ ជាសួនឧទ្យាន មានស្តេចមួយអង្គតែងយាងទៅក្រសាលក្នុងឧទ្យាននោះ ៗ ថ្ងៃមួយ ព្រះរាជាទ្រង់សោយសុរាស្រវឹង ផ្ទុំលក់ក្នុងវេលាថ្ងៃ ៗ ចំណែកខាងព្រះរាជបរិពារទាំងប៉ុន្មាន ដែលតាមហែហមព្រះអង្គទៅផងនោះ ដោយបានដឹងថាព្រះរាជាផ្ទុំលក់ហើយ ក៏នាំគ្នាចេញទៅដើរលេងកំសាន្តក្នុងទីខាងណេះខាងណោះអស់ទៅ ៗ គ្រានោះ មានពស់វែកមួយនៅក្នុងរន្ធឈើ ធុំក្លិនសុរា ហើយក៏លូនចេញតម្រង់មករកស្តេចដោយបំណងនឹងចឹក ប៉ុន្តែរុក្ខទេវតា បានឃើញពស់នោះ ហើយគិតថា អញនឹងជួយសង្គ្រោះឲ្យជីវិតដល់ស្តេចនេះចុះ ហើយក៏តំណែងខ្លួនជាសត្វកង្ហែនទៅស្រែកជិតព្រះកណ្ណានៃស្តេច ស្តេចក៏ទ្រង់តើនឡើង ឯពស់វែកនោះក៏លូនត្រឡប់ទៅវិញ ៗ ព្រះរាជាទតទៅឃើញដូច្នោះ ក៏ទ្រង់ព្រះតម្រិះថា សត្វកង្ហែននេះ មកស្រែកជួយសង្គ្រោះឲ្យជីវិតដល់អញ បើពុំអី អញមុខជាត្រូវស្លាប់ក្នុងទីនេះពុំខាន ដោយព្រះតម្រិះដូច្នេះហើយ

ក៏ទ្រង់តាំងផ្ដើមឲ្យគេឲ្យចំណីដល់ពួកសត្វក្ដែនក្នុងទីនោះផង ទ្រង់ឃោ-សនាបញ្ញត្តច្បាប់ឲ្យអភ័យដល់ពួកសត្វក្ដែនក្នុងទីនោះផង, ព្រោះហេតុនោះ ចាប់ដើមតាំងពីថ្ងៃនោះមក ទីព្រៃនោះឯង គេហៅថា វេឡុវ័ន-កលន្ទកនិវាបដ្ឋាន ដរាបមក ។

× × ×

## រាជគហសេដ្ឋីកសាងវិហារ

ក្នុងសម័យដែលព្រះសម្មាសម្ពុទ្ធ ទ្រង់គង់នៅវត្តវេឡុវ័នកលន្ទក-និវាបដ្ឋាន ជិតក្រុងរាជគ្រឹះ ។ សម័យនោះឯង ព្រះភគវ័ត មិនទាន់បាន អនុញ្ញាតសេនាសនៈដល់ពួកភិក្ខុនៅឡើយ ម៉្លោះហើយភិក្ខុទាំងឡាយនោះ ក៏នាំគ្នានៅក្នុងព្រៃខ្លះ នៅក្បែរគល់ឈើខ្លះ នៅលើភ្នំខ្លះ នៅក្នុងព្រៃស្មសានខ្លះ នៅក្នុងទីកណ្ដាលវាលខ្លះ នៅទីគំនរចំបើងខ្លះ ។ លុះដល់ពេលព្រឹកឡើង ភិក្ខុទាំងនោះ ក៏ដើរចេញអំពីទីនោះៗ សឹងមានចក្ខុសម្លឹងចុះ បរិបូណ៌ដោយឥរិយាបថស្រគត់ស្រគំរមទម្យគួរឲ្យកើតសេចក្ដីជ្រះថ្លា ។ គ្រានោះឯង រាជគហសេដ្ឋី ធ្វើដំណើរចេញពីផ្ទះទៅកាន់ឧទ្យានអំពីព្រលឹម បានឃើញភិក្ខុទាំងឡាយនោះ ក៏កើតមានសេចក្ដីជ្រះថ្លា នឹកគិតថា ភិក្ខុទាំងឡាយ មិនទាន់មានវិហារ (កុដិ) សម្រាប់គង់ស្រួលបួលនៅឡើយទេ បើដូច្នោះ គួរអាត្មាអញចូលសួរមើល បើលោកព្រមនៅ អាត្មាអញនឹងធ្វើវិហារប្រគេន ។ លំដាប់នោះ រាជគហសេដ្ឋី

ចូលទៅរកភិក្ខុទាំងឡាយ ហើយនិយាយនឹងភិក្ខុទាំងនោះថា បពិត្រលោកម្ចាស់ទាំងឡាយ ប្រសិនបើខ្ញុំព្រះករុណាឲ្យគេធ្វើវិហារប្រគេន តើលោកម្ចាស់ទាំងឡាយ នឹងគង់នៅក្នុងវិហាររបស់ខ្ញុំព្រះករុណាឬទេ? ភិក្ខុទាំងនោះឆ្លើយថា ម្នាលគហបតី ព្រះមានព្រះភាគ មិនទាន់បានអនុញ្ញាតវិហារដល់ភិក្ខុទាំងឡាយទេ ។ រាជគហសេដ្ឋីទូលថា បើដូច្នោះ សូមលោកម្ចាស់ទាំងឡាយ ក្រាបបង្គំទូលសួរព្រះមានព្រះភាគ អំពីរឿងវិហារនោះ បើបានការណ៍យ៉ាងណា សូមមេត្តាប្រាប់ដល់ខ្ញុំព្រះករុណាផង ។ ភិក្ខុទាំងនោះ ទទួលពាក្យរាជគហសេដ្ឋីហើយ ក៏នាំគ្នាចូលទៅក្រាបបង្គំគាល់ព្រះសម្មាសម្ពុទ្ធ ហើយទូលថា បពិត្រព្រះអង្គដ៏ចំរើន, រាជគហសេដ្ឋីមានបំណងនឹងឲ្យគេធ្វើវិហារដើម្បីយើងខ្ញុំទាំងឡាយ តើយើងខ្ញុំទាំងឡាយគប្បីប្រតិបត្តិដូចម្តេច? ។ ព្រោះនិទាននេះ ដំណើរនេះ ទើបព្រះភគវ័ត ទ្រង់ធ្វើធម្មីកថា ត្រាស់ហៅភិក្ខុទាំងឡាយមកជួបជុំ ហើយទ្រង់អនុញ្ញាតថា អនុជានាមិ ភិក្ខវេ បញ្ចលេណានិ វិហារំ អឌ្ឍយោគំ បាសាទំ ហម្មិយំ គុហំ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតសេនាសនៈ៥ យ៉ាងគឺ វិហារ ១ អឌ្ឍយោគ ១ ប្រាសាទ ១ ហម្មិយៈ ១ គុហា ១ ។

កាលបើព្រះមានព្រះភាគទ្រង់អនុញ្ញាតដូច្នេះហើយ ភិក្ខុទាំងឡាយនោះចូលទៅរករាជគហសេដ្ឋី ហើយនិយាយយ៉ាងនេះថា ម្នាលគហបតី

ឥឡូវនេះ ព្រះមានព្រះភាគទ្រង់អនុញ្ញាតវិហារហើយ បើអ្នកយល់ថាកាលណាគួរ ក៏គប្បីធ្វើចុះ ។ គ្រានោះ រាជគហសេដ្ឋី ចាត់ការឲ្យគេសាងវិហារបានចំនួន ៦០[១] តែមួយថ្ងៃក៏ហើយទាំងអស់ ។ លុះសាងវិហាររួចហើយ រាជគហសេដ្ឋី ក៏ចូលទៅគាល់ព្រះមានព្រះភាគ ក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចំរើន! សូមព្រះមានព្រះភាគ មួយអន្លើដោយភិក្ខុសង្ឃ ទទួលភត្តរបស់ខ្ញុំព្រះអង្គក្នុងវេលាថ្ងៃស្អែក ។ ព្រះមានព្រះភាគទ្រង់ទទួលនិមន្តដោយតុណ្ហីភាព ។ រាជគហសេដ្ឋី កាលបើបានដឹងច្បាស់ថា ព្រះមានព្រះភាគទ្រង់ទទួលនិមន្តហើយ ក៏ថ្វាយបង្គំលាព្រះមានព្រះភាគ ក្រោកចាកអាសនៈហើយចៀសចេញទៅ ។ គ្រាកាលកន្លងរាត្រីនោះទៅ រាជគហសេដ្ឋី ក៏ឲ្យគេតាក់តែងខាទនីយភោជនីយាហារដ៏ប្រណីតផ្ចិតផ្ចង់រួចហើយ ឲ្យគេទៅក្រាបបង្គំទូលភត្តកាល ចំពោះព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន! ភត្តកាលសម្រេចហើយ ។

ក្នុងវេលាបុព្វណ្ហសម័យ ព្រះមានព្រះភាគ ទ្រង់យាងទៅកាន់និវេសនដ្ឋាននៃរាជគហសេដ្ឋី លុះយាងទៅដល់ហើយ ទ្រង់គង់លើពុទ្ធាសនៈដែលគេតាក់តែងបំរុងទុក មួយអន្លើដោយភិក្ខុសង្ឃ ។ ឯរាជគហសេដ្ឋីបានអង្គាសខាទនីយភោជនីយាហារដ៏ឆ្ងាញ់ពិសា ដោយដៃខ្លួនឯង ថ្វាយចំពោះភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ឲ្យឆ្អែតស្កប់ស្កល់, លុះព្រះអង្គទ្រង់

១ វិហារទាំង ៦០ នោះ មានទំហំតូចៗ ធ្វើដោយគ្រឿងឈើប្រក់ស្លឹក សម្រាប់នៅមួយអង្គៗ ។

សោយហើយស្រេច លែងលូកព្រះហស្តទៅក្នុងបាត្រទៀតហើយ, ទើបរាជគហសេដ្ឋី ក្រាបបង្គំទូលពាក្យនេះនឹងព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គជាអ្នកត្រូវការដោយបុណ្យនិងបានសួគ៌ បានសាងវិហារចំនួន ៦០ នេះ រួចស្រេចអស់ហើយ, បពិត្រព្រះអង្គដ៏ចំរើន! ខ្ញុំព្រះអង្គនឹងគប្បីប្រតិបត្តិចំពោះវិហារទាំងនោះដូចម្តេច? ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលគហបតី! បើដូច្នោះ អ្នកចូលប្រតិស្ឋានវិហារទាំង ៦០ នោះ សំរាប់សង្ឃដែលមកហើយ និងមិនទាន់មក អំពីទិសទាំង ៤ ចុះ ។ រាជ-គហសេដ្ឋីទទួលស្តាប់ព្រះពុទ្ធដីកានៃព្រះមានព្រះភាគដោយពាក្យថា ព្រះករុណាព្រះអង្គ! រួចក៏ប្រតិស្ឋានវិហារទាំង ៦០ នោះ សម្រាប់សង្ឃដែលមកហើយនិងមិនទាន់មក អំពីទិសទាំង ៤ ។ ទើបព្រះមានព្រះភាគទ្រង់ធ្វើអនុមោទនា ចំពោះរាជគហសេដ្ឋី ដោយគាថាទាំងឡាយនេះថា :

សីតំ ឧណ្ហំ បដិហន្តិ តតោ វាឡមិគានិ ច
សរីសបេ ច មកសេ សិសិរេ ចាបិ វុដ្ឋិយោ
តតោ វាតាតបោ ឃោរោ សញ្ជាតោ បដិហញ្ញតិ
លេណត្ថញ្ច សុខត្ថញ្ច ឈាយិតុញ្ច វិបស្សិតុំ
វិហារទានំ សង្ឃស្ស អគ្គំ ពុទ្ធេហិ វណ្ណិតំ ។
តស្មា ហិ បណ្ឌិតោ បោសោ សម្បស្សំ អត្ថមត្តនោ
វិហារេ ការយេ រម្មេ វាសយេត្ថ ពហុស្សុតេ ។

តេសំ អន្នញ្ច បានញ្ច វត្ថសេនាសនានិ ច
ទទេយ្យ ឧជុភូតេសុ វិប្បសន្នេន ចេតសា
តេ តស្ស ធម្មំ ទេសេន្តិ សព្វទុក្ខាបនូទនំ
យំ សោ ធម្មំ ឥធញ្ញាយ បរិនិព្វាតិ អនាសវោ ។

( វិហារ គឺទីអាវាស ឬសេនាសនៈជាទីនៅនៃសង្ឃទាំងឡាយ ) រមែងការពារត្រជាក់ផង ក្តៅផង ម្រឹគសាហាវទាំងឡាយផង ពស់តូចនិងពស់ធំទាំងឡាយផង មូសទាំងឡាយផង ត្រជាក់ទាំងឡាយផង គ្រាប់ភ្លៀងទាំងឡាយផង ខ្យល់និងកម្តៅថ្ងៃដ៏ក្លាខ្លាំង ដែលកើតឡើងហើយ រមែងបាត់ទៅវិញ ព្រោះវិហារនោះ ៗ ។ វិហារទាន គឺការឲ្យទីលំនៅ ( ដែលបុគ្គលបានឲ្យហើយ ) ដល់សង្ឃ ដើម្បីជាទីជ្រកកោនផង ដើម្បីនៅជាសុខផង ដើម្បីផុតបាបធម៌ផង ដើម្បីចំរើនវិបស្សនាផង ព្រះពុទ្ធទាំងឡាយ តែងត្រាស់សរសើរថា ជាទានដ៏ប្រសើរ ។ ព្រោះហេតុនោះឯង បុរសស្ត្រីជាបណ្ឌិត កាលបើបានឃើញច្បាស់នូវប្រយោជន៍របស់ខ្លួន ក៏គួរកសាងវិហារ គឺអាវាស ឬសេនាសនៈទាំងឡាយ ដ៏ជាទីគួររីករាយ ហើយគួរនិមន្តលោកដែលជាពហុស្សូត គឺលោកអ្នកចេះដឹងច្រើនទាំងឡាយ ដែលមានចិត្តដ៏ត្រង់ ហើយប្រគេនបាយ ទឹក សំពត់ និងសេនាសនៈទាំងឡាយ ដល់លោកទាំងនោះចុះ ។ លោកទាំងនោះ រមែងសំដែងធម៌ជាគ្រឿងបន្ទោបង់

ឲ្យឃ្លាតចាកទុក្ខគ្រប់ប្រការដល់អ្នកនោះ លុះអ្នកនោះ បានដឹងធម៌ណា ក្នុងព្រះពុទ្ធសាសនានេះហើយ ក៏ជាអ្នកមិនមានអាសវៈ រមែងបរិនិព្វាន ។

កាលដែលព្រះសម្ពុទ្ធបរមគ្រូ ទ្រង់អនុមោទនាចំពោះរាជគហសេដ្ឋី ដោយគាថាទាំងឡាយនេះរួចហើយ ព្រះអង្គក៏ទ្រង់ក្រោកចាកអាសនៈ យាងចៀសចេញទៅ ។ គ្រាខាងក្រោយពីនោះមកទៀត មនុស្សទាំងឡាយ បានឮដំណឹងថា ព្រះសម្មាសម្ពុទ្ធទ្រង់អនុញ្ញាតវិហារសំរាប់ភិក្ខុសង្ឃហើយ ក៏នាំគ្នាយកចិត្តទុកដាក់កសាងវិហារ ក្នុងស្រុកនិគមជនបទនានា ។ ដើម្បីឧទ្ទិសចំពោះភិក្ខុសង្ឃ ក្នុងព្រះពុទ្ធសាសនាដរាបមក ។ សម័យនោះឯង ភិក្ខុទាំងឡាយ នៅក្នុងអារាមដែលពុំទាន់មានឧបដ្ឋានសាលានៅឡើយ នាំគ្នាឆាន់អាហារក្នុងទីវាល រមែងមានការលំបាកដោយត្រជាក់ខ្លះ ដោយកំដៅថ្ងៃខ្លះ ។ ភិក្ខុទាំងនោះក្រាបបង្គំទូលរឿងនោះ ចំពោះព្រះមានព្រះភាគ, ព្រះអង្គទ្រង់ត្រាស់ថា អនុជានាមិ ភិក្ខវេ ឧបដ្ឋានសាលំ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឧបដ្ឋានសាលា ( សាលាដែលពួកទាយកទាយិកាផ្គត់ផ្គង់ដោយអាហារភោជន បំរើភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ) ។ គ្រានោះ មនុស្សទាំងឡាយ អ្នកមានសទ្ធាជ្រះថ្លា ក៏នាំគ្នាកសាងឧបដ្ឋានសាលាឡើង សំរាប់បំរើភិក្ខុសង្ឃមានព្រះពុទ្ធជាប្រធាន ជាប់ជាប្រពៃណីរហូតមកដល់បច្ចុប្បន្នសម័យនេះ ។ល។ (នៅមានត)

# យោបល់ឯកឧត្តម យឹម-ទិត ផ្ញើជូនសហ. សម-ហ៊ាំង

ឯ ឧ. យឹម-ទិត បានយកលិខិតមួយរបស់លោកដែលផ្ញើទៅសហ. សម-ហ៊ាំង ដើម្បីថ្លែងយោបល់លោកព្រមទាំងមានចំណារអក្សរល្អិត របស់ព្រះសាសនមុនី កឹម-ទូ ភ្ជាប់ជាមួយផង។

*ភ្នំពេញ ថ្ងៃទី ១៦ មិថុនា ១៩៦៧*

*ជំរាបមកលោក សម ហ៊ាំង*

*សូមជ្រាប ។*

*ខ្ញុំបានទទួលសៀវភៅធម៌ ដែលជាស្នាព្រះហស្តសម្តេចក្រុមព្រះមុនីរេត ទ្រង់ព្រះរាជនិពន្ធជាភាសាបារាំង ហើយលោកជាអ្នកប្រែមកជាភាសាខ្មែរ ។ ខ្ញុំបានអានសៀវភៅនេះខ្លះហើយ ដោយមានចាប់អារម្មណ៍ជាច្រើន ដូចជាសម្តេចទ្រង់ព្រះតម្រិះថា ឲ្យអ្នកកាន់ព្រះពុទ្ធសាសនា ត្រិះរិះរកសេចក្តីពិតខ្លួនឯងផង ។ ត្រង់នេះជាការត្រូវពិតណាស់ ពីព្រោះខ្ញុំធ្លាប់បានអានសៀវភៅអ្នកនិពន្ធជាតិយើង បានរៀបរៀងអំពីព្រះពុទ្ធសាសនា គឺព្រះសូត្រក្តី ព្រះវិន័យក្តី ព្រះអភិធម្មក្តី ដោយដកស្រង់យកពីគម្ពីរ*

អហេតុកចិត្ត ក្នុងទីនេះប្រែថា ចិត្តគ្មានហេតុ ឧទាហរណ៍ ដូចបុគ្គលបើកភ្នែក ក្រឡេកទៅឃើញរូបអ្វីជាដំបូង នៅមិនទាន់មានវិតក្កៈវិចារៈ ដែលជាហេតុឲ្យកើតសោមនស្ស ទោមនស្ស ទៅលើរូបនោះនៅឡើយទេ ក្នុងខណៈនោះ ចិត្តនេះ ហៅ អហេតុកចិត្ត ព្រោះមិនទាន់ចាត់ជាចិត្តបុណ្យ ឬ បាបនៅឡើយ ។

ផ្សេងៗមានគម្ពីរទីឃនិកាយ អង្គុត្តរនិកាយជា
ដើម ខ្ញុំបានសំគាល់ឃើញ ក្នុងអត្ថបទ ទាំង
នោះ ដែលអ្នកនិពន្ធដកស្រង់ពីគម្ពីរមកហើយ
គ្មានអធិប្បាយអ្វីក្រៅ ជាសេចក្ដីយល់ឃើញ
របស់អ្នកនិពន្ធ គឺឃើញនៅត្រឹមត្រូវទាំងអស់
តែមានអ្នកនិពន្ធខ្លះបើមានសេចក្ដីយល់ឃើញ
ផ្ទាល់ខ្លួន ច្រើនតែមានទ័ន្តច្រឡំ ។ឧទាហរណ៍
ដូចអភិធម្មសំពីផ្សវចិត្ត មានអហេតុកចិត្តជា
ដើម ។ អហេតុកចិត្តនេះ ជាចិត្តមួយផ្នែក
ដែលមានសុទ្ធតែជាឧបេក្ខា គឺជាចិត្តដែលឥត
ហេតុ គឺហេតុទាំង ៦ មានលោភ ទោស
មោហ និង អលោភ អទោស អមោហ ។
ចិត្តនេះជាតួវិបាក គឺជាផលរបស់កម្មដែល
យើងបានធ្វើមកពីអតីតជាតិ ។ អ្នកនិពន្ធខ្លះ
ឲ្យមានឧទាហរណ៍ថា អហេតុកចិត្តនេះ ជា
ឧបេក្ខាបើធ្វើបុណ្យក៏បានតិច បើធ្វើបាបក៏
បានតិច ។ យល់នេះខុសទាំងស្រុង ។

ឆន្ទៈ (បំណង) បើបំណងកើតឡើងហើយ ត្រូវឲ្យមានវីរិយៈ (សេចក្ដីព្យាយាម, សេចក្ដីប្រឹងប្រែងឈានទៅមុខមិនឈប់) បើវីរិយៈកើតឡើង ត្រូវឲ្យមានចិត្តៈ (សេចក្ដីត្រិះរិះ, សតិ) បើចិត្តៈកើតឡើងហើយ ត្រូវឲ្យមានវិមំសា (ប្រាជ្ញា) ការយល់ឃើញហេតុការណ៍ទូលំទូលាយ, កិច្ចការអ្វីខាងផ្លូវលោកក្ដី គុណវិសេសខាងផ្លូវធម៌ មានឈានសមាបត្តិជាដើមក្ដី ដែលនឹងសម្រេចទៅបាន អាស្រ័យដោយឥទ្ធិបាទធម៌ទាំងអស់; សមដូចយោបល់ របស់ឯកឧត្តមដែលយល់នោះដែរ ។

មួយទៀត មានធម៌ខ្លះ ដូចជាឥទ្ធិបាទធម៌ ដែលព្រះពុទ្ធទ្រង់បានសម្ដែងមក ថាជាធម៌មានខ្លឹមសារ អាចជាធម៌ធ្វើឲ្យមានឫទ្ធិយ៉ាងខ្លាំង បើតាមខ្ញុំមើលទៅមានមនុស្សជាច្រើន ពុំទាន់យល់អស់អំពីអត្ថន័យនៃធម៌នេះទេ ។ យើងយល់ថា : ឥទ្ធិបាទ ដែលជាធម៌ សម្រាប់ប្រព្រឹត្តឲ្យបានខាងផ្លូវលោកុត្តរ ។ ឯធម៌នេះ ត្រូវតែយកមកអនុវត្តក្នុងផ្លូវលោកិយផង ។ ឧទាហរណ៍ ដូចចរិយាដែលមានចែកជាបីផ្នែក ក្នុងនេះ ខ្ញុំយកតែចរិយាសិក្សាមកអធិប្បាយ ។ ចរិយាសិក្សាត្រូវប្រកបទៅនឹងឥទ្ធិបាទ ទើបបានសម្រេចផលដ៏បរិបូណ៌ ។ ដូចលោកជ្រាបស្រាប់ហើយ ឥទ្ធិបាទមានអង្គបួនគឺ ឆន្ទៈ វិរិយៈ ចិត្តៈ និង វិមំសា ។ យើងធ្វើអ្វីក៏ដោយ បើគ្មានឆន្ទៈទេ មិនបានសម្រេចតាមបំណងឡើយ ។ បើមានឆន្ទៈហើយត្រូវឲ្យមានវិរិយៈជួយគាំទ្រផង ត្រង់ពាក្យវិរិយៈនេះ ដែល

ប្រែមកជាភាសាខ្មែរថា ប្រឹងប្រែង មិនពេញ
សព្វទេ គឺប្រឹងប្រែងប្រកបដោយថាមពល ។
ឧទាហរណ៍ដូចជាព្រះពុទ្ធ កាលទ្រង់ប្ដេជ្ញានៅ
ពេលដែលព្រះអង្គធ្វើសមាធិ ក្រោមដើម
និគ្រោធព្រឹក្សនៅពុទ្ធគយាថាៈ ប្រសិនបើមិន
បានត្រាស់ដឹងនៅពេលនេះទេ ព្រះអង្គមិន
រំសាយព្រះភ្នែនឡើយ ។ ឯវិមំសា វិញ ខ្ញុំគឺ
យល់ថាសព្វថ្ងៃនេះ យើងយល់ពាក្យនេះមិន
ច្បាស់លាស់ដែរ វិមំសា ប្រែមកជាខ្មែរថា
ពិនិត្យប្រឡង ពិសោធ យ៉ាងណាមិញ ដូច
និស្សិតដែលបានរៀនវិជ្ជាអ្វីមួយចប់ វិជ្ជានេះ
កាលណាគ្រូល្បងមើលតើសិស្សរបស់ខ្លួនចេះ
ចាំមេរៀននេះហើយឬនៅ "ឲ្យប្រឡង" ដូច
ជារឿងកុមារពេទ្យទៅរៀន នៅសាលាទិសា-
បាមោក្ខនគរតក្កសិលាគ្រប់ ៧ ឆ្នាំហើយ កុមារ
នេះបានទៅសួរគ្រូថា : ការរៀនរបស់ខ្ញុំ តើ
ចប់ហើយឬនៅ គ្រូតបថា បើចង់ដឹងដូច្នេះ
ត្រូវកុមារឯងយកចបមួយទៅជីកយកឬសឈើ

ដែលមានផ្ទះនៅជុំវិញក្រុងតក្កសិលា ហើយពិនិត្យពិសោធមើល តើមានឈើណាខ្លះដែលមិនមែនជាថ្នាំ ។ កុមារពេទ្យបានធ្វើតាមបញ្ជាគ្រូ ហើយក៏មកជំរាបគ្រូវិញថា ក្នុងចំណោមឈើ ដែលខ្ញុំបានពិនិត្យមើលហើយនេះ គ្មានឈើអ្វីដែលមិនមែនជាថ្នាំនោះទេ ។ គ្រូទីកក្នុងចិត្តថា កុមារពេទ្យរៀនបានចប់សព្វគ្រប់ហើយ ។ នេះហើយដែលហៅថាវិមំសា ។

មានឧទាហរណ៍មួយទៀតអំពីផ្លូវអភិធម្ម ខ្ញុំបានអានសៀវភៅ ដែលអ្នកនិពន្ធជាតិយើងបានថែងអំពីសមាធិ ។ ក្នុងសៀវភៅទាំងនោះ អ្នកនិពន្ធបានដកស្រង់ពីគម្ពីរព្រះអភិធម្ម មានសមាធិនិទ្ទេសជាដើម ក្នុងគម្ពីរវិសុទ្ធិមគ្គបានរៀបរាប់ពីសេចក្ដីដែលត្រូវធ្វើសមាធិនោះ ដូចម្ដេចខ្លះ តែមានខ្លះគោលធំបំផុតក្នុងពេលដែលព្រះអង្គបានបញ្ញត្តក្នុងសមាធិការទា គឺមហាសតិបដ្ឋានសូត្រ បើគ្មានសតិទេ តើធ្វើសមាធិកើតឬទេ ? ។

សតិជាគូនឹងសម្បជញ្ញៈ ហៅថា ពហុការធម៌ ធម៌មានឧបការច្រើន ។ បុគ្គលធ្វើការអ្វីក៏ដោយ ត្រូវតែមានសតិសម្បជញ្ញៈ គ្រប់ឥរិយាបថទាំងអស់ ទើបការដែលធ្វើនោះមិនខុសភ្លាត់, ចំណែកខាងការប្រតិបត្តិធម៌ ថ្នាក់ណាក៏ដោយ ត្រូវតែប្រើសតិសម្បជញ្ញៈ ឲ្យកើតមានគ្រប់វេលាទាំងអស់ ទើបសេចក្ដីប្រតិបត្តិនោះ ត្រង់ទៅរកសេចក្ដីពិតបាន បើគ្មានសតិសម្បជញ្ញៈ ក្នុងការដែលខ្លួនធ្វើនោះទេ ទុកជាខុស ប្រើការពុំបានឡើយ សមផ្ទួចឯកឧត្ដមយល់នោះដែរ ។

ការដែលខ្ញុំបានសាសព្ទទាំងប៉ុន្មាននេះ ជាសេចក្ដីយល់ឃើញផ្ទាល់ខ្លួនរបស់ខ្ញុំទេ ការយល់ឃើញនេះ ខ្ញុំមិនអាចអះអាងថា ខ្ញុំយល់ត្រូវឡើយ ប៉ុន្តែសុំឲ្យលោកដែលជាអ្នកប្រាជ្ញខាងពុទ្ធសាសនាពិនិត្យថែមទៀតចុះ ឬពិគ្រោះសួរទាំងអស់លោកណា ដែលស្ទាត់ជំនាញក្នុងព្រះពុទ្ធសាសនានេះទៀតផង ។

មុនទីបញ្ចប់ ខ្ញុំសូមអរគុណលោកដែលបានផ្ញើសៀវភៅ ដែលបានថែងរួចហើយមកឲ្យខ្ញុំ ហើយខ្ញុំសូមជូនមកលោកវិញនូវសៀវភៅមួយស្ដីអំពីព្រះពុទ្ធសាសនា ដែលខ្ញុំដាក់ឈ្មោះថា " ព្រះពុទ្ធសាសនាជាផ្លូវទៅកាន់សន្តិភាព „ និងអត្ថបទមួយទៀតដែលមានឈ្មោះថា "ប្រវត្តិប្រទេសខ្មែរ នៅបច្ចុប្បន្នមួយផ្នែក „ ។

សូមលោកទទួលនូវសេចក្ដីរាប់អាន
របស់ខ្ញុំដោយស្មោះបំពោះ ។

ឃឹម·ធិត

## ផ្នែកអក្សរសាស្ត្រ

អក្សរសាស្ត្រខ្មែរ ខ្មែរគួរថែថ្នម
ឲ្យបានខ្ជាប់ខ្ជួន គង់វង្សគង់មគ់
ព្រោះអក្សរជាតិ គោលជាតិប្រាកដ
អក្សររលត់ ជាតិក៏រលាយ

ប.ព.

# ពិចារណាដើម្បីយល់តក្កវិជ្ជា

(ត)

លោក ហ៊ុន គិមសៀ រៀបរៀង

## ប- ការទាក់ទងរវាងទស្សនិយម (Concept)

សត្វ, លោក, ធាតុភូត ( Phénomène ) ទាំងអស់ ដែលកើតមានឡើង សុទ្ធតែមានការទាក់ទងគ្នាទៅវិញទៅមក ។ ទស្សនៈរបស់មនុស្ស គឺជារូបញ្ចាំងសាកលលោកខាងក្រៅ ដែលឆ្លុះចូលទៅក្នុងខួរក្បាលមនុស្ស ដូច្នេះ ទស្សនៈក៏មានការទាក់ទងគ្នាដូច្នោះដែរ ។

រវាងទស្សនៈ វាមានការទាក់ទងគ្នាដល់ទៅ ៦ យ៉ាង បើអ្នកណាធ្លាប់រៀនតក្កវិជ្ជា គេអាចយល់ច្បាស់រឿងនេះ ។

១- ទាក់ទងស្មើគ្នា ( Rapport identique ) មានទស្សនៈមួយចំនួន បើយើងយកលក្ខណៈឯកឯង ( ផ្ទាល់ ) មកពិចារណា

យើងឃើញថា : ក៏មានកន្លែងខុសគ្នាច្រើន ប៉ុន្តែទស្សនៈនោះ គឺមានកម្រិតតែមួយទេ ។

ឧទាហរណ៍ : " រមគីន " និង " អ្នកនិពន្ធរឿងសុផាត " ខាងលើនេះ ជាទស្សនៈពីរ ប៉ុន្តែចង្អុលកម្រិតតែមួយ ។ លក្ខណៈឯកឯង ( ផ្ទាល់ ) នៃពាក្យ " រម - គីន " ក៏ខុសគ្នាពីពាក្យ " អ្នកនិពន្ធរឿងសុផាត " ប៉ុន្តែបើនិយាយអំពីមនុស្សវិញ គឺតែមួយ ប៉ុន្តែ ពាក្យថា " រម-គីន " ក៏ទូលាយជាងពាក្យថា : " អ្នកនិពន្ធរឿងសូផាត " ។ ដូច្នេះ ពីត្រឹមនេះទៅ យើងហៅថា "ទាក់ទងស្មើគ្នា" ដូចមានគំនូរខាងក្រោមនេះ ។

ក និង ខ មានតម្លៃ

ស្មើគ្នា




រូបទី ១

២- ទាក់ទងក្រោមបង្គាប់ (Rapport dépendent) ក្នុងករណីនេះ គឺការទាក់ទងរវាងទស្សនៈមួយដែលមានលក្ខណៈមិនសូវទូទៅ មិនសូវទូលាយនិងទស្សនៈមួយទៀតដែលមានលក្ខណៈទូទៅឬទូលាយជាង ។

ឧទាហរណ៍ : " ដើមឈើ " និង " ដើមស្វាយ " ។

ដើមស្វាយថា ឈើម្យ៉ាងនៅក្នុងពួកដើមឈើ ។ ដូច្នេះ ពាក្យថា « ដើមស្វាយក៏ចង្អៀតជាងពាក្យថា : «ដើមឈើ » ។




យើងឃើញមានលក្ខណៈ ដើមឈើ ក៏ទូលាយទូទៅ ជាងលក្ខណៈដើមស្វាយ ។

រូបទី ២

៣- ទាក់ទងសមមាត្រ Rappot égal ទាក់ទងសមមាត្រគឺជាការទាក់ទងរវាងទស្សនៈក្រោមបង្គាប់ដែលមានដំពូកតែមួយដូចគ្នាទាំងអស់ ។

ឧទាហរណ៍ : ទស្សនៈ « ផ្លែ » ( ក ) គឺទស្សនៈជំពូកមួយ ដែលរួមមានប្រភេទផ្លែស្វាយ ( ខ ) ប្រភេទផ្លែ « ខ្នុរ » (គ) ផ្លែ « ល្មុត » ( ឃ ) ។

ទស្សនៈ ៣ ខាងក្រោមនេះ គឺ : ស្វាយ, ខ្នុរ, ល្មុត មានតម្លៃស្មើគ្នាទាំងអស់ ។




«ក» (ផ្លែ) ចង្អុលទស្សនៈ ចំពូក ។ រង្វង់តូចៗ ៣ ទៀត គឺ ខ គ ឃ ចង្អុលទស្សនៈប្រភេទ ដែលមានតម្លៃស្មើគ្នាទាំងអស់ ។

៤- ពាក់ទងជាន់លើគ្នា ពាក់ទងជាន់គ្នាបានសេចក្តីថា : ទស្សនៈពីរដែលមានលក្ខណៈទូទៅ ប៉ះគ្នាឬជាជាន់លើគ្នាក៏បាន ។

ឧទាហរណ៍ : យុវជននិងសាស្ត្រាចារ្យ ។ មានយុវជនខ្លះ ធ្វើជាសាស្ត្រាចារ្យ មានសាស្ត្រាចារ្យខ្លះធ្វើជាយុវជន ។ ឧទាហរណ៍ ដូចជា ពលរដ្ឋកំពេញ ខ្លះជាកម្មករ ។ កម្មករ នៅកំពេញ ជាពលរដ្ឋ ។




វាមានលក្ខណៈទូទៅ ជាន់លើគ្នា ។

រូបទី ៤

៥– ពាក់ទងប្រឆាំងគ្នា : គឺជា ការពាក់ទងម្យ៉ាងដែលមានលក្ខណៈឯកជន ( Carractère privé ) ខុសគ្នា ប៉ុន្តែ ទស្សនៈនោះ នៅគង់លក្ខណៈទូទៅដូចគ្នា ។

ឧទាហរណ៍ : " ក្រហម ,, និង " ខៀវ ,, ។ " ក្រហម ,, វាជាពណ៌មួយខុសពីពណ៌ " ខៀវ ,, ប៉ុន្តែ ទាំងពីរនេះ វានៅគង់លក្ខណៈទូទៅមួយគឺ " ពណ៌ " ។

ឧទាហរណ៍ : " កុសល ,, និង ,, អកុសល " ពិតមែន តែពាក្យទាំងពីរនេះ មានលក្ខណៈឯកឯងខុសគ្នា ប៉ុន្តែក៏មានលក្ខណៈទូទៅដូចគ្នាគឺ : កុសលក៏ជាមេរៀន; អកុសលក៏ជាមេរៀន ។

ខ្មៅ និង ស មានលក្ខណៈ ឯកឯងខុសគ្នា ប៉ុន្តែ មានលក្ខណៈទូទៅ ដូចគ្នា គឺពណ៌




រូបទី ៥

៦— ទាក់ទងផ្ទុយគ្នា (Rapport contradictoire) គឺជាការទាក់ទងម្យ៉ាងដែលមានទស្សនៈពីរ ហើយទស្សនៈនីមួយ ៗ ក៏ផ្ទុយគ្នា ប៉ុន្តែជាពិសេស លក្ខណៈឯកឯង នៃទស្សនៈទី ២ ក៏មិនលេចចេញមកឲ្យច្បាស់ទេ ។

ឧទាហរណ៍ : " ខ្មែរ ,, និង ,, មិនមែនខ្មែរ ,, ។ ពាក្យថា " មិនមែនខ្មែរ ,, ក៏ផ្ទុយនឹងពាក្យថា " ខ្មែរ " ប៉ុន្តែក៏មិនបញ្ជាក់ឲ្យច្បាស់ថា តើយួន ឬ ចិន ឬ អ្វី ?

ឧទាហរណ៍: " ស " និង " មិនមែនស " ។ ( ប៉ុន្តែ

កុំច្រឡំនឹងករណី "ស្រី" និង "មិនមែនស្រី" ពីព្រោះមនុស្សយើងមាន តែប្រុសនឹងស្រី ។ ចំណែកឯខ្ទើយយើងមិននិយាយដល់ )

ឧទាហរណ៍ : « ឆ្កែ » និង "មិនមែនឆ្កែ" ។




សូមមិត្តអ្នកអាន ពិចារណាជំពូក "ការទាក់ទងនេះ" ឲ្យច្បាស់ លាស់ ពីព្រោះប្រការនេះសំខាន់ណាស់ ក្នុងការបង្រៀលសំដី លេងពាក្យ ក្នុងសង្គ្រាមសំដី ឬ សង្គ្រាមប៉ាកកា ។ (នៅមានត)

អន្វេក្សណា នបុំ. កិរិយាត្រួតត្រា ។

អន្វេក្សា ស្ត្រី. កិរិយាពិចារណា ។ -អន្វេក្សិត គុ. ដែលត្រួតត្រាមើល។

អន្វឞ្ដកា ស្ត្រី. ថ្ងៃតពីអឞ្ដកា ។

អន្វហ៍ ធាតុ. ហៅបន្ទាប់, ហៅតាមលំដាប់ ។

អន្វាក្រម៍ ធាតុ. ដើរមើលតាមក្រោយ ។

អន្វាគម៍ ធាតុ ទៅតាមក្រោយ, ជូន ។ -អន្វាគត គុ. ដែលទៅតាម, ដែលជូន ។

អន្វាបរ៍ ធាតុ. ធ្វើត្រាប់ ។

អន្វាទ្រុ ធាតុ ដេញតាម, រត់តាម ។

អន្វាធា ធាតុ ដាក់បន្ថែម, បន្ថែមខុស ។

អន្វាធេយ នបុំ. អន្វាធេយ, ទ្រព្យគឺស្ត្រីរៀបការហើយ បានទទួលពីត្រកូលស្វាមី ។

អន្វាគិ ធាតុ. នាំទៅ ។

អន្វាយត្ត គុ. ដែលចងជាមួយ, ដែលអាស្រ័យដោយ, ដែលពឹងផ្អែក ។

អន្វារភ៑ ធាតុ. ប្រារព្ធតាម ។

អន្វារុហ៑ ធាតុ. ឡើងតាម, វាយលុកតាមដំណើម ។

អន្វាលភ៑ ធាតុ. បានស្រេច, បានដល់ដៃ ។

អន្វាលម្ភន នបុំ. ក្ដាប់, មួយចិប ។

អន្វាវិធ៑ ធាតុ. កាន់កាប់, ប្រតិបត្តិតាម ។

អន្វាវ្ឫត៑ ធាតុ. ដេញតាម ។

អន្វាឝ្រិត គុ. ដែលអាស្រ័យតាម ។

អន្វាស ធាតុ. អង្គុយជិត, រស់នៅជិត, គោរព ។

អន្វាសន នបុំ. កិរិយាបំរើ ។

អន្វាហាយ៌ នបុំ. អន្វាហាយ៌, ភោជនដែលឧទ្ទិសចំពោះអ្នកស្លាប់, មតកភត្ត ។

—បចន បុំ ភ្លើងវេទីទិសខាងត្បូងដើម្បីអន្វាហាយ៌ ។

អន្វិ ធាតុ. ទៅតាម, ដើរតាម, ស្វែងរក, ដល់គោលបំណង, ជេះ ។ -អន្វិត គុ. ដែលទៅតាម, ដែលហែហម, ដែលប្រកប, ដែលធ្វើគ្រាប់ ។ អន្វីត ដូចគ្នា ។

អន្វិឞ ធាតុ. ប្រាជ្ញា, ស្វែងរក, ដេញតាម ។ -អន្វិឞ្ដ គុ. ដែលស្វែងរក ។

អន្វីក្ស ធាតុ. ក្រឡេកមើល ។

អន្វីក្សក គុ. ដែលបារម្ភ ។

អន្វីក្សា ស្ត្រី. កិរិយារមិលមើល, កិរិយាសង្ស័យ, ការបារម្ភ ។

អន្វេឞ បុំ. កិរិយាស្វែងរក, កិរិយាស្វែងរកម៉ឺងម៉ាត់ ។

អន្វេឞក គុ. អ្នករកម៉ឺងម៉ាត់ ។ -អន្វេឞិន គុ. អន្វេឞ្ឋូ ការក. អ្នកស្វែងរកកិត ។

អន្វេឞន បុំ., អន្វេឞនា ស្ត្រី. កិរិយាស្វែងរក ។

អប ស្ត្រី ពហុ. (អាបស៑ អបស អទ្ភិស...) ទឹក, ព្រះអាបោ ។

–ចរ បុំ. សត្វទឹក ។ –បតិ ព្រះវរុណ ។ –អគ្និ
គុ. ភ្លើងក្រោមសមុទ្រ ។ –ជ គុ. ដែលកើតក្នុងទឹក ។
បុំ. ឈូក, ព្រះព្រហ្ម ។ –ជនាភ បុំ. ព្រះវិស្ណុ ។ –ជក្យ
បុំ. ព្រះព្រហ្ម ។ –ជសម្ភវ បុំ. ព្រះព្រហ្ម ។ –ជុនី
ស្រី. ដើមឈូក ។ –ជិនីបតិ បុំ. ព្រះអាទិត្យ ។
–ទុគ៌ គុ ដែលទៅមិនបានព្រោះទឹក ។ –ធិ បុំ.
ទីតម្កល់ទឹក, សមុទ្រ ។ –ធិកន្យា ស្រ្តី. នាងលក្ស្មី ។
–ធិជីវិន បុំ អ្នកនេសាទ, ប្រមង់ ។ –ធិតនយ
បុំ. វត្ថុដែលត្រូវបាន ។ –អង្វិន ទាំងពីរ ។ –ពិន្ទុ
បុំ. ដំណក់ទឹក ។ –ភវ ឬ ភូ បុំ. ព្រះព្រហ្ម ។
–អញាម –តរតម បុំ. នាមអ្នកសិទ្ធ ។

អប បុព្វបទ, សេចក្ដីថា តិក, តត, ចោកថយ ។

អប មកពី អប ។

(នៅមានត)

# រឿងសាមកុក

ចាកញ៉ាវិបុលរាជសេនា

ឆ្វ · ភាគ ៨

ប្រែ·រៀបរៀង

( ក )

> រឿងសាមកុកទុកជាយុទ្ធសាស្ត្រ  អ្នកវាងវៃឆ្លាតបើបានអាន
> នឹងចេះឧបាយកលចំណាន  ទាំងមានសន្តានស្នេហាជាតិ
>
> —— យូរ—អ៊ិន ——

## សាមកុក ខ្សែ ៦៤

តាំងពីចូភីលើកខ្លួនជាព្រះចៅវុយអង ដំរួសចូធ្លូជាបិតា ហៃហ្យិទុនឈឺស្លាប់រហូតទៅ ដល់ហាមកៀងនិងទៀវគាត់លបកាត់ក្បាលទៀវហ៊ុយស្លាប់នាំរត់ទៅស្រុកកាំងតាំង ។

ឯចូភីនោះ លុះបានឡើងយសជាស្តេចសម្រេចរាជការហើយ ក៏តាំងខ្លួនជាព្រះចៅវុយអង់ជំនួសបិតា បើករង្វាន់បំណាច់ឲ្យខុនរាជការទាំងឡាយតាមគុណានុរូបនិងបណ្ដាស័ក្តិ ហើយឲ្យកេណ្ឌទាហានបាន ៣០ ម៉ឺន លើកចេញអំពីទីក្រុងតម្រង់ទៅស្រុកចៀវគួនក្នុងដែនខែត្រផៃកុក ដែលធ្លាប់នៅពីដើមនោះ ប្រយោជន៍នឹងក្រសាលឲ្យសប្បាយផង លុះលើកទៅដល់ស្រុកផៃកុក ក៏សំដែងយសដ៏ខ្ពង់ខ្ពស់អស្ចារ្យ ។

អស់បណ្ដាអ្នកស្រុកទាំងពួង ក៏មកប្រជុំគាល់ដោយសេចក្ដីត្រេកអរសាទរសប្បាយណាស់ ខ្លះក៏តែងគ្រឿងបណ្ណាការមកថ្វាយដោយច្រើន ក្នុងខណៈនោះ មានមនុស្សបំរើស៊ើបការនាំអាថ៌សេចក្ដីទៅក្រាបទូលព្រះ

ទៅវ៉ុយអង់ថា ហៃហ្គិទុនមានជម្ងឺឈឺធ្ងន់ណាស់ មើលទៅឃើញច្បាស់ថាជម្ងឺនោះ គង់នឹងស្លាប់ជាប្រាកដ វ៉ុយអង់ឮដូច្នោះក៏ស្លុតព្រះទ័យដោយសេចក្ដីអាល័យកប់ការ ស្ដាយហៃហ្គិទុនណាស់ ក៏លើកទ័ពត្រឡប់វិលមកវិញ លុះមកដល់ស្រុកនៀបកុនវេលាណា ហៃហ្គិទុន ក៏ធ្វើកាលកិរិយា វ៉ុយអង់ក៏តាក់តែងរៀបសំស្ការសពតាមទំលាប់ប្រវេណី ទីនាយទាហានឯក ហើយហៃទៅបញ្ចុះទុកតាមធម្មតា ។

កាលចូគីឡើងជាទីវ៉ុយអង់ជួសបិតាជាអម្ចាស់មកប្រហែល ៦ ឆ្នាំ ក្នុងខែកគ្រប់ខ មានហង្សហើរទៅស្រែកយំនៅត្រង់ស្រុកសេងសឹក ហើយនិងមាននកផសីហ៍ ចូលមកដើរត្រេច ក្នុងស្រុកលិមតោ រួចត្រឡប់បាត់ទៅវិញ មហាជនទាំងឡាយក៏នាំយកហេតុនោះទៅទូលវ៉ុយអង់ រួចអំពីនោះ មានមករពណ៌លឿង មានសក្ដានុភាពណាស់ មកសំដែងឫទ្ធិអណ្ដែតនៅលើអាកាសជាអស្ចារ្យធំ មហាជនទាំងពួងក៏ក្រឡេកឃើញចូក ក៏ឃើញច្បាស់ទាំងអស់គ្នា ។

វ៉ុយអង់ឃើញហេតុទាំង ៣ ប្រការដូច្នេះ ជាអស្ចារ្យណាស់ ទើបឲ្យហៅលីគុក ខៅជី ដែលជាមន្ត្រីធំ ហើយជាចាស់ទុំជាងគេ នូវអស់នាម៉ឺនឯទៀតមកប្រជុំប្រឹក្សាហើយត្រាស់សួរថា ៖ អាកេតទាំង ៣ ប្រការនេះ ឃើញចំឡែកអស្ចារ្យនៅក្នុងស្រុកយើង តើនឹងល្អឬអាក្រក់យ៉ាងណា ។ លីគុកនិងខៅជី ក្រាបទូលថា ៖ កើតអស្ចារ្យប្រាកដក្នុងស្រុកយើង

ដូច្នេះជាមង្គលប្រសើរណាស់ គឺនឹងឲ្យចំរើនសួស្ដីមង្គលដល់ទ្រង់នឹងឲ្យបានគង់ព្រះកិត្តិយសជាទីរុយអង មិនតែប៉ុណ្ណោះក៏ទេ ក្នុងបច្ចុប្បន្នជាតិនេះ បុណ្យនឹងចំរើនឲ្យលឿនទៅឡើងទៀត គឺទ្រង់នឹងបានសោយរាជសម្បត្តិជាមហាក្សត្រិយ៍គ្រប់គ្រងផែនដីនេះ ទើបបណ្ដាលចៃដឲ្យចិត្តនៃមហាជនទាំងប្រុសស្រីឲ្យមានសេចក្ដីស្នេហាស្រឡាញ់ ព្រះបរមពោធិសម្ភារបារមី ចង់ឲ្យទ្រង់ឡើងជាម្ចាស់ផែនដីតទៅ ។

ខណៈនោះអស់នាម៉ឺនមុខមន្ត្រីធំតូចក៏ប្រឹក្សាយល់ព្រមគ្នាថា យើងត្រូវក្រាបទូលព្រះចៅហៀនគេ សុំឲ្យប្រគល់រាជសម្បត្តិថ្វាយមកព្រះចៅចូគី លុះប្រឹក្សាយល់ព្រម ទើបចាត់ឲ្យហ៊ូហ៊ឹម អងឡង់ ស៊ុនលៀក ការសៀង តាត់កៀវ តាន់កុន គេងកៃ នូវអស់មន្ត្រីធំ ៗ ហើយនិងនាយទាហានប្រមាណ ៤០ នាក់ នាំគ្នាចូលទៅក្រុងហ៊ូគោ ហើយក៏ចូលទៅគាល់ព្រះចៅហៀនគេ ។ ហ៊ូហ៊ឹមទូលថា ៖ ចូគីជាទីរុយអងធំនួសបួផូនោះ មានបុណ្យសម្ភារបារមីច្រើនណាស់ មានទាំងសតិបញ្ញាជ្រៅជ្រះឆ្លាសវៃ មានព្រះទ័យអាណិតអាណាប្រជានុរាស្ត្រ ទូទាំងផែនដី រាស្ត្រទាំងប្រុសស្រី ក៏បានសេចក្ដីសុខក្សេមក្សាន្ត ។ មុខមន្ត្រីទាំងប៉ុន្មានក៏ប្រឹក្សាយល់ព្រមគ្នាទាំងនាយទាហាននិងរាស្ត្រប្រជា ឃើញថា វេលានេះជាឱកាសដ៏សមគួរ ដែលនឹងឧបត្ថម្ភទំនុកបំរុងផែនដី បានចំរើនតទៅ សូមព្រះអង្គទ្រង់ប្រគល់នូវរាជសម្បត្តិខត្តិយរាជឲ្យចូគីពេញ

ទីជាព្រះមហាក្សត្រិយ៍ចុះ ព្រះអង្គក៏នឹងបានគង់ជាសុខក្សេមក្សាន្តយឺនយូរតទៅ ។

ព្រះចៅហៀនគេ ទ្រង់ព្រះសណ្តាប់សព្វគ្រប់ ក៏ឲ្យស្មុគរទ្ធត់ក្នុងព្រះទ័យស្ងៀមនៅមួយស្របក់ ហើយក្រឡេកមើលមុខនាម៉ឺនទាំងពួង ក៏ទ្រង់ព្រះកន្សែងសោកាត្រាស់ថា យើងនឹកគិតអាណិតទៅដល់បុរាណក្សត្រិយ៍ មានព្រះចៅហាន់កោចោជាដើម ព្រះបរមវង្សផងយើងពេកណាស់ អំណើះតមកក៏មានព្រះរាជវង្សអង្គក្សត្រិយ៍ បានសោយរាជសម្បត្តិជាលំដាប់គ្នាជាយូរប្រមាណ ៤០០ - ៥០០ ឆ្នាំមកហើយ ជាទីបំផុតត្រឹមអង្គយើង ។ នេះនៅក្មេងសេចក្តីគិតម្រិះប្រាជ្ញាក៏មែន តែថាបានទទួលរាជសម្បត្តិផ្ទាល់ពីព្រះវររាជបិតា ដោយសារសេនាបតីនាម៉ឺនសព្វមុខមន្ត្រីជំនុំយល់ព្រម យើងក៏បានអនុលោមទទួលរក្សារាជសម្បត្តិដោយសត្យានុធម៌តរៀងមកដល់សម័យនេះ យើងក៏មិនមានប្រព្រឹត្តឲ្យខុសខាសពីសណ្តាប់ធ្នាប់បុរាណរាជប្រវេណីឯណាឡើយ ម្តេចហើយអស់អ្នកទាំងឡាយ មកនិយាយឲ្យយើងលើកយករាជសម្បត្តិរបស់យើងឲ្យទៅអ្នកដទៃវិញដូច្នោះ យើងពិតទៅឃើញខុសអំពីយុត្តិធម៌ច្បាប់ សុំឲ្យអស់អ្នកក្រឡាប់វិលទៅប្រឹក្សាគ្នាម្តងទៀតសិនចុះ ។

ហ្លួហ៊ុម ពួដូច្នោះក៏ចេញទៅ នាំយក លីតុក ខៅជី ជានាម៉ឺនចាស់ទុំចូលទៅគាល់ព្រះចៅហៀនគេហើយទូលថា ៖ ព្រះអង្គ ចូរទ្រង់ប្រឹក្សាពីគ្រោះនឹងអ្នកចាស់ទុំ ២ នាក់នេះចុះ តោះបីគួរពុំគួរប្រការម្តេច ក៏

ល្ហមទ្រង់ទឹងជឿស្តាប់បាន លីតុកក៏ទូលថា តាំងពីចូរីឡើងទីជាំ
រុំយអង ជំនួសបិតាវៀងមក ទូលបង្គំបានឃើញស្រុកទេសក៏រាបទាប
សប្បាយ បណ្តាពស្ត្រទាំងឡាយក៏បានសេចក្តីសុខក្សេមក្សាន្តគ្រប់គ្នា
បំណើអាហារក៏កើតឡើងបរិបូណ៌ គ្មានខ្វះកន្ទះអ៊ូសោះ មានហង្សសត្វ
ដែលរូបល្អស្រស់ក៏ហើរចូលមកក្នុងស្រុក រាជសីហ៍ក៏ចូលមកដើរតក្រុក
សត្វទីកន្ទ្រង់ខែត្រខណ្ឌពន្ធសីមា ស្តេចមករដែលមានរង្វង្កា ក៏អណ្តែត
ត្រសែតមកនៅលើអាកាស សំដែងរិទ្ធិទេភាសរុងរឿងកណ្តាលស្រុក
ទេស អាភេទទាំង ៣ ប្រការនេះ ជាទីអស្ចារ្យថ្លៃណាស់ ទូល
បង្គំយល់ច្បាស់ថា ចូរីទឹងមានបុណ្យកុសល គួរដល់ទូរពជសម្បត្តិ
ជាព្រះមហាក្សត្រិយ៍តទៅ ពោធិ៍ទូលថា ពេលកណ្តាលយប់ស្ងាត់
ទូលបង្គំបានឃើញផ្កាយនក្ខត្តឫក្សអន្សាស្រុក ដែលប្រចាំបុណ្យរបស់ព្រះ
អង្គ មានរស្មីសៅហ្មងវិប្បវត្តខុសអំពីធម្មតា សំដែងអាការឲ្យឃើញ
ថា ព្រះអង្គទឹងអស់បុណ្យក្នុងជាន់នេះហើយ ឯផ្កាយដែលប្រចាំបុណ្យ
ចូរីនោះ មានដួងធំអស្ចារ្យ រស្មីភ្លឺថ្លាបរិសុទ្ធណាស់ សំដែងហេតុ
ឲ្យឃើញច្បាស់ថា ចូរីទឹងមានបុណ្យបារមីថ្លៃថ្លា ទាំងមនុស្សនិង
ទេវតា ក៏និយមសរសើរពប់អានចូរីណាស់ បានជាបណ្តាលឲ្យ
ឃើញអាភេទច្បាស់ទាំង ៣ ប្រការ ជាទីប្រាកដដល់ភ្នែកអ្នកទាំងពួង
ហេតុនេះ សមគួរឲ្យព្រះអង្គទ្រង់លើកពជសម្បត្តិឲ្យ ចូរីគ្រប់គ្រងជា
ម្ចាស់ផែនដីតទៅចុះ ។

ព្រះចៅហៀនគេត្រាស់តបថា ដែលអស់អ្នកមកនិយាយដូច្នេះជាការមិនសមគួរនឹងជឿទេ ព្រោះមិនបានឃើញចំពោះនឹងភ្នែកយ៉ាងណា ហើយនៅកំណត់ក្នុងចិត្តថា មិនគួរនឹងឲ្យលើកកជសម្បត្តិ ដែលជាព្រះកេរ្តិ៍របស់ព្រះបរមក្សត្រិយ៍អំពីបុរាណឲ្យទៅអ្នកដទៃសោះ អង្គឡុងទូលថា ការទាំងនេះជាប្រវេណីមានមកអំពីបុរាណ មានល្អហើយក៏គង់ត្រឡប់ទៅជាអាក្រក់ ។ មានហើយក៏គង់នឹងត្រឡប់ទៅជាល្អវិញបាន យ៉ាងដូចប្រទេសស្រុកនីមួយ ៗ ធ្លាប់គង់នៅមាំមួនបរិបូណ៌ហើយ ក៏កើតជាសឹកសង្គ្រាមជ័យ ឲ្យវិនាសខ្ទេចខ្ទីអស់ទៅ លុះខ្ទេចខ្ទីទៅហើយក៏ត្រឡប់បានចំរើនមាំមួនឡើងជាធម្មតា ឯសម្បត្តិទ្រព្យសព្វសារពើទកជី ដែលព្រះអង្គទ្រង់ទទួលអំពីព្រះបរមរាជវង្ស ច្រើនផែនដីមកហើយ ប្រមាណ ៤០០ ឬ ៥០០ ឆ្នាំនោះ ទូលបង្គំយល់ឃើញថា វង្សរបស់ព្រះអង្គនឹងត្រូវផុតរលត់ក្នុងសម័យនេះជាពិត ហេតុនេះសុំឲ្យព្រះអង្គពិនិត្យលះបង់កជសម្បត្តិនោះប្រគល់ឲ្យបូកិចុះ បើព្រះអង្គនៅតែរឹងទទឹងដូច្នោះ មុខជានឹងមានសេចក្តីភ័យអន្តរាយមកដល់ព្រះអង្គពុំបាន ។

ព្រះចៅហៀនគេ បានទ្រង់ព្រះសណ្តាប់សព្វគ្រប់ប្រការ ក៏អាក់អួលព្រះទ័យទ្រង់ព្រះកន្សែងពិលាប ហើយក៏យាងចូលទៅក្នុងក្រឡាព្រះបន្ទំ អស់មន្ត្រីតូចធំក៏នាំគ្នាសោកទ្រហ៊ោអឺងកង រួចនាំគ្នាដើរចេញត្រសងមកព្រះរាជវាំង លុះព្រឹកឡើង អស់នាម៉ឺនទាំងនោះ ក៏នាំគ្នាចូលទៅគាល់

នៅទីព្រះរាជវាំងម្ដងទៀត ហើយបើពួកខ្ញុំឲ្យចូលទៅ អញ្ជើញស្ដេចឲ្យយាងចេញមក ព្រះចៅហៀនៈគក៏ទ្រង់ទឹងខ្លាចមិនអាចចេញមកសោះ នោះនាងចូហៅដែលជាប្អូនចូគី ជាទីព្រះអគ្គមហេសីមានសេចក្ដីធ្វល់ក៏ក្រាបទូលសួរថា អស់មុខមន្ត្រីឲ្យបំរើចូលមកអញ្ជើញស្ដេចចេញទៅក្រៅ ហេតុអ្វីព្រះអង្គមិនទ្រង់ចេញទៅដូច្នោះ ព្រះចៅហៀនគេក៏តែតែទ្រង់ព្រះកន្សែងសោក ហើយមានព្រះរាជទង្គារត្រាស់ប្រាប់ព្រះមហេសីតាមសេចក្ដីដែលបង្កើតឡើងថា បងប្រុសរបស់ប្អូនឯងឲ្យបំរើមកកំហែងបង ប៉ងនឹងដណ្ដើមយករាជសម្បត្តិ បានជាពួកនាម៉ឺនទាំងនេះគិតគប់គ្នានឹងកំចាត់យើង ឲ្យយើងលើកស្វេតច្ឆត្រប្រគល់ឲ្យចូគីដោយបង្ខំ ហេតុនេះបានជាបងនៅសម្ងំមិនចេញទៅ ។

ព្រះនាងចូហៅបានឮដូច្នោះ ក៏ខឹងខ្លាំងណាស់ថា បងខ្ញុំម្ចាស់ហេតុម្ដេចបានជាមកគិតក្បត់ដូច្នោះ ព្រះនាងថាមិនទាន់ផុតពីមាត់ ស្រាប់តែចូហាង និង ចូហ៊ុំ សៀតក្រឹបចូលទៅទូលអញ្ជើញស្ដេចឲ្យចេញទៅ ព្រះនាងចូហៅក៏ស្រែកជេរថា អាពួកក្បត់ទាំងអស់នេះវាមានស័ក្ដិយសពីព្រោះនរណា ឥឡូវហេតុម្ដេចវានាំគ្នាមកធ្វើជាសត្រូវក្បត់គិតប្រទុស្ត-រ៉ាយនឹងម្ចាស់ផែនដីវិញ កាលគ្រាបិតាអញនៅរស់ក៏បានធ្វើសេចក្ដីគាប់ប្រសើរ ទុកឈ្មោះគ្មាននរណាស្មើបាន ហើយបានរៀបចំស្រុកទេសទាំងប៉ុន្មានឲ្យរាបទាបស្រួលបួលទាំងអស់ បណ្ដារាស្ត្រក៏ស្ម័គ្រស្មោះនិយម

កប់កានស្រឡាញ់ពេញទាំងផែនដី អស់ទាំងនាម៉ឺនមុខមន្ត្រីធំតូចក៏កោត ក្រែងអំណាចខ្លាចគ្រប់គ្នា ម្តេចបិតាអញមិនមានចិត្តគិតពុះពារទំនងដណ្តើម យករាជសម្បត្តិម្ចាស់ផែនដី ឥឡូវហេតុអ្វីបងអញដែលបានស្តីការជំនួស បិតាប៉ុណ្ណោះ មកបែរប្រែចិត្តគិតប្រទុស្តហ៊ើយទំនងដណ្តើមយករាជសម្បត្តិ ដូច្នេះ មនុស្សយ៉ាងនេះមិនមានចំរើនប៉ុន្មាន ទេពតាសព្វឋានក៏មិនជួយ ឲ្យពរសព្ទសាធុការទេ ថាហើយក៏ខ្ញួញយំដំ១ពត្រឡប់យាត្រាចូលទៅក្នុង វិញ អស់បណ្តាស្រីស្នំក្រមការ ដែលនៅក្នុងវាំងនោះមិញ ក៏ស៊ីង ជាទុក្ខទោមនស្សខ្ញួញយំទាំងអស់គ្នាទ្រហឹងអឹងកង ។

ឯចូហ៊ុវទិងចូហាង ក៏បង្ខំព្រះចៅហៀនតេ ស្តេចចេញទៅទីព្រះរាជ រោងរម្យជួបជុំនាម៉ឺនមុខមន្ត្រីទាំងពួង ព្រះចៅហៀនតេទទឹងពុំបាន ក៏ ដោះព្រះសុក័តយ៉ាងខ្ពស់មានរូបមករដែលធ្លាប់ទ្រង់ចេញប្រជុំមុខមន្ត្រីនោះ ចេញពីព្រះអង្គហើយក៏ទ្រង់ជូនព្រះអង្គយ៉ាងថោកទាបចេញទៅ ។ ហ៊ួហ៊ុម ទូលថា ព្រះអង្គទ្រង់ព្រមប្រគល់រាជសម្បត្តិឲ្យចូកីតាមសេចក្តីដំនុំ នាម៉ឺន មុខមន្ត្រីក្រាបទូលថ្វេ បើព្រះអង្គទ្រង់ព្រមប្រគល់ហើយក៏ជាសិរីសុវត្ថិ មង្គលប្រពៃមិនមានភ័យអន្តរាយឡើយ ព្រះចៅហៀនតេទ្រង់ព្រះសណ្តាប់ ហើយក៏ទ្រង់ព្រះកន្សែងសោកាត្រាស់ថា នាម៉ឺនពីបុរាណ ក៏បានយសស័ក្តិ និងប្រាក់បៀវត្សដែលព្រះមហាក្សត្រិយ៍អម្បូរព្រះរាជវង្សរបស់យើង ទ្រង់ ប្រទានប្រោណបានតកូនចៅរៀងមកដល់វេលានេះ ហេតុអ្វីឡើយក៏មិន

មានត្រិះរិះគិតកតញ្ញូដល់ព្រះតេជះព្រះគុណខ្លះសោះ នាំគ្នាមកប្រទុស្តរ៉ាយដូច្នេះ ៗ

ហ៊្លីហ៊ុមទូលថា បើព្រះអង្គមិនធ្វើតាមពាក្យមុខមន្ត្រីប្រឹក្សា ក្នុងថ្ងៃនេះឬថ្ងៃស្អែក នឹងមានអន្តរាយថ្វែក ៗ មកដល់ព្រះអង្គមិនខានឡើយ ពាក្យនេះទូលបង្គំនឹងបានក្រុងទូលព្រះអង្គដោយទុច្ចរិតមុសាក៏ទេ ព្រះចៅហៀនតេត្រាស់ថា បើអស់លោកអ្នកទាំងឡាយកល់គ្នាមិនបានគិតអាក្រក់នឹងយើងទេ នរណានឹងមកប្រទុស្តរ៉ាយនឹងយើងសោត ៗ ហ៊្លីហ៊ុមស្រែកគំហកដោយសំឡេងខ្លាំងថា បណ្តាក្សត្រទាំងអស់គ្នាឃើញថា ព្រះអង្គលង់ឡើមិនសូវមានតម្រិះប្រាជ្ញាបេះរក្សាផែនដី និងមិនចេះដឹងសេចក្តីដែលនឹងគ្រប់គ្រងរាជសម្បត្តិ បានជាកើតចោរដើរស្ទាក់ខ្ទាត់លួចប្លន់គ្រប់ដំបន់នានា ក្សត្រប្រជាក៏កើតក្តៅក្រហាយគ្រប់ស្រុក កើតកន្ទល់កលិយុគខ្លួចខ្ទីវិនាសច្រើនណាស់ គ្រានេះ ពួកជាទីពឹងពំនាក់បានជួយទុក្ខធុរៈអាណាប្រជានុក្សត្រពាសករទាំងឡាយ ហើយទំនួលខ្ទាយជួយទំនុកបំរុងព្រះអង្គឲ្យគង់ជាសុខមកយូរហើយ មិនមែននឹងក្បួងកំចាត់ព្រះអង្គឡើយ គួរហើយព្រះអង្គនឹងដឹងគុណូបការ ពួកដែលព្រះអង្គនៅរឹងមិនព្រមសាមគ្គីប្រគល់ផែនដីឲ្យដូច្នេះ នឹងចង់ឲ្យបណ្តាក្សត្របះបោរបលាចលឲ្យកើតអំពល់ដល់ព្រះអង្គឬ ? ៗ ព្រះចៅហៀនតេឮដូច្នោះក៏ភ័យស្ញាំងកាំង ទ្រង់ក្រោកយាងចូលទៅក្នុងវិញ ៗ

អងឡេងក៏ញាក់មុខឲ្យហ៊្លីហ៊ុម ៗ ស្ទុះក្រោកដើរបន្ទាន់តាមទៅទាន់

ហើយក៏ចាប់ជាប់ខ្នោះជាយព្រះសុភ័គព្រះចៅហៀនគេទុក ហើយធ្វើទឹកមុខជាទឹងខ្ញាំងណាស់ថា ប្រើក្បាការផែនដីមិនទាន់បានសេចក្តីយ៉ាងម្តេចស្តេចមិនត្រូវត្រោកទៅណាទេ ទីងព្រមប្រគល់កជសម្បត្តិ ឬមិនព្រមថាមកចុះ? ព្រះចៅហៀនគេភ័យណាស់ទឹងត្រាស់តបក៏មិនរួច ខ្លាចញ័រអស់ព្រះអង្គ ៗ ចូហាន់ទឹងចូហ៊ាំកំហូតគ្រប់គ្រាលើកឡើងហើយស្រែកថា ត្រាព្រះរាជលញ្ចករសម្រាប់កជ្ជទៅឯណា ចូប៊ិតឆ្លើយថា ត្រាព្រះរាជលញ្ចករខ្ញុំរក្សាទុកឯង ចូហាន់ថា បើត្រាសម្រាប់កជ្ជទៅលើអ្នកឯង ចូរទៅយកមកឲ្យយើងឲ្យឆាប់ ៗ ចូប៊ិតថា ត្រាសម្រាប់កជ្ជនេះជារបស់ព្រះមហាក្សត្រិយ៍ ព្រះអង្គមិនទាន់មានព្រះតម្រាស់ថាឲ្យ ១ ឯងទេ ៗ ចូហាន់ទឹងខ្ញាំងណាស់ ក៏បង្គាប់ទាហានឲ្យចាប់ចូប៊ិតនាំយកទៅសម្លាប់ ចូប៊ិតឥតតក់ស្លុតនេត្រខ្លាចទីងសេចក្តីស្លាប់សោះ បេះតែស្រែកជេរចូហាន់ទាល់តែគេសម្លាប់ ៗ

ព្រះចៅហៀនគេទតឃើញដូច្នោះ ក៏តក់ស្លុតញ័រអស់ព្រះអង្គមិនបាត់ឡើយ ហើយក្រឡេកទៅឃើញទាហានប្រមាណ ៥០០ នាក់គ្រឿងសស្ត្រាវុធគ្រប់ដៃ សុទ្ធតែពួកចូក៏ទាំងអស់ មិនឃើញមានពួកព្រះអង្គសោះឡើយ គិតហើយក៏បញ្ចេញព្រះសូរសៀងថា យើងព្រមប្រគល់កជសម្បត្តិឲ្យហើយ សុំតែជីវិតយើងទុកចុះ កាសៀងថាបើព្រះអង្គព្រមប្រគល់ឲ្យហើយ ទូលបង្គំឃើញថាចូក៏ទឹងថ្វាយជីវិត

ទុកតទៅ មិនបានធ្វើអន្តរាយដល់ព្រះអង្គទេ ត្រូវព្រះអង្គធ្វើព្រះចុតហ្វាយ ប្រគល់កដសម្បត្តិឲ្យប៊ូគីចុះ ៗ

ព្រះចៅហៀនគេបានឮដូច្នោះ ក៏ត្រាស់បង្គាប់គាន់កុយឲ្យតែងព្រះចុតហ្វាយប្រគល់កដសម្បត្តិសេចក្ដីថា យើងបានសោយកដសម្បត្តិគ្រប់គ្រងផែនដីរក្សាសេចក្ដីសុខអស់អាណាប្រជានុរាស្ត្រមក ជាយូរយារគណ-នាកប់ជាប់ ៣២ ឆ្នាំហើយ ឥឡូវផ្កាយប្រចាំព្រះអង្គយើងសៅហ្មងសន្តានចិត្តនាម៉ឺនមុខមន្ត្រីផងនឹងអស់អាណាប្រជានុរាស្ត្រទាំងឡាយ ក៏ឃើញថា រូបកាយនៃយើងមិនសមគួរនៅគ្រងកដសម្បត្តិឡើយ ហើយឃើញថាផ្កាយប្រចាំខ្លួនប៊ូគីជាទីរុងរឿងស្វាងត្រចះ បុណ្យតេជះរបស់គេក៏គួរដល់នូវកដសម្បត្តិពេញបរិបូណ៌ នាម៉ឺនទាំងរាស្ត្រក៏ទាំងនគរក៏សាទរស្រឡាញ់រាប់អាន ឲ្យប៊ូគីបានឋានពីគតគ្រប់គ្រងកដសម្បត្តិ ជាព្រះមហាក្សត្រាធិកដ យើងក៏ព្រមប្រគល់អំណាចកដសម្បត្តិនេះឲ្យប៊ូគីតាមទីប្រាថ្នាមហាជនចុះ លុះធ្វើរួចក៏ប្រគល់ឲ្យហ្វឹហឹមនឹងអស់នាម៉ឺនទាំងពួងនាំយកទៅជាមួយនឹងត្រាបម្រាប់កដ្ឋ ដើម្បីប្រគល់ឲ្យប៊ូគី ៗ

ឯប៊ូគីនោះ លុះបានឃើញព្រះចុតហ្វាយនឹងត្រាព្រះរាជលញ្ឆករសម្រាប់កដ្ឋ ក៏មានចិត្តត្រេកអរសាទរពន់ប្រមាណ គិតចង់បានទទួលយកគ្រងខណៈនោះ តែថាតីមោះមានមាយាធ្វើជារេកសៀមទៅ ៗ សុ-មាអ៊ី ក៏ទូលទាស់ឃាត់ថា ទ្រង់កុំអាលទទួលយកឡើយ រឿងនេះ

ហើយត្រូវតែទ្រង់ធ្វើរឿងកាវថ្វាយត្រានេះទៅវិញសិនទើបគួរសម ដើម្បីនឹងបំបាត់នូវពាក្យគរហានិន្ទាផង ចូកីយល់ឃើញត្រូវទំនង ទើបចាត់ប្រើអង់ឡង់ឲ្យតែងចុកហ្លាយ ១ ច្បាប់កប់រៀបសេចក្ដីថា ទូលបង្គំចូកីទីវ៉ុយអង់សូមថ្វាយត្រាព្រះវលញ្ចកសម្រាប់រាជ្យមកទ្រង់វិញ ព្រោះទូលបង្គំជាអ្នកមានសតិបញ្ញាតិចណាស់ នឹងហើសទទួលយករាជសម្បត្តិតាមសព្វព្រះទ័យតែម្ដងពុំបាន ការនេះគួរតែទ្រង់គិតរកនពីគ្រោះពិចារណាជ្រើសរើសរកអ្នកល្អ ដែលមានតម្រិះប្រាជ្ញាជាជាងទូលបង្គំ ដែលគួរនឹងគ្រប់គ្រងមហាជនក្នុងផែនដីនេះបាន សូមឲ្យទ្រង់ព្រះរាជទានសម្បត្តិទៅអ្នកនោះទើបគួរ ហើយចាត់ប្រើអង់ឡង់និងមន្ត្រីទាំងពួង ឲ្យអញ្ជើញត្រាសម្រាប់រាជ្យនោះទៅថ្វាយព្រះចៅហៀនតេជាមួយនឹងចុកហ្លាយ ។

ព្រះចៅហៀនតេ បានឃើញសំបុត្រនឹងត្រា ក៏ឲ្យព្រួយព្រះចិន្ដាគិតម្ដងទៀត ទើបប្រឹក្សានឹងឋណ្ដាខ្ញុំរាជការទាំងពួងថា ហេតុអ្វីបានជាចូកីបង្វិលត្រាមកឲ្យយើងវិញ ហ្លួហ៊ុមទូលថា កាលព្រះអង្គតាំង ធ្វើជាទីវ៉ុយ·អង់ ចូកីក៏មិនព្រមទទួលដល់ ៣ ដង ឯក្រោយទើបចូកីព្រមទទួល គ្រានេះត្រូវតែព្រះអង្គតាំងទៅទៀតទើបចូកីព្រមទទួល ព្រះចៅហៀនតេ នឹកគ្នាន់ក្នុងព្រះទ័យអាល័យរាជសម្បត្តិណាស់ តែជាត្រូវការដោយសេចក្ដីខ្លាចគេ ទើបបង្គាប់ឲ្យហាងវៃកែតែងព្រះរាជតម្រាស់សេចក្ដីថា ចូកីនេះសមគួរណាស់ ហើយដែលនឹងត្រូវទទួលរាជសម្បត្តិជំនួសយើងបាន ។

(នៅមានត)

# ឯកសារ សាស្ត្រាស្លឹករឹត និង ក្រាំង

*ដែលមាននៅវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ*

លោក ញ៉ុក-ថែម រៀបរៀង

( ត )

ចំណងជើង : " សាស្ត្រា កុមារភណា "(១)

អ្នកនិពន្ធ : *សុវណ្ណបញ្ញា (ប្រហែលនាមធាយា?) ។*

កាលបរិច្ឆេទ : *ថ្ងៃព្រហស្បតិ៍ ២ កើត ខែបុស្ស ឆ្នាំថោះសប្តស័ក ព.ស. .. ? ។*

របៀបនិពន្ធ : *ពាក្យកាព្យ បទកាកគតិ – ពំនោល – ព្រហ្មគីត – មណោ្ឌកាក និង បទឥន្ទ្រវិជិត ។*

ប្រភពរឿង : *រឿងព្រេង ។*

លក្ខណៈឯកសារ : *សាស្ត្រាស្លឹករឹត មាន ១៣ ខ្សែចប់ ។*

---

១ – សាស្ត្រាកុមារភណានេះ កវីតាំងចិត្ត រៀបរៀងជារឿងជាតក ១ ដូចសេចក្តីផ្តើមរបស់កវី ប៉ុន្តែខ្វះអត្ថបទបញ្ចប់ ដោយការសដាតិ ។ ឯកសារមានចំនួនដល់ ១៣ ខ្សែ តែមិនចប់ ត្រូវកវីបញ្ចប់ដោយបង្ខំ ទើបអត្ថបទបញ្ចប់របស់កវី មិនសូវសមហេតុសមផលទេ? ។

អត្ថបទក្នុងផ្ទៃរឿង គ្មានលក្ខណៈដូចជារឿងជាតកទេ បែរជាមានអត្ថន័យទាក់ទង និងទំនៀមទម្លាប់ ពិធីបុណ្យទានផ្សេងៗ និងជំនឿផ្សេងៗរបស់ខ្មែរ កាលពីសម័យព្រេងនាយ ។ គួរកត់សំគាល់ថា សេចក្តីរៀបរៀងរបស់កវីនេះ មិនសូវរៀបរាយទេ ទាំងពាក្យកាព្យសោតទៀត ក៏មិនសូវល្អ ទាំងមានតក់ច្រើនផង ។

ខ្សែទី ១ មានសន្ទឹក ៣៦, ទី ២ មានសន្ទឹក ៣៦,

ទី ៣ មានសន្ទឹក ២៩, ទី ៤ មានសន្ទឹក ៣១,

ទី ៥ មានសន្ទឹក ៣៣, ទី ៦ មានសន្ទឹក ៣១,

ទី ៧ មានសន្ទឹក ៣១, ទី ៨ មានសន្ទឹក ៣១,

ទី ៩ មានសន្ទឹក ៣៥, ទី ១០ មានសន្ទឹក ៣៨,

ទី ១១ មានសន្ទឹក ៣៥, ទី ១២ មានសន្ទឹក ២៤,

ទី ១៣ មានសន្ទឹក ២២ ។

ឯកសារនេះ ពុទ្ធសាសនបណ្ឌិត្យ បានច្បាប់ដើមមកពីវត្តសត្បូរ ចុះលេខសាស្ត្រា ១៣៩៣ ។

**អត្ថបទផ្តើម:** នេះគឺបទព្រហ្មគីត ខ្ញុំលើកហត្ថលុតជង្គង់ បង្គំផ្តោះតម្រង់ ទៅព្រះអង្គត្រាស់វិញ្ញាណ ។ ព្រះស្រីកែវរត្នត្រៃ បង់ដកថ្ងៃ ព្រះកម្មដ្ឋាន ព្រះវិបស្សនាមាន ព្រះអភិធម្មនាំប្រាប់ ។ ព្រះនព លោកុត្តរ ធម៌បវរប្រាំបួនណា ព្រះត្រៃលក្ខណញាណជា នូវ ព្រះត្រៃសរណគមន៍ ។ ...

អហារីនាមនៃ លោកស្រដីមកនេះជា នាមសុវណ្ណបញ្ញា ចិត្តសន្តានឹកកែះរេ ។ ផ្តាំថោះសប្តស័ក នោះទៀនជាក់ខែបុស្ស ថ្ងៃព្រហស្បតិឯផង ពីកើតខែនេះឯងហោង ។

អវត្តបទបញ្ចប់: បើលោកណាប្រាជ្ញផង មើលហើយហោងគុំទិទ្ធា

ជួយតម្រង់ឲ្យជា ត្រូវពណ៌នាឡើងបរិយាយ ។

ទិតាននេះទៀតទេ កាព្យបន្ទំកអតិប្រាយ

បរិបូណ៌ចប់បរិយាយ អស់អម្បាលណោះហើយនៃ ។

ទិតានតាមបរិយាយ រឿងនិយាយកយសំដី

សូមទេចប៉ុណ្ណោះខ្ញី អស់ម៉្លេះនៃបរិបូណ៌ហោង ។

XXX

បំណងជើង : " សាស្ត្រា ចន្ទឃាត(១) "

អ្នកនិពន្ធ : មាន ៣ រូប គឺពៅពញាកដាកត្តិ, ពៅពញាជំនិត-

ក្សត្រ និង ពៅពញាស្រីអញ្ចិត ។

កាលបរិច្ឆេទ : ផ្ដើមនិពន្ធនៅថ្ងៃព្រហស្បតិ៍ ៨ កើតខែជេស្ឋ ឆ្នាំមមី

ព.ស. ២៤០១ (គ.ស. ១៨៥៨) ។

---

១ ពាក្យថា "ចន្ទឃាដ" ឬ "ចន្ទឃាតក៍" តាមរូបស័ព្ទ មានន័យមិនស្របតាមដំណើររឿងនេះទេ ព្រោះឈ្មោះតួអង្គសំខាន់ ដែលជាតួឯកក្នុងផ្ទៃរឿង មាននាមដូច្នេះ ព្រោះតួអង្គនេះកើតលើថ្ងៃដែលមានរាហូចាប់ចន្ទដែលហៅថា "ចន្ទគ្រាះ" ។ ដូច្នេះ តួអង្គនេះគួរសរសេរជា "ចន្ទគ្រាះ" (សំ.) ឬ "ចន្ទគាហៈ" (បា) ដូច្នេះវិញ ទើបស្របតាមកំណើតរបស់តួអង្គនេះ។

តួអង្គ ១ ទៀត ដែលត្រូវជាបងប្អូនជាតួអង្គសំខាន់ទីពីរ មាននាមថា "សូរ្យឃាត" ក៏គួរសរសេរថា "សូរ្យគ្រាះ" ដូច្នេះវិញដែរ ទើបស្របតាមប្រវត្តិកំណើតរបស់ខ្លួន ព្រោះតួអង្គកើតក្នុងថ្ងៃដែលមានសូរ្យគ្រាះ (រាហូចាប់ព្រះអាទិត្យ) ឯច្បាប់បាលីដើម មានអក្ខរាវិរុទ្ធដូចម្ដេច ខ្ញុំមិនទាន់បានពិនិត្យប្រៀបធៀបមើលព្រោះគ្មានឯកសារជាភាសាបាលីនៅដិតដៃ ។ អ្នកពៅ

របៀបនិពន្ធ : ពាក្យកាព្យ (បទកាកគតិ -ពំនោល -ព្រហ្មគីត- កុដ្ឋលីលា ។

ប្រភពរឿង : មហាសិបជាតក៍ ឬ បញ្ញាសជាតក ។

លក្ខណៈឯកសារ : សាស្ត្រាស្លឹករឹត ១០ ខ្សែចប់ជុំជាតក៍ ។ ខ្សែទី ១ មានសន្លឹក៣៨, ទី ២ មានសន្លឹក ៤៥, ទី ៣ មានសន្លឹក ៣៤,

---

ពញាជំនិតក្សត្រី បានចាប់ផ្តើមនិពន្ធអត្ថបទកំណាព្យនេះនៅថ្ងៃ ៥ ៨ ពី ឆ្នាំមមី ព.ស. ២៤០១ បាននិពន្ធចប់ក្នុងថ្ងៃ ៤ ៨ ក្នុងឆ្នាំមមីដដែល អស់ថិរវេលាត្រឹម ៧០ ថ្ងៃ (២ខែ ១០ ថ្ងៃ) ។

ឯកសារនេះ មានចំនួនសន្លឹកសាស្ត្រាដល់ ៤៥៥ សន្លឹក គប្បីចាត់ទុកជាមហាកំណាព្យយ៉ាងវែងមួយ ហើយកវីបាននិពន្ធអស់ថិរវេលាដ៏ខ្លីជាងពីរខែប៉ុណ្ណោះ ក៏បានចប់គ្រប់ ហើយជើងកាព្យសោតទៀត ក៏មិនសូវមានតក់ទេ ដែលមានតក់ខ្លះ ដោយសារភ្លាំងភ្លាត់នៅពេលចារចម្លងតៗគ្នាមក ។

បើទុកជាកវីបានបញ្ជាក់ថា ខ្លួនបានអញ្ជើញកវីពីររូបទៀតឲ្យជួយតែងផងក៏ដោយ ក៏នៅតែគួរស្ងើចសរសើរដល់ស្នាដៃតែងកំណាព្យយ៉ាងវែងនេះដែរ ។

ឯកសារនេះ ពិតមែនតែជារឿងជាតក តែអត្ថន័យ នៃរឿងទូទៅ លេចចេញមកអំពីឥទ្ធិពលនៃគោលនិយមផ្សេងៗលាយចម្រុះគ្នា ។

តួអង្គសំខាន់ ដែលកវីបានទុកដាក់ជាតួអង្គពោធិសត្វនោះ បានបំពេញសកម្មភាពផ្សេងៗស្របតាមលក្ខណៈមនុស្សនិយម ដូចជារក្សាការយុត្តិធម៌ គោរពប្រពៃណី កាន់ទំនៀមទម្លាប់ជាអាទិ ។ តួឯកក្នុងផ្ទៃរឿង បានបំពេញសកម្មភាព បង្ក្រាបសភាវៈអាក្រក់ផ្សេងៗ ដូចជាព្រះរាមដែរ តែមិនឃោរឃៅទេ គឺមានលក្ខណៈទន់ភ្លន់ស្របតាមគតិយុត្តិធម៌ច្រើន ជាពិសេសស្របតាមគតិបណ្ឌិត មិនលុះដោយលោភៈ ទោសៈ ឬក្រេវក្រោធគិតពិចារណាទេ ។

នៅទីបំផុត កវីបានបញ្ជាក់អំពីឥទ្ធិពលនៃកម្មផល នៃតួអង្គផ្សេង ៗ កាលអំពីអតីតជាតិដែលតួអង្គនីមួយៗត្រូវទទួលផលវិបាកជាចាំបាច់ ដូចមានរឿងបញ្ជាក់ក្នុងផ្ទៃរឿងស្រាប់ ។

ទី ៤ មានសន្លឹក ៣៦, ទី ៥ មានសន្លឹក ៤៣, ទី ៦ មាន
សន្លឹក ៤៦, ទី ៧ មានសន្លឹក ៤០, ទី ៨ មានសន្លឹក ៥៨,
ទី ៩ មានសន្លឹក ៥៦, ទី ១០ មានសន្លឹក ៤៩ ។ បូករួម
ទាំងអស់ត្រូវជា ៤៥៥ សន្លឹកស្លឹករឹត ។ ឯកសារនេះ ពុទ្ធសា-
សនបណ្ឌិត្យ បានចម្លាប់អំពីវត្តសំរោង ស្រុកកៀនស្វាយ ខេត្ត
កណ្តាល យកមកចារចម្លងរក្សាទុកកាលពី គ.ស. ១៩៤៤
ចុះលេខសាស្ត្រា ។

**អត្ថបទផ្តើម** កាកបទ អតិទុក្ខក៏ ចប់មបទំ មមបញ្ញា អកោសលំ
ធិរ៉ាមាំ គរហិកា ។ មយាវន្ទេ មសម្ពុទ្ធេ សិរសាសទា
ទសន្គុលិ បតិដ្ឋិតា អវបាទា លោកនាថោ ៕
មយំដើមបទ យើងខ្ញុំលំអុត ទូនអង្គអភី ផ្គួបផ្គុំតាំង
បញ្ចង្គប្រតិ ក្រាបក្រោមបាទវី– សេសសុទ្ធសាស្តា ។ ព្រះអង្គ
គ្រូគ្រប់ ត្រាណាត្រើយត្រៃភព ឯកអង្គនាថា ប្រោសប្រាណ
ប្រែប្រាស លាកលះលេងលា ទុកចៀសពោលអា- បាយ
បាបបង់ទៅ ។ . . . ។ល។

**អត្ថបទបញ្ចប់** ចន្ទឃាដជា- តកនិដ្ឋិតា និពានព្រះបាទ ចន្ទឃាដថ្ងៃថ្លា
ក្នុងហាសិបជាតក៍ នៅក្នុងនិបាត ថែងចប់សេចក្តី ។ និពាន
កាព្យ នេះនាមចៅពញា ជំនិតក្សត្រ លើកជាល្បើកថ្វាយ

បរិយាយសេចក្តី ដោយបទបាលី ជុំជាតកសព្វគ្រប់ ។
ជាតកសេចក្តី នេះខ្ញុំតាំងពី តែងតាំងថ្វាយបង ដោយប្រាជ្ញាខ្លៅ
ពុំសូវប្រសប់ តែងនៅតាំងឋប់ ជួបចប់និទាន ។ ថ្ងៃពុធប្រាំបី
កេចស្រាពណ៍មាសី ឆ្នាំមមីបាន សកពជសាសនា ព្រះអនាវ-
រញ្ញាណ ឯខែនោះបាន ចតុមាសា ។ ថ្ងៃបានកំណត់
ប្រាំពីរថ្ងៃគត់ ឯឆ្នាំគណនា ពីរពាន់បួនរយ និងមួយវស្សា
សង្ខេបគាថា សូរេចម្វ៉េះហោង ។

×××

បំណងជើង : " សាស្ត្រា សុបិនក្ខ "

អ្នកនិពន្ធ : រកពុំទាន់ឃើញ ។

កាលបរិច្ឆេទ : គ្មានបញ្ជាក់ក្នុងអត្ថបទ ។

របៀបនិពន្ធ : ពាក្យកាព្យ ( បទកាកគតិ និង បទពំនោល ) ។

ប្រភពរឿង : រឿងព្រេងខ្មែរ ?

លក្ខណៈឯកសារ : សាស្ត្រាស្លឹករឹត ១ខ្សែមាន ១៨ សន្លឹក ។

ឯកសារនេះ ពុទ្ធសាសនបណ្ឌិត្យ បានមកអំពីវត្តខ្វង់ ខេត្ត កំពង់ចាម ចុះលេខសាស្ត្រា ៦៦៧ ។

សាស្ត្រាប្រភេទនេះ មានច្រើននៅតាមវត្តទាំងឡាយ ។ ព្រោះ

កាលជំនាន់ដើម គេនិយមឲ្យក្មេង ៗ នៅវត្តហាត់រៀនអានសាស្ត្រានេះ ជាដំបូងជាមួយសាស្ត្រាច្បាប់ផ្សេង ៗ ។

អត្ថបទផ្ដើម : នេះបទកាកគតិ ។ ប្រណាម្យផ្ទូលី ដាក់លើសិរសី ក្រាបក្រោមបាទា ព្រះបាទសម្ដេច សារពេជ្ញសាស្ដា ថ្វាយវរវន្ទា នៃព្រះគូរនាថ ។ ព្រះអង្គត្រាស់ត្រេច សាងសម្ភារស្រេច ផ្ដាច់វដ្ដសង្សារ លើសលែងត្រៃភព សាយសព្វពិស្ដារ ស្ដេចផ្ចាញ់ក្រុងមារ រួចដល់និព្វាន . . . ។ល។ . . .

អត្ថបទបញ្ចប់ : សាធុសម្លាយ ចូរស្ដាប់អភិប្រាយ ជាបរិយោសាន រួមសេអាថ៌ធម៌ ជាច្បាប់សព្វប្រាណ ទុកតែងទូន្មាន អាត្មាសព្វថ្ងៃ ។ អស់ភិក្ខុសាមណេរ ចូរចាំដំណែល នេះឯងប្រពៃ បានបួសជាសង្ឃ ទ្រង់ដោយធម៌ថ្លៃ បានបរិបូណ៌ក្រៃ សម្បត្តិនិព្វាន ។ គួរតែសទ្ធា គួរតែឧស្សាហ៍ សន្សំឲ្យបាន គួរតែសូត្ររៀន ធម៌ជាប្រធាន នាំខ្លួនឲ្យបាន និព្វាននាយហោង ។

សុបិនជាតក ព្រះអ្នកថ្លែងទុក ( ជាបណ្ដាំផង ) គួរចាំគួរចាប់ គួរស្ដាប់គួររង ធម៌នេះឯងហោង បរិបូណ៌ចែងចប់ ។

ចំណងជើង : « សាស្ត្រាច្បាប់ស្រីធំ »

អ្នកនិពន្ធ : គេមិនទាន់ឃើញ ។

កាលបរិច្ឆេទ : គ្មានបញ្ជាក់ក្នុងអត្ថបទ ។

របៀបនិពន្ធ : ពាក្យកាព្យ (បទភុជង្គលីលា)

ប្រភេទរឿង : សីលធម៌ និង ប្រពៃណីនិយម ។

លក្ខណៈឯកសារ : សាស្ត្រាស្លឹករឹត ១ ខ្សែ មាន ៨ សន្លឹក ។

ឯកសារនេះ បានមកពីវត្តខ្វង់ ខេត្តកំពង់ចាម លេខសាស្ត្រា ៦៦៧ ។ សាស្ត្រាប្រភេទនេះ មានផ្សាយខ្លះទៅ នៅតាមវត្តទាំងឡាយ ។

អត្ថបទដើម: នេះបទកំណត់ចង់ជា ភុជង្គលីលា ចង់ជាច្បាប់ស្រី ។

កាលនាងឥរេនទតី ចរោកតាមប្ដី បណ្ណកយក្សា ។ នាងវិមលា ជាព្រះមាតា បើកបន្ទូលថា ហៃកូនពិសី ។ នាងនឹងត្រេច ត្រង់តាមប្ដី ចេញចាកអំពី ពិភពនាគនេះ ។ . . .

. . . . ។ល។ . . . .

អត្ថបទបញ្ចប់ : ច្បាប់នេះឧត្តមថ្លៃថ្លា បើស្រីឯណា បានរៀនបាន ស្ដាប់ . . . . (ផុត)

ហៅមហាកិត្តិត្រៃកន្លង ជាលាភណាស់ហោង បានស្ដាប់ ប្រពៃ ។ . . . (ផុត)

ហើយចូរចាំចងគ្រប់គ្នា ស្ដាប់ច្បាប់នេះណា ប្រសើរពេកក្រៃ ។
ចូរចាំកុំភ្លេចឡើយនៃ ចរចាអស់ឮ វែងចប់សេចក្ដី ។ ច្បាប់
នេះឧត្ដមប្រពៃ ជាច្បាប់អស់ស្រី បរិបូណ៌ចប់ហោង (១) ។

×××

ចំណងជើង : "សាស្ត្រា ក្បួនចៅពាក្យចាស់(២)"

អ្នកនិពន្ធ : រកមិនទាន់ឃើញ

កាលបរិច្ឆេទ : គ្មានបញ្ជាក់ក្នុងអត្ថបទ ។

របៀបនិពន្ធ : ពាក្យកាព្យ (បទកាកគតិ និងព្រហ្មគីត) ។

ប្រភេទរឿង : ច្បាប់សីលធម៌និងប្រពៃណីនិយម ។

លក្ខណៈឯកសារ : សាស្ត្រាស្លឹករឹត ១ ខ្សែ មាន ៧ សន្លឹកកន្ទុះ ។

ឯកសារនេះ បានមកពីវត្តខ្វង់ ខេត្តកំពង់ចាម លេខសាស្ត្រា ៣៦៧ ។

---

១– ច្បាប់នេះ មានវិបត្តិ ដើមពាក្យ និងរលងឃ្លាល្បះច្រើនអន្លើ ដោយការចារចម្លងត ៗ គ្នា ។

២– ច្បាប់នេះ នៅអត្ថបទខាងដើម ប្រើបទកាកគតិ រៀបរាប់សរសើរគុណម្ដាយ និងលក្ខណៈទារកដែលមកចាប់កំណើតក្នុងផ្ទៃម្ដាយ ។ ខាងចុងប្រើបទព្រហ្មគីត គឺជាច្បាប់ពាក្យចាស់តាមធម្មតា ដូចមានពាក្យផ្ដើមថា : បទព្រហ្មគីត ។

ពាក្យចាស់ពាក្យពីព្រេង ទោសខ្លួនឯងមើលមិនយល់ ទោសគេតូចសោតសល់ រមិលយល់ប៉ុនទាំងភ្នំ ។

អត្ថបទផ្ដើម : កូនអើយចាស្ដាប់ អាតុកទីនប្រាប់ ដោយបទគាថា
ព្រះស្រីសារពេជ្ញ ស្ដែងស្ដេចទេសនា សរសើរគុណមា-តា
ដោយគម្ពីរ ។ សណ្ដាប់ប្រាជ្ញផង ដោយទូវគន្ធ អាថ៌
ព្រះបាលី ច្បាស់ច្បាប់សួស្ដី នរប្រុសស្រី ចងចាំគ្រប់ប្រាណ
. . . ។ល។ . . . .

អត្ថបទបញ្ចប់ : (បទព្រហ្មគីត) រីឯអ្នកផង ឲ្យចាំចងប្រសើរពិត
កុំធ្វើឥតបើគិត គេមិនរាប់ជាមនុស្សឡើយ ។
ច្បាប់នេះប្រសើរគាប់ ជួបជុំចប់ជាតកហើយ ទៅឆ្ងាយល្វេង
ល្ហើយឡប់ខ្សែឡាត់សួរបេហោង ។

×××

បំណងដើង : « សាស្ត្រា ច្បាប់ក្រម »

អ្នកនិពន្ធ : រកមិនទាន់ឃើញ ។

កាលបរិច្ឆេទ : គ្មានបញ្ជាក់ក្នុងអត្ថបទ ។

របៀបនិពន្ធ : ពាក្យកាព្យ (បទកាកគតិ)

ប្រភពរឿង : ច្បាប់សីលធម៌និងប្រពៃណីនិយម។

លក្ខណៈឯកសារ : សាស្ត្រាស្លឹករឹត ១ ខ្សែមាន ៣ សន្លឹកកន្ទះ ។
ឯកសារនេះ បានមកពីវត្តខ្វង់ ខេត្តកំពង់ចាម លេខសាស្ត្រា

៦៦៧ ។ សាស្ត្រាច្បាប់នេះ សម្បូរណាស់តាមវត្តទាំងឡាយ ។

អត្ថបទផ្ដើម : នេះបទកាកគតិ ។ នេះគឺច្បាប់ក្រម ប្រសើរឧត្ដម
ខ្ញុំនានអ្នកផង ប្រើទទួលទោនកុំបីមានធ្គង ប្រាជ្ញាបុណ្យផង
កើតដោយប្រណិបតន៍ ។ . . . . .

. . . . . . . ។ល។ . . .

អត្ថបទបញ្ចប់ : នរអ្នកណា ទីងនាំអាត្មា សង្វាហ៍អវេច្បាគ ស្វែង
ធម៌ជាផ្លូវ ទៅកាន់បរលោក ចូលមហាធាតុមោក្ខ គឺនិព្វាន
ហោង ។

×××

បំណងដើង : „ សាស្ត្រាក្រមច្បាប់ „

អ្នកនិពន្ធ : កំមិនទាន់ឃើញ ។

កាលបរិច្ឆេទ : គ្មានបញ្ជាក់ក្នុងអត្ថបទ ។

របៀបនិពន្ធន៍ : ពាក្យកាព្យ បទកាកគតិ ។

ប្រភពរឿង : ទំនៀមទំលាប់ទីងប្រពៃណីនិយមក្នុងព្រះពុទ្ធសាសនា។

លក្ខណៈឯកសារ : សាស្ត្រាស្លឹករឹត ១ ខ្សែមាន ៥ សន្លឹកចប់ ។
ឯកសារនេះ ពុទ្ធសាសនបណ្ឌិត្យ បានមកពីវត្តខ្នុង កំពង់ចាម
ចុះលេខសាស្ត្រា ៦៦៧ ។

អត្ថបទផ្ដើមៈ បទកាកគតិ ។ នេះគឺក្រមច្បាប់ ព្រះលោកបង្គាប់

ទូន្មានអ្នកផង កើតនាលោកិយ ដែនដីនេះហោង ឲ្យបាន

បួសសង គុណព្រះមាតា ។ បួសហើយលំអុត ចាំសីល

ស្រគត់ ចម្រើនភាវនា សង្វាតសូត្ររៀន រៀនអាត្មា ខ្ជី

ឃ្លាតក្រោ កុំខ្ជិលឡើយហោង ។ . . . ។ល។ . . .

អត្ថបទបញ្ចប់ៈ ច្បាប់នេះប្រពៃ ប្រសើរថ្លាថ្លៃ លែងក្រមច្បាប់ផង

ចូរចាំចូរចាប់ ដោយច្បាប់ធម៌ផង ចូរគ្រាប់ចូរគ្រង ចូរ

រៀនចាំចង ទុកនៅអាត្មា ។ បើអ្នកណាចាំ អស់អាថ៌

កិច្ចកម្ម ដោយព្រះគាថា អ្នកនោះឯងបាន ដូចក្ដីប្រាថ្នា

សួរបេបកាក និដ្ឋិតចប់ហោង ។

×××

បំណងជើង : " សាស្ត្រា សេចក្ដីក្រមច្បាប់ ",

អ្នកនិពន្ធ : រកមិនទាន់ឃើញ ។

កាលបរិច្ឆេទ : គ្មានបញ្ជាក់ក្នុងអត្ថបទ ។

របៀបនិពន្ធ : ពាក្យកាព្យ បទកាកគតិ ។

ប្រភពរឿង : សុជីវធម៌ និងសីលធម៌ តាមប្រពៃណីនិយម ។

លក្ខណៈឯកសារ : សាស្ត្រាស្លឹករឹត ១ ខ្សែ ៧ សន្លឹក ។

ពុទ្ធសាសនបណ្ឌិត្យ បានចារចម្លងអំពីវត្តខ្វង់ ខេត្តកំពង់ចាម

ចុះលេខ ៦៦៧ ។

អត្ថបទផ្ដើម : នេះបទកាកគតិ ។ ក្រមច្បាប់នេះគិត លើកតាម

សុចរិត គន្លងមាត្រា តែងជាបរិយាយ ទុកឲ្យអស់មហា-ជន

ផងនានា ត្រាន់មើលតទៅ ។ ច្បាប់នេះជាល្បើក ទើប

និងរៀនលើក ពុំដឹងខុសត្រូវ ដៀតក្មេងសេចក្ដី ប្រាជ្ញា

ខ្វីខ្វៅ ពុំទាក់ជាក់នៅ អស់អាថិទំនង ។

. . . . . . . ។ល។ . . . .

អត្ថបទបញ្ចប់ : អស់អាថិកាព្យកិច្ច ពាក្យល្បើកសេចក្រេច នូវពាក្យ

សច្ចា សូមឲ្យទៀងទាត់ កុំឃ្លាតឡើយណា សូរេចបកាព

និដ្ឋិតំចប់ហោង ។

(នៅមានត)

# ឯកសារ កម្ពុជសុរិយា

(គ)

លោក ឌឹក-គាម ប្រមូលរៀបរៀង

សេចក្ដីដំណាលពីរឿងភិក្ខុមួយរូប: ព្រះមហា ប៉ុណ្ណ-សម្ភាជ ទ.ក. ៨, ទំព័រ ៤៣៦, ឆ្នាំ ១៩៤៧, (ម.៥២/១៩) ។

សេចក្ដីដំណាលអំពីទេវបុត្តមារនិងព្រះថេរឧបគុត្ត : ព្រះមហា ប៉ុណ្ណ-សម្ភាជ ទ.ក. ៦, ទំព័រ ៣៣០, ឆ្នាំ ១៩៤៧, (ម.៥២/១៩) ។

សេចក្ដីថ្លែងការណ៍ សារពត៌មាន របស់ព្រះតេជព្រះគុណព្រះពោធិវង្ស ហួត-តាត : ទ.ក ៨, ទំព័រ ៩៥០, ឆ្នាំ ១៩៥៩, (ម.៥២/៣១) ។

សេចក្ដីថ្លែងគុណព្រះមហាវិមលធម្មថោង : ព្រះគ្រូសំឃវិជ្ជា ហ-គាត ទ.ក. ២, ទំព័រ ៣៩, ឆ្នាំ ១៩២៧, (ម.៥២/២) ។

សេចក្ដីបង្ហាញប្រយោជន៍ : អ្នកឧកញ៉ាពិទិត្យវោហារ ជួន-ហិល ទ.ក. ៤, ទំព័រ ៨៧, ឆ្នាំ ១៩២៦-២៧, (ម.៥២/១) ។

សេចក្ដីបង្ហាញប្រយោជន៍នៃទស្សនាវដ្ដីកម្ពុជសុរិយា

ដល់សាធារណជន : ព្រះអង្គម្ចាស់ក្រុមព្រះ នរោត្តម ភាណុវង្ស
ទ.ក. ១, ទំព័រ ១៥, ឆ្នាំ ១៩២៧ (ម.៥២/២) ។

សេចក្ដីបរិសុទ្ធិនៅឯណា : ព្រះទេពសត្ថា គឹម-គូរ ទ.ក. ៩,
៦៤៣, ឆ្នាំ ១៩៥៥, (ម.៥២/២៤) ។ ទ.ក ៨, ទំព័រ
ទំព័រ ៨៥១, ឆ្នាំ ១៩៦០ (ម.៥២/៣២) ។

សេចក្ដីប្រកាសបដិការ របស់ ព្រះមហាវិមលធម្ម
ថោង : ព្រះគ្រូសំសត្ថា ជ - ណាត ទ.ក. ២, ទំព័រ ៥១
ឆ្នាំ ១៩២៧ (ម.៥២/២) ។

សេចក្ដីប្លែក ៗ : ទ.ក. ៣, ទំព័រ ២១, ឆ្នាំ ១៩៤២,
(ម.៥២/១៤) ។

សេចក្ដីផ្ទុយតទល់នឹងការឃោសនា : ទ.ក. ៥, ទំព័រ
៨, ឆ្នាំ ១៩៤១ (ម.៥២/១៣) ។

សេចក្ដីពណ៌នា គាំត្តគុណ របស់ព្រះមហាវិមលធម្ម-
ថោង ព្រះញាណវីរិយឡុង ទ.ក. ២, ទំព័រ ១០៥, ឆ្នាំ
១៩២៧, (ម.៥២/២) ។

សេចក្ដីពណ៌នាតាមគោលខ្លះអំពី ក្បាច់អលង្ការ ក្នុង
ប្រទេសឥណ្ឌូចិន : លោក ល្វី-ហ្វីណូត៍ ទ.ក ៤, ទំព័រ ៣៩,
ឆ្នាំ ១៩២៧ (ម.៥២/២) ។

សេចក្តីពណ៌នាមរណកិច្ច របស់ព្រះមហាវិមលធម្ម-
ដោយ : ព្រះគ្រូវិមលបញ្ញា អ៊ុម-សូរ ក.ក. ២, ទំព័រ ៩៧
ឆ្នាំ ១៩២៧ (ម.៥២/២) ។

សេចក្តីពណ៌នា អំពីគុណ របស់ ព្រះមហាវិមលធម្ម-
ដោយ : លោក លី-ហ៊ួណុក ក.ក. ៣, ទំព័រ ៣, ឆ្នាំ ១៩២៧
(ម.៥២/២) ។

សេចក្តីពន្យល់អំពីពាក្យខ្មែរខ្លះ ( ក្នុងសេចក្តីរាយការណ៍ជាភាសាចិនក្នុងសតវត្សទី ១៣ : (លោក
សីដេស ) ហ្វូននិពន្ធមន្ត្រី ញ៉ុក-ថែម ក.ក. ១២, ទំព័រ
៦១៩, ឆ្នាំ ១៩៤៤ (ម.៥២/១៦) ។

សេចក្តីពិចារណានៃពុទ្ធសាសនិកជនម្នាក់ : លោក
ប៉ាយ-ប៊ុក ក.ក. ១១, ទំព័រ ៩៨០, ឆ្នាំ ១៩៥៧
(ម.៥២/២៩) ។

សេចក្តីមួយ និយាយអំពីពង្សាវតារសង្ខេប របស់
ប្រទេសកម្ពុជា : ក.ក. ១៤, ទំព័រ ៦៣, ឆ្នាំ ១៩៤១,
(ម.៥២/១៣) ។

សេចក្តីយល់ឃើញអំពីប្រាសាទនគរវត្ត : លោក ព្រាតស៊ី
ក.ក. ៧-៨-៩, ទំព័រ ៩៧, ឆ្នាំ ១៩៣៦, (ម.៥២/៨) ។

សេចក្ដីយុត្តិធម៌ និងប្រាក់ : លោក កយ · ប៊ុក ទ.ក. ៦, ទំព័រ ៦៦៧; ឆ្នាំ ១៩៦៤, (ម.៥២/៣៦) ។

សេចក្ដីរាយការណ៍អំពីពួកតំណាងខេត្តកំពត នាំប្រាក់ចំនួន ១.០០០ មកជូនព្រះរាជបណ្ណាល័យ : ទ.ក. ១១ ទំព័រ ១០១ ឆ្នាំ ១៩២៧ (ម.៥២/២) ។

សេចក្ដីរំលឹកគុណ លោករេស៊ីដង់ សុប៉េរីយ៉ើរ បូ. ដ្វាំង : ទ.ក. ៧, ទំព័រ ៣ ឆ្នាំ ១៩២៦-២៧ (ម.៥២/១) ។

សេចក្ដីរំលឹកជាសំនៀង (កាព្យ) : ព្រះគិរម្យភាសាអ៊ូ ទ.ក. ៧·១២, ទំព័រ ៩៧, ឆ្នាំ ១៩៣៣, (ម.៥២/៥) ។

សេចក្ដីល្អ សេចក្ដីអាក្រក់ : លោក ស៊ុន · ហ៊ាន ទ.ក. ៤, ទំព័រ ២៥៩ ឆ្នាំ ១៩៥៣ (ម.៥២/២៥) ។

សេចក្ដីសង្ខេបនៃគម្ពីរបញ្ចតន្ត្រៈ : ទ.ក. ១៩ - ២០ ទំព័រ ២៦, ឆ្នាំ ១៩៤២, (ម.៥២/១៤) ។

សេចក្ដីសង្គ្រោះ : លោក ផេង · ជ្រើ ទ.ក. ២ ទំព័រ ១៧៧ ឆ្នាំ ១៩៦៣ (ម.៥២/៣៥) ។

សេចក្ដីសន្និដ្ឋានមួយអំពីការកសាងព្រះកែវមរកត: ទ.ក. ១៦ ទំព័រ ១០ ឆ្នាំ ១៩៤១ (ម.៥២/១៣) ។

សេចក្ដីសាមគ្គីធាកំងសេស និង ខ្មែរ : ទ.ក. ១០,
ទំព័រ ៦, ឆ្នាំ ១៩៤១ (ម.៥២/១៣) ។

សេចក្ដីសុខ និង សេចក្ដីចំរើន របស់ប្រទេស តែង
ប្រព្រឹត្តទៅជាមួយនឹងវប្បធម៌ : លោក ប៉យ-ប៊ុក ទ.ក. ៨,
ទំព័រ ៧៣៣, ឆ្នាំ ១៩៥៦ (ម.៥២/២៨) ។

សេចក្ដីសូត្ររំលឹកគុណាឧទ្ទិសដល ចំពោះព្រះមហា
វិមលធម្មបោង : ទ.ក ២, ទំព័រ ១៨៥, ឆ្នាំ ១៩២៧,
(ម.៥២/២) ។

សេចក្ដីសំខាន់ ៗ ក្នុងសៀវភៅមួយ របស់ប្រទេស
ជប៉ុន : ទ.ក. ៨, ទំព័រ ៨, ឆ្នាំ ១៩៤១, (ម.៥២/១៣ )

សេចក្ដីសំគាល់អំពីរូបព្រះមេត្រិយពោធិសត្វដែលតាំង
នៅក្នុងព្រះរាជបណ្ណាល័យ : កាប៊ីឡេស ទ.ក. ១,
ទំព័រ ១៩, ឆ្នាំ ១៩២៧, (ម.៥២/២) ។

សេចក្ដីស្រង់ធម៌ទេសណាយ៉ាងសង្ខេប : លោកកំម៉ង់ផ្គ
ទ.ក. ៨, ទំព័រ ៩៣, (ម.៥២/៣) ។

សេចក្ដីស្រង់ពីព៉ារ (លោកអាំងស្បិកទ័រត្រួតសាលា
បឋមវិជ្ជានៅកម្ពុជាក្រោម ) : ទ.ក. ៤ - ៥ - ៦, ទំព័រ
១២, ឆ្នាំ ១៩៣៥ (ម.៥២/៧) ។

សេចក្តីស្រង់អំពីរឿងមួយនិយាយអំពីការសិក្សា : គ-ប- ដេមាដេក្កិ ទ.ក. ៩, ទំព័រ ៨; ឆ្នាំ ១៩៤១ (ម.៥២/១៣) ។

សេចក្តីអធិប្បាយពីវិធីសាងប្រាសាទនគរវត្ត : លោក ហ-ម៉ាក្រាស ទ.ក. ៤ ៥-៦, ទំព័រ ៧៥, ឆ្នាំ ១៩៣៦ (ម.៥២/៨) ។

សេចក្តីអធិប្បាយរបស់ជាតិហុល្លង់ដេស់ម្នាក់ អំពីការពឹងពាក់ប្រាស្រ័យនៅស្រុកខ្មែរ : ចីគិម-ហាក់ ទ.ក. ៤, ទំព័រ ៣, ឆ្នាំ ១៩៤០, (ម.៥២/១២) ។

សេចក្តីអធិប្បាយពន្យល់ជៀនវស្សា : ការប៊ុឡេស ទ.ក. ៧, ទំព័រ ៣, ឆ្នាំ ១៩២៧ (ម.៥២/៦) ។

សេចក្តីអធិប្បាយសង្ខេបអំពីបឋមសាសនៈ : អ្នកអង្គម្ចាស់វឌ្ឍនាយាវង្ស ទ.ក. ៣, ទំព័រ ៨៧, ឆ្នាំ ១៩២៦-២៧, (ម.៥២/១) ។

សេចក្តីអធិប្បាយអំពីថ្ងើមថ្ម ដែលឆ្លាក់ជារូបព្រះពុទ្ធបរិនិព្វាន : កាប៊ីឡេស ទ.ក. ៣, ទំព័រ ១៥, ឆ្នាំ ១៩២៧ (ម.៥២/២) ។

សេចក្ដីអធិប្បាយអំពីរូបបុរាណសុភាសិត : អ្នកអាចារ្យ
ផត-ប៊ុន ទ.ក. ៨, ទំព័រ ៤៤១, ឆ្នាំ ១៩៤៣,
(ម.៥២/១៥ ) ។

សេចក្ដីអធិប្បាយអំពីបុរាណវត្ថុ នៅជិតពិពិធភណ្ឌវត្ថុ
ពោធិកល : លោក ហ-ប៉ាម៉ង់ទៀរ និង លោក ក.ដាំលេត ទ.ក.
១-២-៣, ទំព័រ ១០៧, ឆ្នាំ១៩៣៦ (ម.៥២/៨) ។

សេចក្ដីអធិប្បាយអំពីរូបព្រះពោធិសត្វអវលោកិតេស្វរ
១ អង្គ នៅក្នុងព្រះបរមរាជវាំងក្រុងភ្នំពេញ : ការប៉ុ-
ឡេស ទ.ក. ៣, ទំព័រ ១, ឆ្នាំ ១៩៣០, (ម.៥២/៣)។

សេចក្ដីអធិប្បាយអំពីរូបសិវៈ ១ ដែលមានមុខ ៤
និងដៃ ៤ : ការប៉ឺឡេស ទ.ក. ២, ទំព័រ ១, ឆ្នាំ ១៩៣០
(ម.៥២/៣) ។

សេដ្ឋីឆាត់ (រឿងព្រេង) : ទ.ក. ៣, ទំព័រ ២៦,
ឆ្នាំ ១៩៤២ (ម.៥២/១៤) ។

សេរីភាព : លោក ផេង - ជ្រើ ទ.ក. ១២; ទំព័រ ១២៥២
ឆ្នាំ ១៩៦៣, (ម.៥២/៣៥) ។

សេះពលាហា (រឿង) : លោក វិកទ័រ-គោលូបេហ៍ ទ.ក.

៣-៦, ទំព័រ ៧៥, ឆ្នាំ ១៩៣១, (ម.៥២/៤) ។

សែងគ្រោចបេចចាចាស់ទុំ : ទ.ក. ១០-១១-១២, ទំព័រ ១២៣, ឆ្នាំ ១៩៣៩, (ម.៥២/១១) ។

សោវសោយ (រឿង) : ព្រះមហាឧត្តមវិជ្ជា ប៊ុន-ម៉ម ទ.ក. ៥, ទំព័រ ៣៥១, ឆ្នាំ ១៩៥៤ (ម.៥២/២៥) ។

សំបុត្ររបស់លោកឪពុកទៅបុត្រី : លោក ឈន-អៀម ទ.ក. ៦, ទំព័រ ៦៣៣, ឆ្នាំ ១៩៦៥

សំលៀកបំពាក់ខ្មែរ : ក្រុមជំនុំទំនៀមទម្លាប់ខ្មែរ ទ.ក. ៣, ទំព័រ ២២៤, ឆ្នាំ ១៩៥២, (ម.៥២/១៤) ។

សំភសកថា និយាយអំពីគូសំភស ៤ ពួក : មហាថែម ទ.ក. ៧-៨-៩, ទំព័រ ១៩៣, ឆ្នាំ ១៩៣៩, (ម.៥២/១១) ។

សំវេគកថា : លោក ស្រ៊ី-អ៊ូ ទ.ក. ១០, ទំព័រ ៨៩៧, ឆ្នាំ ១៩៤៧ (ម.៥២/២៩) ។

ស្កូប៉ែនហ៊ារ និង ព្រះពុទ្ធសាសនា : ទ.ក. ៧-៨-៩, ទំព័រ ៥, ឆ្នាំ ១៩៣៩, (ម.៥២/១១) ។

ស្តូបរបស់ព្រះចានជម្ពាសោក : លោក ប៉ូល-មុស ទ.ក.

៩, ទំព័រ ៣, ឆ្នាំ ១៩៤០, (ម.៥២/១២) ។

ស្តេចក្រុងចិន (រឿងព្រេង) : ទ.ក. ៤-៥-៦, ទំព័រ ១២៣, ឆ្នាំ ១៩៣៧, (ម.៥២/៩) ។

ស្តេចត្រី (រឿង) : លោក ផេង ជ្រីវ ទ.ក. ១១, ទំព័រ ៨.៣១, ឆ្នាំ ១៩៥១, (ម.៥២/២៣) ។

ស្តេចចាយស្ការ : លោក ញ៉ែម-ទឹម ទ.ក. ១២, ទំព័រ ១៣៨៦, ឆ្នាំ ១៩៦០ (ម.៥២/៣២) ។

ស្តេចឧទេន : ក្រុមការ ជុំ-មៅ ទ.ក. ៧-៨-៩, ទំព័រ ២៩, ឆ្នាំ ១៩៣៥, (ម.៥២/៧) ។

ស្ពានរបស់ព្រះគគក់ (តាមយោបល់របស់ហីនយាន-មហាយាន) : ទ.ក. ១៦, ទំព័រ ៧, ឆ្នាំ ១៩៤១, (ម.៥២/១៣) ។

ស្ទឹងគង្គាជាស្ទឹងសក្តិសិទ្ធិ : ទ.ក. ២២; ទំព័រ ៩, ឆ្នាំ ១៩៤១ (ម.៥២/១៣) ។

ស្នាដៃឥតុក : លោក ស៊ុន - ផូ ទ.ក. ៨, ទំព័រ ៩២០ ឆ្នាំ ១៩៦០, (ម.៥២/៣២) ។

ស្នេហាជាតិ (រឿង) : លោក គង់ - លិម ទ.ក. ១០,

ទំព័រ ៧៦៦, ឆ្នាំ ១៩៤៩, (ម.៥២/២៤) ។

ស្នេង (អំពី) : លោក ឆៃ-ឈុនអេង ទ.ក. ៥, ទំព័រ ៤៣, ឆ្នាំ ១៩៦៥, (ម.៥២/៣៧) ។

ស្រីត្កោកមាស (រឿងព្រេង) : ទ.ក. ១, ទំព័រ ៧៩, ឆ្នាំ ១៩៣៥ (ម.៥២/៧) ។

ស្រីគ្រប់លក្ខណ៍ : យុគ វីធី ទ.ក. ៨, ទំព័រ ៩២០; ឆ្នាំ ១៩៥៩ (ម.៥២/៣១) ។

ស្រីពីរនាក់ដណ្ដើមក្បូនគ្នា (រឿងព្រេង) : ទ.ក. ១, ទំព័រ ៤៩, ឆ្នាំ ១៩៤២ (ម.៥២/១៤) ។

ស្រីស្មោះត្រង់នឹងស្វាមី : ទ.ក. ១.។ - ១៨ ទំព័រ ៦២, ឆ្នាំ ១៩៤២, (ម.៥២/២៤) ។

ស្រុកកំពង់ធំពីដើម : ទ.ក. ៤ - ៥ - ៦, ទំព័រ ១១២, ឆ្នាំ ១៩៣៥, (ម.៥២/២៤) ។

ស្លាប់ព្រោះជាតិ (រឿង) : លោក គង់-លឹម ទ.ក. ១០, ទំព័រ ៧៦៦, ឆ្នាំ ១៩៤៩ (ម.៥២/២៤) ។

ស្វាលួចមកុដស្ដេច (រឿងព្រេង) : ទ.ក. ៤, ឆ្នាំ ១៩៤២, (ម.៥២/១៤) ។

ហង្សយន្ត : ទ.ក. ៦, ទំព័រ ៦៣៦, ឆ្នាំ ១៩៥៩,

(ម.៥២/៣១) ។

ហិតោបទេស : ក្រមការ ជុំ-មៅ ទ.ក. ១ - ៨ ទំព័រ ៨៦,

ឆ្នាំ ១៩៣៣, (ម.៥២/៥) ។

ហុល្លង់ដេស៍នៅស្រុកខ្មែរក្នុងសម័យលង្វែក : ទ.ក.

២៦, ទំព័រ ៩, ឆ្នាំ ១៩៦១, (ម.៥២/១៣) ។

ហេតុដូច ម្តេចបានជាព្រះពុទ្ធសាសនា ផុតរលត់ពី

ប្រទេសឥណ្ឌា : ខេមរវង្ស ទ.ក. ៣, ទំព័រ ១៩,

ឆ្នាំ ១៩៦០ (ម.៥២/១២) ។

ហោរាសាស្ត្រ និង ពុទ្ធសាសនា : ទ.ក. ៥, ទំព័រ ៣,

ឆ្នាំ ១៩៦០, (ម.៥២/១២) ។

ហ្មចាត : ម.វៀងហ្មចាត ។

ហ្លួងព្រះបាង ( ក្បួនហែព្រះរាជទ្រព្យ កំពុងហែចូល

ទៅវត្តបាណា ) : ទ.ក. ៧, ទំព័រ ១, ឆ្នាំ ១៩៦១,

(ម.៥២/១៣) ។

(នៅមានត)

# សេចក្ដីជូនដំណឹង

## អំពីលទ្ធផល នៃ ការប្រឡងប្រជែង ខាង ទំនៀមទម្លាប់ខ្មែរ

(ឆមាសទី ១ ឆ្នាំ ១៩៦៧)

ក្រុមជំនុំទំនៀមទម្លាប់ខ្មែរ នៅពុទ្ធសាសនបណ្ឌិត្យ ក្រុងភ្នំពេញ មានសេចក្ដីរីករាយនឹងផ្សាយដំណឹងចំពោះព្រះតេជព្រះគុណ អស់លោកអ្នក ជាសមាជិកឆ្លើយឆ្លង និង បេក្ខជនទូទៅថា : នៅក្នុងឆមាសទី ១ នៃឆ្នាំ ១៩៦៧ គឺពីខែមករាដល់ខែមិថុនា ១៩៦៧ នេះ ក្រុមជំនុំបានបើកការប្រឡងប្រជែងទំនៀមទម្លាប់ខ្មែរ ពីរមុខ គឺ :

១– អំពីគ្រឿងសាស្ត្រាវុធ

២– អំពីការបូជាសត្វសែនចំពោះវត្ថុស័ក្ដិសិទ្ធ

ដើម្បីប្រមូលឯកសារ មកតំកល់ទុក សម្រាប់ធ្វើជាគោលចារឹក នៃប្រពៃណីផ្នែកនេះ ទុកជាសម្បត្តិជាតិតរៀងទៅ ។ តាំងពីបានបើកឱកាសប្រឡងមក មានបេក្ខជនជាច្រើនទាំងព្រះសង្ឃ ទាំងគ្រហស្ថ ជាសមាជិកឆ្លើយឆ្លងខ្លះ ពុំមែនជាសមាជិកខ្លះ បានផ្ញើអត្ថបទមកចូលប្រឡងប្រជែង ។ ក្រុមជំនុំក៏បានប្រជុំពិនិត្យនូវវិញ្ញាសាទាំងនោះ យ៉ាងហ្មត់ចត់ ដោយបានសម្រេចជាលទ្ធផលដូចតទៅ :

## ក- ផ្នែកគ្រឿងសាស្ត្រាវុធ

រង្វាន់លេខ ១ : សហ. កំណាំ-គូ នៅសង្កាត់អង្គតាសោម ស្រុកត្រាំកក់ ខេត្តតាកែវ បានរង្វាន់ . . . ១០០០៛០០

រង្វាន់លេខ ២ : សហ. កែវ-កុល នៅភូមិព្រៃយោធ សង្កាត់អង្គតាសោម ស្រុកត្រាំកក់ ខេត្តតាកែវ បានរង្វាន់ . . . . . . . ៨០០៛០០

រង្វាន់លេខ ៣ : សហ. សេក សែត នៅសង្កាត់តាំងក្រសាំង ស្រុកសន្ទុក ខេត្តកំពង់ធំ បានរង្វាន់ . . . ៦ ០៛០០

រង្វាន់លេខ ៤ : សហ. យ៉េម-ត្រមម នៅការិយាល័យភូមិបាល ស្រុកបាទី ខេត្តតាកែវ បានរង្វាន់ . . . ៤០០៛០០

ព្រមទាំងអ្នកបានរង្វាន់លើកទឹកចិត្ត ៤ រូបទៀត គឺ :

- សហ. ម៉ម យី គ្រូបង្រៀននៅសាលាសុគន្ធបញ្ញា សង្កាត់ព្រែកស្ងួន ស្រុកកណ្ដាលស្ទឹង ខេត្តកណ្ដាល បានរង្វាន់ . . . . . . . ២០០៛០០
- សហ. កៅ យី នៅសង្កាត់បឹងត្រាញ់ ស្រុកសំរោង ខេត្តតាកែវ បានរង្វាន់ . . . . . . . ២០០៛០០
- សហ. សាន-ឌុយហៅ កែវសានឌី នៅសៀមរាបក្រុង ២០០៛
- សហ. ចាយ សេរី ធ្វើការនៅសាលាខេត្តពោធិ៍សាត់ បានរង្វាន់ — . . . . . . . ២០០៛០០

# ១- ផ្នែកបូជាសក្ការៈចំពោះវត្តសក្តិសិទ្ធិ

ដោយឯកសារស្តីពីផ្នែកទី ២ នេះ មានចំនួនតិចពេក ហើយសរសេរពុំសូវប្រកបដោយខ្លឹមសារច្បាស់លាស់ផងនោះ ក្រុមជំនុំសម្រេចជ្រើសបានល្អគួរសមតែពីរវិញ្ញាសា ដោយឲ្យជារង្វាន់លើកទឹកចិត្ត គឺ:

- ព្រះភិក្ខុ ផៃ ឈុន គង់នៅវត្តបទុមគង្គា សង្កាត់បាក់ខែង ស្រុកមុខកំពូល ខេត្តកណ្តាល បានរង្វាន់ ៣០០៛០០
- លោក អ៊ុំ-ឈុំ នៅសង្កាត់កុមាររាជា ស្រុកបាទី ខេត្តតាកែវ បានរង្វាន់. . . . . . ៣០០៛០០

រង្វាន់ទាំងនេះ ក្រុមជំនុំបានផ្ញើទៅជូនសាមីជន ក្នុងពេលយ៉ាងឆាប់ខាងមុខនេះ តាមរយៈប្រៃសណីយ៍ ។ ម្យ៉ាងទៀត នៅក្នុងឆមាសទី ២ នៃឆ្នាំ ១៩៦៧ នេះ ក្រុមជំនុំបានប្រកាសប្រឡងប្រជែង ២ មុខទៀត គឺ :

១- អំពីទេសចរខ្មែរបុរាណ

២- អំពីភាសាសាស្ត្របុរាណខ្មែរ

ក្រុមជំនុំទំនៀមទម្លាប់ខ្មែរ សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះព្រះតេជព្រះគុណ អស់លោក-អ្នក ដែលបានយកព្រះទ័យ យកចិត្តទុកដាក់ជួយរក្សាកេរ្តិ៍ដំណែលរបស់ជាតិដ៏ថ្លៃថ្លាទាំងនេះ ជាតិយោគាត ។

## ប្រកាសប្រឡងប្រជែងទំនៀមទម្លាប់ខ្មែរ

### ក្នុងឆមាសទី ២ ឆ្នាំ ១៩៦៧

នៅឆមាសទី ២ គឺតាំងពីខែកក្កដា ដល់ខែធ្នូ ឆ្នាំ ១៩៦៧ ក្រុមជំនុំទំនៀមទម្លាប់ខ្មែរ នៅពុទ្ធសាសនបណ្ឌិត្យ ក្រុងភ្នំពេញ ត្រូវការជ្រើសរើសយកឯកសារ ដោយបើកការប្រឡងប្រជែង ២ មុខគឺ :

១– អំពីជំនឿខ្មែរបុរាណ

២– អំពីភាសាសាស្ត្របុរាណខ្មែរ

*ដូច្នេះ អស់លោក អ្នកចេះដឹងទាំងឡាយ ជាស្ត្រី ជាបុរស ឬ បព្វជិតក្តី ដែលស្ម័គ្រចិត្តប្រឡង សូមសរសេរតែងអត្ថបទ តាមគោលបញ្ហាដូចរៀបរាប់ខាងមុខ ហើយសរសេរ* ឲ្យការណ៍ទៅក្រុមជំនុំទំនៀមទម្លាប់ខ្មែរ នៅពុទ្ធសាសនបណ្ឌិត្យ យ៉ាងយូរបំផុតត្រឹមថ្ងៃដាច់ខែវិច្ឆិកា ឆ្នាំ ១៩៦៧ ។

ការប្រឡងប្រជែងនេះ មានរង្វាន់ ៤ ថ្នាក់ :

| | |
|---|---|
| លេខ ១ . . . ១០០០៛០០ | លេខ ៣ . . . ៦០០៛០០ |
| លេខ ២ . . . ៨០០៛០០ | លេខ ៤ . . . ៤០០៛០០ |

បើអស់លោក-អ្នកត្រូវការសរសេរអត្ថបទ ដូចខាងលើនេះ ទៅដាក់ប្រឡង សូមសរសេរលើសៀវភៅ កុំសរសេរលើក្រដាសតែ ១ សន្លឹក ឬ ២ សន្លឹកឡើយ ហើយសូមសរសេរនាម និងទីលំនៅរបស់ខ្លួន ឲ្យច្បាស់លាស់លើក្រដាស ១ សន្លឹកដោយឡែក ដាក់ក្នុងស្រោមជាមួយនឹងអត្ថបទនោះ យកទៅឲ្យក្រុមជំនុំផ្ទាល់ខ្លួនក៏បាន ផ្ញើទៅតាមប្រៃសណីយ៍ក៏បាន ដោយការខ្ទង់សំបុត្រថា :

ពុទ្ធសាសនបណ្ឌិត្យ
ការិយាល័យទំនៀមទម្លាប់ - ភ្នំពេញ

## គោលបញ្ហានៃការប្រឡង

## ១. អំពីឱសថខ្មែរបុរាណ

ដែលហៅថា « ឱសថខ្មែរបុរាណ » គឺយើងសំដៅយកថ្នាំគ្រប់បែប ដែលតម្រាបុរាណខ្មែរយើងបានកំណត់ឲ្យផ្សំដោយស្លឹកឈើ, ដើមឈើ, មើមឈើ, ឫស ស្បែក ស្លាបសត្វ ឬ វត្ថុដទៃ ៗ ទៀត ជាដើម ។ ជួនកាល គ្រឿងផ្សំថ្នាំខ្មែរយើង ចេះចាំដោយ ត ៗ គ្នាមកក៏មាន ដូច្នេះសូមសរសេររៀបរាប់អំពីឱសថទាំងនោះ យ៉ាងតិចណាស់ ក៏ឲ្យបាន ឱសថ ៥ មុខ ដែរ ហើយសូមសរសេរ

រាប់រៀបឲ្យត្រូវតាមសំនួរហូរហែខាងក្រោម បើប្រសិនត្រង់ចំណុចណាពុំបានដឹង ក៏សូមរំលង ទៅចុះ :

### ក_ ឈ្មោះឱសថ

- តើឱសថនេះឈ្មោះអ្វី? ឈ្មោះនេះគេហៅតាមឈ្មោះពេក ឬ តាមឈ្មោះរបៀបប្រើ? នរណាជាអ្នករកឃើញ បង្កើតឱសថនេះឡើង បើស្គាល់ឈ្មោះ ឬ ប្រវត្តិដើមយ៉ាងណា ក៏សូមប្រាប់មកផង ។

### ខ- អំពីគ្រឿងផ្សំ

- តើមានអ្វីខ្លះជាគ្រឿងផ្សំ សូមរាប់ឈ្មោះវត្ថុសំរាប់ផ្សំនោះ ឲ្យបានគ្រប់ឈ្មោះ ។ ចំពោះរុក្ខជាតិ ឬ ធម្មជាតិអ្វីមួយដែលត្រូវយកមកផ្សំនោះ សូមប្រាប់ពីរូបរាងនិងភាគរបស់វា ទីកន្លែងដែលមានរបស់ទាំងនោះផង ។

- ក្នុងការស្វែងរកគ្រឿងផ្សំទាំងនោះ តើគេមានប្រកាន់ត្រណម ឬ និយមតាមទំនៀមបែបណាខ្លះ សូមរាប់រៀបពីត្រណមនិងទំនៀមនោះឲ្យច្បាស់លាស់ ទាំងរបៀបធ្វើ ទាំងគ្រឿងប្រដាប់ដែលប្រើក្នុងពេលរកវត្ថុនោះ ។

### គ -អំពីវិធីផ្សំ

- សូមរាប់រៀបពីរបៀបកាប់ចិញ្ច្រាំ ឬ ចិត ឬ កោសគ្រឿងផ្សំនោះ មួយមុខម្ដង ៗ ។

- ការផ្សំ សូមនិយាយបញ្ជាក់ពីចំនួនដោយប៉ាន់ចំហ៊ុំ ឬកំណត់តាមក្លុកជញ្ជីង នូវគ្រឿងផ្សំទាំងនោះមួយម្តង ៗ ។

- របៀបបញ្ចូលគ្នានេះ, តើគេបញ្ចូលដោយបុកឲ្យល្អិតលាយគ្នា ឬ កាប់ឲ្យតូច ៗ ដាក់ក្នុងឆ្នាំង ក្នុងដបជាមួយគ្នា ឬ មួយគោស យកកំទេចច្របល់គ្នា ហើយគេត្រូវយកទៅស្ងោរ, ត្រាំស្រា, ដុតយកចំហាយ ឬ មូរជក់ជាបារី ។ល។ ក៏សូមពន្យល់ឲ្យច្បាស់លាស់ អំពីរបៀបផ្សំថ្នាំនោះ ។

- ក្នុងពេលផ្សំ មានត្រូវសូត្រមន្តអាគមគាថាយ៉ាងណាដែរ ? បើមានក៏សូមប្រាប់ផង ឬ បើមានធ្វើអ្វីផ្សេងទៀតតាមជំនឿក៏សូមកប់រៀបផងដែរ ដូចមានបាយសិង្សាដក់ជាដើម ។

ឃ - វិធីប្រើ ឱសថនេះត្រូវប្រើតាមវិធីណា ដូចជាត្រូវផឹក, ត្រូវលេប, ត្រូវហាល-ធូង, លាប, ត្រាំងូត ឬ ធ្វើបែបណា ៗ សូមបញ្ជាក់របៀបប្រើនោះ និង សូមប្រាប់ពីកំណត់ដែលត្រូវប្រើនោះផង ដូចជាត្រូវប្រើប៉ុន្មានដងក្នុង ១ ថ្ងៃ ជាដើម ។

ង- ត្រណមផ្សេង ៗ

- ក្នុងពេលដែលប្រើឱសថនោះ មានកាន់ត្រណមដូចម្តេចខ្លះ ? (ដូចជា គេមិនឲ្យបរិភោគអ្វីខ្លះ កាន់កិរិយាបែបណា អស់រយៈពេលប៉ុន្មានទើបផុត) ។

- តើរៀបរណ្តាប់ថ្វាយគ្រូ ឬ គ្រាស់គ្រូដូចម្តេច មានអ្វីខ្លះ? ។

## ២ អំពីភាសាសាស្ត្របុរាណខ្មែរ

សូមបញ្ជាក់ថា " ភាសាសាស្ត្រ " ក្នុងទីនេះ សំដៅយក លំនាំបែបបទនៃពាក្យសំដីដែលយើងប្រើប្រាស់ ឬ ថាទំនុកទំនើបបែបផែន ឬ វិជ្ជា ដែលវេទនាភាសា ពោលគឺពាក្យសំដី ដែលយើងនិយាយ ស្តីប្រស្រ័យគ្នា ឲ្យដឹង ឲ្យយល់ថា ដូច្នេះដូច្នោះនេះឯង ។ ព្រោះ ថា ទោះបីជាជាតិតែមួយ ប្រទេសតែមួយ ក៏គង់តែមានរបៀបនិយាយ ស្តី ប្រើពាក្យពេចន៍ និង ការឲ្យន័យ ឬ សំនួនវោហារ ដោយឡែក ៗ ពីគ្នា អាចឲ្យសំគាល់បានថា នេះជាសំដីអ្នកស្រុកនេះ នេះជាសំដី អ្នកស្រុកនោះ ឬថា អ្នកនេះ ជាអ្នកមានកំណើតដើម ពីសញ្ជាតិណា ៗ ជាដើម ។

ដើម្បីឲ្យឆាយក្នុងការសរសេរពន្យល់ទៅក្រុមជំនុំវិញ សូមលោក អ្នកពិនិត្យតាមសំនួរហូរហែ ខាងក្រោមនេះ ៖

### ក- អំពីសូរសំនៀងនៃការប្រើពាក្យសំដី

តាមធម្មតា អ្នកស្រុក អាន ឬ និយាយចេញជាពាក្យសំដីមិនមែន មានសូរសំនៀងដូចគ្នាទេ តែងតែល្អៀងពីគ្នាបន្តិច ៗ ឬ សឹងតែស្តាប់ គ្នាពុំបានសោះក៏មាន ហេតុនេះ សូមពន្យល់ថា :

– តើសំដីភាសាអ្នកស្រុកណា ដែលលោក-អ្នកសរសេរនោះ មានសំឡេងទន់, ថ្នម, យារវែង ឬក៏ រឹង, កញ្ចក់ ៗ, កំបុត ៗ

សូមឲ្យឧទាហរណ៍ជាសំដីមួយឃ្លា ឬ ច្រើនឃ្លា ដើម្បីបង្ហាញឲ្យឃើញ ជាសភាពភាសាតាមភូមិតាមស្រុក ។

— បើប្រសិនជាអាចធ្វើជាតារាងមួយប្រៀបធៀបសំឡេង គាន ពាក្យមួយម៉ាត់ៗ ដែលប្លែកគ្នាបាន ក៏សូមធ្វើតាមទំនងគំរូ តារាងខាងក្រោមនេះ :

| ឈ្មោះភូមិភាគ | សំឡេងអ្នកភ្នំពេញ | សំឡេងអ្នកភូមិភាគ | សេចក្ដីសង្កេត |
|---|---|---|---|
| | | | |

ខ - អំពីន័យរបស់ពាក្យ ឬ ការប្រើពាក្យប្លែកគ្នា

ប្រទេសខ្មែរយើង គ្មានគ្រាមភាសា(Dialecte) ទេ, យើង មានតែពាក្យប្លែកគ្នាខ្លះៗ តាមភូមិភាគតែប៉ុណ្ណោះគឺ ជាជួនកាលរបស់តែមួយ តែអ្នកស្រុកហៅឈ្មោះផ្សេងពីគ្នា ដូចជាកាពិ អ្នកកំពតហៅគី, ក្រមាអ្នកបាត់ដំបងហៅកន្សែង, ចានស្រាក់អ្នកកំពង់ចាមហៅកាតូ ។ល។ ជួនកាលផ្ទុយពីនេះទៅវិញ គឺពាក្យតែមួយសោះ ហើយអ្នកស្រុកឲ្យន័យប្លែកគ្នាដូចពាក្យ រនែង (ក្រែងខ្លាច) អ្នកបាត់ដំបងថាឧស្សាហ៍; សោ អ្នកសៀមរាប អ្នកបាត់ដំបងឲ្យន័យថា ហត់នឿយ, អាក្រក់ ។ល។

បើគេឃើញច្រើនក៏សូមធ្វើជាតារាងមួយដែរ ។

## គ– ដើមកំណើតពាក្យ

ពាក្យនីមួយៗ សុទ្ធតែមានដើមកំណើតចេញមកពីប្រភពផ្សេងៗ ប៉ុន្តែយើងលើកយកមកក្នុងពេលនេះ តែចំពោះពាក្យដែលមានដើមកំណើតពីមនុស្សដើមដែលធ្លាប់រស់នៅលើស្រុកយើងតែប៉ុណ្ណោះ ដូចជាពួកកុលសម្ព័ន្ធ ព្នង, ស្ទៀង, កួយ, ស្អូច, ព័រ ជាដើម តើមានពាក្យណាខ្លះក្លាយមកពីភាសាអ្នកអស់នោះ សូមធ្វើជាបញ្ជីមួយ រាយពាក្យទាំងនោះ ហើយប្រាប់ថាក្លាយពីកុលសម្ព័ន្ធណា? សព្វថ្ងៃគេមានដូចម្តេចៗ ផងៗ

ចំណែកពាក្យខ្លះដែលទាក់ទងពីភាសាជាតិនានាដូចជា មន ម៉ាឡាយូ ជ្វា លាវ ។ល។ ដែលធ្លាប់ទាក់ទងយើងពីបុរាណកាល ក៏សូមរាប់រៀបផងដែរ (ចំពោះកំណើតពាក្យពីភាសាបាលី–សំស្ក្រឹតពុំបាច់និយាយទេ)។

សេចក្តីបញ្ជាក់– អត្ថបទដែលបេក្ខជនសរសេរទៅដាក់ប្រឡង ទោះជាប់ក្តី មិនជាប់ក្តី ត្រូវទុកជាសម្បត្តិរបស់ក្រសួងតទៅ មិនបង្វិលឲ្យសាមីខ្លួនវិញទេ ។

សូមផ្ញើរូបថតសាមីខ្លួនលោក-អ្នកដែលសរសេរអត្ថបទប្រឡង បីសន្លឹកមកជាមួយផង គឺរូបមួយកំណាត់ខ្លួន ទំហំ ៤×៦ លើកលែងតែរបស់លោកណាដែលបានផ្ញើពីលើកមុនរួចមកហើយ ។

ក្រុមជំនុំទំនៀមទម្លាប់ខ្មែរ

# ផ្នែកកំណត់ និង ប្រវត្តិការណ៍

យើងបានទទួលដំណឹងថា សម្ដេចសហជីវិនព្រះប្រមុខរដ្ឋ ទ្រង់បានថ្វាយសៀវភៅ ព្រះរាជសុន្ទរកថា ក្នុងឱកាសថ្វាយសញ្ញាប័ត្រ បណ្ឌិតអក្សរសាស្ត្រ, ចំពោះសម្ដេចព្រះសង្ឃរាជ គណៈមហានិកាយ ចំនួន ៣០១ ច្បាប់ ។ ក្រោយដែលទ្រង់បានទទួលហើយ សម្ដេចព្រះសង្ឃរាជជាអម្ចាស់ ទ្រង់ថ្លែងព្រះបុគហ្ញាយ ថ្លែងអំណរព្រះមហាករុណាធិគុណ និង ព្រះពរសិរីមង្គល ថ្វាយចំពោះ សម្ដេចព្រះប្រមុខរដ្ឋ វិញ ដូចមានសេចក្ដីទាំងស្រុងតទៅនេះ ...

## ព្រះរាជាណាចក្រកម្ពុជា

ក្រសួងព្រះសង្ឃរាជគណៈមហានិកាយ

វត្តឧណ្ណាលោម ក្រុងភ្នំពេញ

សូមថ្វាយព្រះពរ សម្ដេចព្រះប្រមុខរដ្ឋ ព្រះបិតាអក្សរសាស្ត្រជាតិ ជាទីគោរពដ៏ខ្ពង់ខ្ពស់បំផុតនៃអាត្មាភាព

សូមទ្រង់ជ្រាប ។

នៅថ្ងៃទី ៦ កក្កដា ១៩៦៧ នេះ អាត្មាភាពបានទទួលអំពីលោក អ៊ុក-ម៉ូត អនុរដ្ឋលេខាធិការក្រសួងធម្មការ ជាព្រះរាជបំរើនៃព្រះអង្គ នូវសៀវភៅព្រះរាជសុន្ទរកថា នៃសម្ដេចជាអម្ចាស់ចំនួន ៣០០ ច្បាប់ ជា ៣០១ ច្បាប់ទាំងសៀវភៅដែលនេះ ដែលចងក្រងពិសេស មាន ព្រះរាជចំណារ និង ព្រះហស្តលេខា ជាអនុស្សាវរីយ ទៅក្នុងអនាគត ពុំអាចជនណាទាំងកេ្តចក្តាំង ។ អាត្មាភាពសូមទទួលដោយគោរពយ៉ាង --

ខ្ពង់ខ្ពស់ក្រៃលែង ទូវព្រះរាជអំណោយដ៏ចំឡែកនេះ ហើយនឹងចែកសៀវភៅនោះដល់ភិក្ខុសង្ឃ និង គ្រហស្ថដែលគួរចែក ដើម្បីរក្សាទុកជាអនុស្សរណៈជាទីរលឹក និង ជាទិដ្ឋានុគតិ គឺជាតម្រាប់ឲ្យកុលបុត្រកុលធីតាជាកូនចៅទាំងឡាយ ពេញចិត្តចំពោះអក្សរសាស្ត្រជាតិតរៀងទៅ ។

សូមថ្វាយព្រះពរ

តាំងពីក្រោយដែលសម្តេចជាអម្ចាស់ ទ្រង់ព្រះមេត្តាប្រោសព្រះរាជទាន សញ្ញាបត្របណ្ឌិតខាងអក្សរសាស្ត្រខ្មែរ ដល់អាត្មាភាពនោះ រៀងរហូតមកដល់សព្វថ្ងៃនេះ វចនានុក្រមខ្មែរទាំង ២ ភាគ ក៏ហាក់ដូចជាមានព្រលឹងព្រលះជាងពីដើមច្រើនណាស់ ដោយសារព្រះតេជៈដ៏ខ្ពង់ខ្ពស់បំផុតនៃសម្តេចជាអម្ចាស់ ។ អាត្មាភាព មានអំណរច្រើនណាស់ ចំពោះព្រះមហាករុណាធិគុណដ៏លើសលន់ពន់ប្រមាណនេះ ។ ព្រះរាជយោបល់ដ៏ជ្រាលជ្រៅពុំអាចនឹងស្ទង់បាន និង ព្រះរាជសុន្ទរកថាដែលទ្រង់ព្រះមេត្តាប្រោសឲ្យបោះពុម្ពជាអក្សរខ្មែរ និងអក្សរបារាំងផ្សាយនេះ ជាឱសថទិព្វពូកែផុតឆាប់ ញុំាំងអក្សរសាស្ត្រខ្មែរ ដែលមានកំឡាំងខ្សោយ ឲ្យមានកម្លាំងរឹងប៉ឹងឡើង ញុំាំងវចនានុក្រមខ្មែរ ដែលស្គមកំព្រឹងកំព្រយ ទទួលព្រះរាជទានដំណក់ជ្រលៀក ដូចជាសន្ទប់នោះ ឲ្យមានស្មារតី និងកម្លាំងក្រោកឡើង ឲ្យមានសាច់ មានឈាម មានព្រលឹងរឹងប៉ឹងអាចស្ទុះស្ទាពេញទំហឹងបាន ។

ដែលអាត្មាភាពមានអំណរដ៏គប់ប្រសិរណានា ចំពោះព្រះមហាករុណាធិគុណនេះ គឺដោយហេតុដូចបានថ្វាយព្រះពរដោយសង្ខេបខាងលើនេះ ដែលកម្រនឹងបានជួបប្រទះ ពោះបីរកប៉ុកដល់កកជ្យដ៏យូរ ក៏កម្រនឹងបានជួប ដូចក្នុងសម័យសម្តេចព្រះប្រមុខរដ្ឋ ជាអម្ចាស់នេះឡើយ ។ ដែលអាត្មាភាពថ្វាយព្រះពរនេះ ដោយសុទ្ធចិត្តពិតត្រង់ ពុំមែនដោយបេះតែបញ្ជោរលើកព្រះបាទាព្រះអង្គឡើយ ។

អាត្មាភាពសូមថ្វាយព្រះពរ សូមព្រះអង្គទ្រង់ប្រកបដោយព្រះមហាតេជះឈ្នះអស់មារសត្រូវ គ្រប់ទិសទី គ្រប់កាលវេលា សូមព្រះអង្គមានព្រះសុខភាពដ៏បរិបូណ៌ជានិច្ច សូមព្រះអង្គមានព្រះជន្មាយុយឺនយូរដ៏ឆ្ងាយក្រៃលែងជាងរយវស្សា ។

គួរពុំគួរ សូមទ្រង់ព្រះករុណាប្រោស

សូមថ្វាយព្រះពរ នៅថ្ងៃទី ៧ កក្កដា ១៩៦៧

អាត្មាភាព

សម្តេចព្រះសង្ឃរាជ

គណៈមហានិកាយ

( ព្រះហស្តលេខា : ) ជួន-ណាត

# ព្រះរាជសុន្ទរកថានៃសម្ដេចព្រះប្រមុខរដ្ឋ
# ក្នុងឱកាសពិធីថ្វាយសញ្ញាប័ត្របណ្ឌិតខាងអក្សរសាស្ត្រ
# បំពោះសម្ដេចព្រះសង្ឃរាជ ថ្នាក់ទី ១

## ជួន-ណាត

*សម្ដេចជាអម្ចាស់ ជាទីសក្ការៈ*

*ព្រះថេរានុថេរៈ ជាទីគោរព*

*ឯកឧត្ដម - អស់លោក*

*ជនរួមជាតិជាទីស្នេហា*

*ទូលព្រះបង្គំ ខ្ញុំព្រះករុណា ខ្ញុំ មានបីតិសោមនស្សណាស់ ដោយបានមកជាអធិបតីក្នុងពិធីដ៏មហោឡារិកនេះ ។ មានសេចក្ដីរីករាយសប្បាយជាខ្លាំង ចំពោះភូមិន្ទសកលវិទ្យាល័យយើង ដែលបានសម្រេចលើកតម្កល់ព្រះអង្គសម្ដេចព្រះសង្ឃរាជ ជាឋានៈអ្នកប្រាជ្ញទី ១ របស់យើងផ្នែកខាងអក្សរសាស្ត្រខ្មែរ ។ ទូលព្រះបង្គំ – ខ្ញុំព្រះករុណា ខ្ញុំ សូមសរសើរ ហើយថ្លែងអំណរគុណលោកសកលវិទ្យាធិការ លោកមហាវិទ្យាធិការ និង សាស្ត្រាចារ្យទាំងអស់ ដែលបានសម្រេចថ្វាយព្រះកិត្តិយស និងគារវកិច្ច ចំពោះសម្ដេចព្រះសង្ឃរាជជាអម្ចាស់ ដែលព្រះអង្គមានព្រះកិត្តិនាមល្បីល្បាញតាំងពីយូរមកហើយ គឺសម្ដេចព្រះ*

សង្ឃរាជព្រះអង្គមានទាទីផ្ទាប់គេក្នុងវិស័យចំណេះវិជ្ជា និងស្នាព្រះហស្ត ៗ គឺដោយសារសម្តេចនេះហើយ ទើបអក្សរសាស្ត្រយើងមានទម្រង់ទាន់សម័យ ៗ ព្រះអង្គទ្រង់បានកំណត់ក្បួនវេយ្យាករណ៍ខ្មែរ ឲ្យត្រឹមត្រូវ ទាំងខាងពាក្យសម្ពន្ធ ដ៏ដូចជាខាងការអានឲ្យច្បាស់លាស់ ៗ ហើយចំណែកខាងស្នាព្រះហស្តព្រះអង្គផ្នែកគរុកោសល្យ និង អក្សរសាស្ត្រ ក៏មានសារប្រយោជន៍លេខ ១ ៗ គឺព្រះអង្គសម្តេចព្រះសង្ឃរាជនេះហើយ ដែលជាឫសគល់នៃវឌ្ឍនភាពរបស់ភាសាខ្មែរ ដែលឥឡូវសម្បូណ៌ទៅដោយពាក្យពេចន៍ប្រើប្រាស់ ប្រកបទៅតាមការចាំបាច់នៃសម័យថ្មី ៗ សម្តេចព្រះអង្គបានជួយស្រោចស្រង់ភាសាខ្មែរយើងឲ្យចៀសវាងបាននូវការតាំងដំណើររបស់ភាសាបុរាណជាច្រើន ៗ ដូច្នេះព្រះឋានៈជាមហាបណ្ឌិតខាងអក្សរសាស្ត្រ ដែលបានប្រគល់ថ្វាយក្នុងពេលនេះ គឺជាសក្ខីភាព នៃកតញ្ញូតាធម៌ ចំពោះព្រះអង្គ ក្នុងវិស័យពហុវិជ្ជា ៗ គឺព្រះអង្គមានចំពោះជាតិមាតុភូមិ នូវមហាគុណូបការដែលគ្មាននរណាប្រកែកកើត ៗ

អក្សរសាស្ត្រខ្មែរ ផ្នែកទូទៅហើយនិងផ្នែកសាសនា ផុសឡើងវិញហើយ អំពីរាត្រីកាលដ៏អាប់អួរមួយ ដ៏យូរលង់ៗការលួចប្លន់និងដុតបំផ្លាញរាជធានីអង្គរ ដែលសៀមបានធ្វើ ជាហេតុមួយបណ្តាលឲ្យខ្មែរបានកើតប្រទះនូវមហន្តរាយ ដែលមានទំហំធំលើសមហន្តរាយនៃអារ្យប្រទេសជាតិដទៃក្នុងប្រវត្តិសាស្ត្រ ៗ កង់ទំពណ្ណានពាន រាបានភគត្បាតតាំងពីន

ប្រទេសខ្មែរស៊ីវិល័យ ហើយក៏បានបំផ្លាញគ្រប់បែបយ៉ាង នូវសៀវភៅ និងក្បួនខ្នាត ដែលបុព្វបុរសយើង បានតាក់តែងយ៉ាងអំណត់ មកតាំងពីច្រើនសតវត្សហើយៗឯកសារទាំងនេះគឺជាឃ្លាំងនៃប្រវត្តិសាស្ត្រ, អក្សរសាស្ត្រ និង វិទ្យាសាស្ត្រ ។ ពួកប្លន់ទឹកដីនៃខ្មែរក្នុងសម័យនោះ ក៏ជាអនក្ខរជន ក៏ប្រណែនយ៉ាងខ្លាំង ចំពោះជាតិអកសន់ខ្មែរ ក៏ខឹងសម្បារនឹងការលូតលាស់ចំរើននៃអារ្យធម៌ខ្មែរយើង ។

ប្រាកដណាស់ សៀមក៏ដណ្តើមប្លន់យកអស់ទាំងអ្វីដែលជាតម្លៃរបស់ជាតិយើង ក៏ចម្លងលក្ខណៈអក្សរយើង ក៏ផ្ដិតយកបែបរដ្ឋបាលសម័យអង្គរយើង ហើយក៏បំផ្លែងនូវសំណល់រឿងឯកសារនៃអក្សរសាស្ត្រយើងដែលមិនទេះរលាយ ធ្វើទៅជារបស់ក៏ ។ ស្របជាមួយនឹងការណ៍នេះ ហើយរហូតមកដល់សតវត្សទី ១៧ សៀមបានដុតបំផ្លាញនូវបណ្ណាល័យដែលបានរៀបចំវិញខ្លះក្នុងសម័យលង្វែកទៅទល់នឹងសម័យឧដុង្គ ។សៀមក៏មានបំណងផ្ដាច់ខ្មែរអំពីអតីតកាលដ៏ថ្កើងរុងរឿងនៃខ្លួន ។ យើងអាចរក្សាទុកបាននូវអារ្យធម៌ខ្មែរក្នុងសម័យដើមនោះ ដោយសារតែសិលាចារឹកនៅលើផ្ទៃថ្ម ហើយនិងការចេះចម្លងក្បួនតម្រាតៗគ្នា ដោយមាត់ទទេ ។

បន្តពីសៀមមក ពួកយួនបានចិត្តធ្វើបាបខ្មែរ ប៉ុន្តែ ក៏ពុំអាចបញ្ចូលបាននូវវប្បធម៌របស់ក៏ មកក្នុងប្រទេសយើងឡើយ ។ រហូតមកដល់សតវត្សទី ១៩ កដបល្ល័ក្តដែលជាអគ្គការការពារ ហើយលើកទឹកចិត្តជួយ

សិល្បៈ និង អក្សរសាស្ត្រ, ទស្សនវិជ្ជា និងសាសនាជាទិច្ចរៀនមក ត្រូវ តើបប្រវះនូវអតីតគ្រប់បែបយ៉ាង ដែលធ្វើឲ្យអស់នូវលទ្ធភាព ឧបត្ថម្ភ វប្បធម៌ជាតិ ដោយខ្លួនរវល់តែផ្លាស់កន្លែងពីនេះទៅនោះ ។ ក្នុងគ្រា ដ៏លំបាកនោះ ខ្មែរយើងខ្វះនូវអ្នកកត់ត្រាប្រវត្តិសាស្ត្រកវី-អ្នកនិពន្ធ ដើម្បី សរសេរទុកឲ្យបានគង់វង្សនូវរឿងរ៉ាវ ឬនូវចម្រៀង ដែលបង្ហាញអំពីវិភាព របស់ខ្មែរក្នុងសម័យរង់ទុក្ខវេទនា ។ រីឯព្រះពុទ្ធសាសនាយើង ក៏ត្រូវចុះអន់ ថយ ហើយមាននិវត្តន៍ទៅតាមជំនឿឆ្វេង ជំនឿក្រៅសាសនា ដែល ផ្ទុយអំពីទ្រឹស្តីបរិសុទ្ធ នៃព្រះបរមគ្រូ ។ ការប៉ុនប៉ងរៀបចំទម្រង់ថ្មីឡើង វិញ ចាប់ផ្តើមនៅក្នុងរជ្ជកាលនៃព្រះករុណាព្រះបាទសម្តេចព្រះហរិរក្ស-រាមាធិបតីព្រះអង្គឌួង ។ ប៉ុន្តែ ចំបាំងថ្មីទៀតជាមួយសៀម និង យួន នាំឲ្យរំខានដល់ការខិតខំផ្តួចផ្តើមនេះ ។

អាណាព្យាបាលបារាំងសែស បាននាំមកឲ្យយើង នូវសន្តិភាព និង ស្ថិរភាពខ្លះដែរ ។ ប៉ុន្តែ ពួកអាណាព្យាបាលនេះ គេគ្មានផលប្រយោជន៍អ្វី នឹងរៀបចំនូវវប្បធម៌ជាតិរបស់យើងឡើយ ។ ជាកុសល សម័យនោះ មានអ្នកស្នេហាជាតិយើងមួយក្រុម បេះដូងរួមគ្នាសម្រេចចិត្តពញាក់ស្មារតី ជាតិឲ្យភ្ញាក់រឭក គិតទៅដល់ការចុះអន់ថយនៃអក្សរសាស្ត្រ និងដល់ តម្លៃនៃសាសនាយើង ។ ក្នុងចំណោមវរជនទាំងនោះ មានព្រះរាជ អយ្យកោខាងបិតារបស់ទូលព្រះបង្គំ-ខ្ញុំ គឺសម្តេចវរចក្រណារិទ្ធិសុទ្ធារស

ដែលព្រះអង្គត្រូវអាក់ខានបានសោយរាជសម្បត្តិ ព្រោះតែអាណានិគមបារាំង មិនសប្បាយចិត្តនឹងសកម្មភាពរបស់ព្រះអង្គ ដែលជាអ្នកការពារឧត្តមប្រយោជន៍ និង កិត្តិយសជាតិ ។

ក្នុងសម័យនោះ សម្តេច ជួន-ណាត និង ហួត-តាត ព្រះអង្គមានយុវភាពនៅឡើយ ។ ប៉ុន្តែព្រះអង្គមានសមត្ថភាពពេញទីដើរជួរមុខនៃចលនាស្រោចស្រង់និងលើកតម្កើងវប្បធម៌ជាតិ ដើម្បីបើកនិងត្រាយផ្លូវនៃការលូតលាស់ចំរើន ដ៏ពិតប្រាកដ នៃបុនភព(renaissance) របស់វប្បធម៌ខ្មែរ ដែលបន្តដំណើរជានិច្ចមកដល់សព្វថ្ងៃនេះ ។ មុខការដែលត្រូវបំពេញមានទំហំធំធេងណាស់ ។ បណ្ឌិតសន្និបាតមួយប្រកបដោយអ្នកប្រាជ្ញមានសទ្ធាជ្រះថ្លាដ៏ឧត្តម មានចិត្តក្លាហាន ធ្វើការយ៉ាងសកម្ម ហើយតាមរបៀបបែបផែនវិទ្យាសាស្ត្រនិងបច្ចេកទេសផង បានពុះពារនឹងមុខការនេះ ។ ព្រះអង្គខ្លះ ដូចជាព្រះអយ្យកោទូលព្រះបង្គំខ្ញុំ សម្តេចល្វី-ឯម និងអ្នកប្រាជ្ញច្រើនទៀត បានអនិច្ចកម្មទៅ កំពុងបំពេញសកម្មភាព ។ សព្វថ្ងៃនេះ ក្រុមអ្នកប្រាជ្ញជំនាន់នោះ ពិសេស គឺសម្តេច ជួន-ណាត និង ហួត-តាត ព្រះអង្គនៅតែបន្តការនេះគ្មានអាក់រេ ព្រះអង្គយាងត្រង់តាមមាគ៌ាដែលបានដៅទុកមក ។

វឌ្ឍនភាពយ៉ាងធំមួយ បានសំរេចហើយ ក្នុងការសំរិតសំរាំងពាក្យដែលត្រូវខ្ចីឬត្រូវប្រែមកពីបរទេស ហើយក្នុងការសំដែងស្វែងរកឲ្យបាន

ត្រឹមត្រូវតាមព្រះធម៌ និងព្រះវិន័យរបស់ព្រះពុទ្ធជាម្ចាស់ ។ ក្នុងករណីនេះ គួរសរសើរចំពោះការបកប្រែ ការបោះពុម្ពនិងការផ្សាយព្រះត្រៃបិដកដែលមានដំណើរជឿនលឿនទៅមុខយ៉ាងទៀងទាត់ឥតខ្ចោះ ។ អ្នកខ្លះនិយាយខុសទាំងស្រុងថា នៅក្នុងសាសនាយើង មានធម៌ថ្មី-ធម៌ចាស់ ។ តាមការពិត យើងពុំមានធម៌ពីរទេ ។ មានតែមួយគត់ ។ ដែលនិយាយថាធម៌ថ្មីនោះ គឺការដែលចង់សំអិតសំអាងព្រះសាសនាឲ្យផុតអំពីជំនឿខុស អំពីការយល់ហួសហេតុផល និងអំពីទម្លាប់ខុស គឺពុំមែនធ្វើឲ្យពុទ្ធសាសនាទៅជាបែបថ្មីទេ ។ ការពិត គឺធ្វើឲ្យព្រះសាសនាត្រឡប់ទៅរកប្រភពដើម ដ៏ត្រឹមត្រូវល្អវិញតែប៉ុណ្ណោះ ។

o × o

ជាមួយនឹងឯកភាពជាតិ ភាសាជាតិត្រូវមាននាទីដ៏ធំ ហើយបំពេញមុខងារដ៏ខ្ពង់ខ្ពស់ ។ ខ្មែរយើងក៏បានរៀបចំភាសាជាតិឲ្យទៅជាឧបករណ៍សំរាប់ប្រើឲ្យសមទៅតាមការចាំបាច់នៃឯកភាពជាតិ ។ សម្ដេចជាអម្ចាស់ព្រះអង្គបានដឹកនាំប្រជាជាតិក្នុងការប្រើពាក្យនីមួយៗឲ្យចំន័យល្អត្រឹមត្រូវ ។ ព្រះអង្គព្រះរាជបញ្ជាឲ្យចៀសវាងនូវការច្រឡំ ក្នុងការជ្រើសរើសពាក្យហើយនិងការប្រើពាក្យផ្ទុយខុសអំពីគំនិត ។ ព្រះអង្គបានដឹកនាំឲ្យបំពេញនូវការកំណត់ក្បួនវេយ្យាករណ៍និងវាក្យសម្ពន្ធ នូវការបង្កើតពាក្យដើម្បីប្រើប្រាស់ក្នុងវិទ្យាសាស្ត្រ បច្ចេកទេស នយោបាយ និង អក្សរសាស្ត្រ ។

សម្តេចព្រះសង្ឃរាជទ្រង់គង់នៅជាប្រមុខ នៃចលនារៀបចំបែបថ្មីឲ្យស្រប តាមកាលសម័យនៃវប្បធម៌ចំរើននេះ ។ ទូលព្រះបង្គំ ខ្ញុំ សូមបន្ថែមថា ទោះបីព្រះអង្គមានវ័យចាស់ក៏ដោយ ក៏សម្តេចព្រះសង្ឃរាជ ទ្រង់នៅមាន សកម្មភាពណាស់ ។ ទ្រង់បានបង្កើតសមិទ្ធិច្រើនអនេកប្បការគឺព្រះអង្គនៅ មានភាពជាយុវវ័យនៅឡើយ ៗដ៏ពិតណាស់វរជន-អ្នកប្រាជ្ញក្មេងៗក៏ពុំអាច មានថាមភាពនិងប្រសិទ្ធិភាពស្មើនឹងព្រះអង្គបានឡើយ ។ នៅក្នុងពុទ្ធិក-វិទ្យាល័យ និងពុទ្ធិកមហាវិទ្យាល័យ នៅក្នុងគណៈកម្មការនានា និងអង្គការ ផ្សេង ៗ ខាងអក្សរសាស្ត្រ សម្តេចព្រះសង្ឃរាជទ្រង់ជាសាស្តា និងជា អ្នកចាត់ចែងដឹកនាំឧបត្ថម្ភជានិច្ច ។ជាងនេះទៅទៀតការងារដ៏ធ្ងន់ក្រៃលែង នេះពុំមែនតម្កល់ព្រះអង្គត្រឹមតែជាអ្នកនិពន្ធពហុផលប៉ុណ្ណោះទេ ពិសេស ព្រះអង្គជាកវីដែលក្រៅអំពីស្នាព្រះហស្តទាំងឡាយ គឺមានពាក្យពេចន៍ បទចម្រៀង "នគររាជ" ដែលទ្រង់និពន្ធនៅដើមរាជ្យរបស់ទូលបង្គំ ខ្ញុំ គឺក្នុងឆ្នាំ ១៩៤១ ។

អក្សរសាស្ត្រខ្មែរយើង ផ្នែកសាសនា, ទស្សនវិជ្ជា, វិទ្យាសាស្ត្រ និរុត្តិសាស្ត្រជាបាលីនិងជាសំស្ក្រឹត មានតម្លៃ មានឋានៈដ៏ខ្ពស់ឧត្តុង្គឧត្តម ណាស់នៅលើផ្ទៃពិភពអន្តរជាតិ និងក្នុងចំណោមនៃអត្ថបទនានាដ៏មានតម្លៃ នៃវប្បធម៌សកលលោក ។ ប៉ុន្តែ យើងមានសេចក្តីស្តាយចំពោះសភាព ទន់ខ្សោយនៃអក្សរសាស្ត្រផ្នែករឿងកវីធម្មតា ដូចជាប្រលោមលោក

ទាំងជា ។ល។ បុព្វហេតុនៃសភាពទន់ខ្សោយនេះ គឺបណ្ដាលមកតែអំពីសម្ដេចទាំងព្រះភិក្ខុសង្ឃជាអ្នកចេះដឹងយើង ព្រះអង្គពុំអាចចូលរួមបានក្នុងចលនាបែបនេះ ពីព្រោះផ្ទុយនឹងវិន័យរបស់ព្រះអង្គ ។

អ្នកទទួលខុសត្រូវក្នុងវិស័យអក្សរសាស្ត្របែបធម្មតានេះ ច្រើនតែល្អក់ទៅក្នុងនយោបាយ ឬមនោគមវិជ្ជា ឬមួយជាអ្នកគិតតែពីរឿងរកចំណេញលុយ ដែលជាហេតុដឹកនាំគេ ឲ្យធ្លាក់ទៅក្នុងផ្លូវផ្ទុយនឹងសីលវិជ្ជា ឬមួយផ្លូវថោកទាប ។ ចំណែកឯជនរួមជាតិយើង ដែលមានគំនិតវិជ្ជាអន្តរជាតិ ឬ មួយមិនប្រសប់ប្រើនូវភាសាជាតិ ដោយពុំយល់ជ្រៅជ្រះ ឬមួយជាប់រវល់នឹងមុខងារខាងនយោបាយ ឬក្នុងមុខក្រសួងរាជការវិញ ក៏ជាឧបសគ្គរារាំងពុំឲ្យគេចូលមកជួយលើកតម្កើងអក្សរ-សាស្ត្រជាតិរបស់ខ្លួនបាន ។ តែក្នុងខណៈនេះ ស្នាព្រះហស្ដដ៏ល្អលើសលុបនិងមិនចេះសាបសូន្យនៃសម្ដេចព្រះសង្ឃរាជ ជួន ណាត តែមួយព្រះអង្គនេះ ក៏គ្រប់គ្រាន់បរិបូណ៌នឹងបញ្ចាំងនូវរស្មីចិញ្ចែង នៃអក្សរសាស្ត្ររបស់ប្រទេសជាតិយើងទាំងមូល ទៅលើឆាកអន្តរជាតិ ។ គឺជាក័ត្តសំណាងធំអស្ចារ្យរបស់យើង ដែលមានព្រះអង្គសម្ដេចជាបុត្រនៃកម្ពុជរដ្ឋ ។ រួចមកហើយ សម្ដេចព្រះអង្គជា "ព្រះពជា,, នៃព្រះសាសនាពិសិដ្ឋរបស់យើង, ហើយពិសេសទៅទៀត ប្រវត្តិសាស្ត្រច្បាស់ជាទទួលគត់ត្រាទុកព្រះអង្គជា „ព្រះពជា" នៃអក្សរសាស្ត្រខ្មែរជាប្រាកដ ។